ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ព្រះមហាវីរក្សត្រ នរោត្តម សីហនុ : សមភាព និងការផ្សះផ្សា

◆ ការកេណ្ឌទ័ព និងមនោគមវិជ្ជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៥៨ ខែកុម្ភៈ ឆ្នាំ២០១៣

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៥៨ ខែកុម្ភៈ ឆ្នាំ២០១៣


## មាតិកា


◆ព្រះមហាវីរក្សត្រ នរោត្តម សីហនុ ........ ១

### ផ្នែកឯកសារ

◆បញ្ជីឈ្មោះ និងរូបថតអ្នកទោសមន្ទីរស-២១ ........ ៣

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆មិនដែលភ្លេចបងប្អូន ........ ៧

◆ជីវិតក្នុងកំព្រា ........ ១១

◆ការកេណ្ឌទ័ព និងមនោគមវិជ្ជា ........ ១៣

### ផ្នែកច្បាប់

◆អៀង ធីរិទ្ធៈ អតីតកាលនៅតែអន្ទោល ........ ២៨

◆សេចក្ដីសម្រេចស្ដីពីការថតខ្សែអាត់សំឡេង ........ ៤២

◆កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌល ........ ៤៥

### វេទិកាពិភាក្សាសាធារណៈ

◆ការសោយព្រះទិវង្គតរបស់ព្រះមហាវីរក្សត្រ ........ ៥៤

◆ចាមមូស្លីមនៅម៉ាឡេស៊ីផ្ដល់ទស្សនៈពីការ ........ ៥៦

### ធំព័រស្រាវជ្រាវរកក្រុមគ្រួសារ

◆ ដំណើរជីវិតខ្ញុំ ........ ៥៨







## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩


រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះ ៖** អេង កុកថាយ, អាន រ៉ាហ៊ីន, លី សុខឃាង, អាន ហាញឌុល, វ៉ានឌុល ឌីហ្វាល់កូ, ម៉ែន ពិចិត្រ, លន់ដាលីន, ឌី ខាំបូលី, សូ ហ្វារីណា, តាំង ស៊ីនឿន
**អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុនិន្ទ, ស៊ុន សុធីតា **អ្នកបកប្រែ ៖** នង ច័ន្ទមល្លិកា និង ភួង ច័ន្ទប្រណិត **និពន្ធនាយកទូទៅ ៖** ឆាំង យុ និង ញាណ សុជាតិ
**ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង វើង Email: dccam@online.com.kh,
Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ព្រះមហាវីរក្សត្រ នរោត្តម សីហនុ : សមភាព និងការផ្សះផ្សា

ព្រះមហាវីរក្សត្រ នរោត្តម សីហនុ គឺជាបុគ្គលដ៏មានសុទិដ្ឋិនិយម មានព្រះកាយពលមាំមួន និងមានព្រះវោហាសព្ទ ប្រកបដោយប្រជាប្រិយភាព ។ ព្រះអង្គគឺជាបុគ្គលដែលមានភាពរីករាយក្នុងជីវិត ហើយតែងតែគោរពចំពោះមនុស្សដទៃ មិត្តភក្តិ និងសត្រូវ ។ នៅពេលដែលព្រះអង្គឡើងគ្រងរាជ្យសម្បត្តិពេលព្រះជន្ម១៩ព្រះវស្សា ព្រះអង្គបានខិតខំពង្រីកក្តីមេត្តា និងបង្កើនភាពវាងវៃខាងនយោបាយជាច្រើនឆ្នាំ រហូតព្រះអង្គមានទំនុកចិត្តគ្រប់គ្រាន់ហ៊ានដាក់រាជ្យក្នុងឆ្នាំ១៩៥៥ ។ ប៉ុន្តែជីវិតរបស់ព្រះអង្គបានឆ្លងកាត់របត់នយោបាយជាច្រើនដំណាក់កាលផ្សេងៗគ្នា ។ តើព្រះអង្គនឹងទទួលបានការអភ័យទោសចំពោះចំណាត់ការក្តៅដែលព្រះអង្គធ្វើទៅលើក្រុមនយោបាយប្រឆាំងនឹងព្រះអង្គ ដូចជាការសម្លាប់ជាសាធារណៈ និងការចាក់បញ្ចាំងសកម្មភាពសម្លាប់ទាំងនោះតាមរោងកុនដែរឬទេ? ខ្ញុំគិតថានោះគឺជាវិធានការកាលសម័យនោះដែលបានកន្លងផុតទៅហើយ ។ បន្ទាប់មក សម្តេច នរោត្តម សីហនុ បានចុះព្រះហស្តលេខាលើការលុបចោលការកាត់ទោសប្រហារជីវិតក្នុងទសវត្សរ៍៩០ ។ ប៉ុន្តែកេរដំណែលមួយក្នុងចំណោមកេរដំណែលចុងក្រោយជាច្រើនរបស់ព្រះអង្គគឺជាការស្រឡាញ់ស្មើគ្នាចំពោះក្រុមពូជសាសន៍ និងសាសនាផ្សេងគ្នាក្នុងប្រទេសកម្ពុជាដែលហាក់បីដូចជារឿងថ្មីកាលគ្រានោះ ។ ខណៈដែលព្រះអង្គប្រកាន់យកមាគ៌ាដូច្នេះ ចលនាសិទ្ធិមនុស្សនៅសហរដ្ឋអាមេរិកកំពុងតែកើតឡើងយ៉ាងគំហុក ។ ប៉ុន្តែប្រទេសអាហ្វ្រិកខាងត្បូងនៅតែត្រូវការរយៈពេល៤០ឆ្នាំក្រោយមកទៀត រហូតដល់មានការលុបបំបាត់ចោលច្បាប់ប្រឆាំងជនជាតិស្បែកខ្មៅ ។

ក្នុងទសវត្សរ៍៥០ និង៦០ សម្តេចព្រះ នរោត្តម សីហនុ បានដាក់ឈ្មោះក្រុមសាសានា ពូជសាសន៍ និងនយោបាយផ្សេងគ្នាក្នុងប្រទេសកម្ពុជាដែលផ្តើមដោយពាក្យ "ខ្មែរ" ។ ការដាក់ឈ្មោះនោះរួមមាន ខ្មែរស ខ្មែរក្រហម ខ្មែរខៀវ ខ្មែរអ៊ីស្លាម ខ្មែរកុម្មុយនីស្ត ខ្មែរលើ ខ្មែរក្រោម ខ្មែរដើម និងខ្មែរឥស្សរៈ ។ យើងក៏ឮពាក្យខ្មែរកាន់ព្រះពុទ្ធសាសនាដែរកាលគ្រានោះ ។ ខ្មែរទាំងអស់ត្រូវបានចាត់ទុកថាជាកូនចៅរបស់ព្រះអង្គ ។ ព្រះអង្គប្រើ


ជនជាតិភាគតិចភ្នំចូលរួមពិធីដង្ហែព្រះបរមសពព្រះមហាវីរក្សត្រ នរោត្តម សីហនុ កាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៣

សភាពនៃកន្លែងរស់នៅ និងចរន្តនយោបាយដើម្បីដាក់ឈ្មោះឲ្យក្រុមទាំងនោះ ។ ឧទាហរណ៍ ខ្មែរលើត្រូវបាននិយាយសំដៅទៅលើជនជាតិភាគតិចដែលរស់នៅតំបន់ខ្ពង់រាប ហើយខ្មែរក្រោមសំដៅទៅលើជនជាតិខ្មែរដែលរស់នៅតំបន់ទំនាប ។

ប្រទេសកម្ពុជាត្រូវបានបែងចែកទៅតាមរយៈផែនទីភូមិសាស្ត្រ ។ នាសម័យមុនអង្គរ ប្រទេសកម្ពុជាត្រូវបានបែងចែកជាចេនឡាដីគោក និងចេនឡាដីទឹក ។ នេះប្រហែលជាដោយសារនៅតំបន់កណ្តាលប្រទេសកម្ពុជាមានទំនាបដែលលេចទឹកតាមរដូវកាលជុំវិញបឹងទន្លេសាប និងប្រព័ន្ធផ្លូវទឹកទន្លេមេគង្គ ។ ទីតាំងភូមិសាស្ត្រនោះ បង្កើតបានជាអត្តន័យមួយក្នុងចំណោមប្រជាជនកម្ពុជាក្នុងការបែងចែកប្រទេសជាពីរផ្នែកដូចជា ផ្នែកខាងក្រោមគឺជាតំបន់ទំនាបមានទឹក ហើយផ្នែកខាងលើគឺជាតំបន់ខ្ពង់រាបហួតហែង ។ ការដាក់ឈ្មោះ ខ្មែរស (ខ្មែរសេរីកា) ខ្មែរក្រហម ខ្មែរកុម្មុយនីស្ត និងខ្មែរឥស្សរៈ(ខ្មែររំដោះ) ត្រូវបានប្រើសម្រាប់កំណត់អត្តសញ្ញាណក្រុមនយោបាយ ។ ពេលខ្លះ ការដាក់ឈ្មោះនេះកើតឡើងស្របតាមនយោបាយពិភពលោក ។

ការចាត់ថ្នាក់ជនមូស្លីមក្នុងប្រទេសកម្ពុជាថាជាខ្មែរអ៊ីស្លាមគឺជារឿងគួរឲ្យចាប់អារម្មណ៍ ។ មានរឿងគួរឲ្យចម្លែកចិត្តដែលពាក្យមូស្លីមមិនត្រូវបានប្រើក្នុងភាសាខ្មែរដើម្បីនិយាយសំដៅទៅរកអ្នកកាន់សាសនាអ៊ីស្លាមនោះឡើយ ប៉ុន្តែពាក្យអ៊ីស្លាមត្រូវបានប្រើដើម្បីនិយាយសំដៅទៅរកសាសនា និងអ្នកកាន់សាសនានោះ ដូច្នេះប្រជាជនខ្មែរនាពេលបច្ចុប្បន្នតែងតែហៅជន មូស្លីមថាជា "អ៊ីស្លាម" ។ ការដាក់ឈ្មោះជនមូស្លីមក្នុងប្រទេសកម្ពុជារបស់សម្តេចព្រះ នរោត្តម សីហនុ ថាជាជនជាតិខ្មែរដែលកាន់សាសនាផ្សេងគ្នានោះបានបង្ហាញពីការស្រឡាញ់យ៉ាងកក់ក្តៅរបស់ព្រះអង្គចំពោះប្រជាជនមូស្លីមទាំងនោះ ទោះបីជាប្រជាជនទាំងនោះមានពូជសាសន៍ខុសគ្នាក៏ដោយ ។ ព្រះអង្គបានដើរតួជាអ្នកនយោបាយផ្សះផ្សាដែលបង្រួបបង្រួមក្រុមសាសនា និងពូជសាសន៍ទាំងអស់ក្នុងសង្គមដែលបានបែងចែកតាមរយៈស្ថានភាពសេដ្ឋកិច្ច និងពូជសាសន៍ ។

ទោះបីជាយ៉ាងនេះក៏ដោយ ក្នុងការបង្កើតខ្មែរអ៊ីស្លាម សម្តេចព្រះ នរោត្តម សីហនុ ផ្នែកការបែងចែករបស់ព្រះអង្គលើទស្សនៈច្បាស់លាស់មួយចំនួន ។ ជនមូស្លីមក្នុងប្រទេសកម្ពុជារួមមានជនជាតិចាម ជនជាតិជ្វា និងជនជាតិខ្មែរដែលប្រកាន់សាសនាអ៊ីស្លាម ។ ជនជាតិជ្វានិយាយភាសាខ្មែរញឹកញាប់ដូចគ្នាទៅនឹងភាសាម៉ាឡេ ។ សព្វថ្ងៃ ក្រៅពីពាក្យថាអ៊ីស្លាម ជនជាតិជ្វាមិនមានលក្ខណៈផ្សេងគ្នាពីជនជាតិខ្មែរដែលនិយាយភាសាខ្មែរនោះឡើយក្រៅពីសាសនា ។ ដូច្នេះ ពាក្យខ្មែរអ៊ីស្លាមត្រូវប្រើសម្រាប់ហៅជនជាតិជ្វាត្រឹមត្រូវជាងប្រើសម្រាប់ហៅជនជាតិចាម ។

អំឡុងពេលដង្ហែក្បួនព្រះបរមសពរបស់ព្រះមហាវីរក្សត្រ នរោត្តម សីហនុ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៣ វាគឺជារឿងដែលគួរឲ្យស័ក្តិសមដែលប្រជាជនដែលមានពូជសាសន៍ សាសនា និងនយោបាយផ្សេងគ្នា បានចូលរួមគោរព និងលាចំពោះមេដឹកនាំដ៏អស្ចារ្យមួយរូបក្នុងចំណោមមេដឹកនាំដ៏អស្ចារ្យជាច្រើនក្នុងប្រទេសកម្ពុជា ។ ពេលដែលបិតារបស់ព្រះអង្គ នរោត្តម សុរាម្រិត បានសោយព្រះទិវង្គតក្នុងឆ្នាំ១៩៦០ ព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពរបស់ព្រះអង្គត្រូវបានរៀបចំឡើងដោយមានការចូលរួមពីប្រជាជនមាននិន្នាការផ្សេងៗគ្នា ។ ព្រះរាជពិធីនោះទំនងជាកើតឡើងដោយសារការរៀបចំយ៉ាងល្អរបស់ព្រះមហាវីរក្សត្រ នរោត្តម សីហនុផ្ទាល់ព្រះអង្គ ។ **អេង កុកថាយ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthsocheat@dccam.org*

*Home page: www.dccam.org*

# បញ្ជីឈ្មោះនិងរូបថតអ្នកទោសមន្ទីរស-២១ដែល ទទួលបាននៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២

**អ្នកកត់ត្រា ៖ ឆាំង យុ, ញាណ សុដាតិ និង ស៊ីវ សាវីណា**

**(តពីលេខមុន)**

| ល.រ | ឈ្មោះ | ភេទ | លេខរូបថត | រឿងរ៉ាវទាក់ទងនឹងប្រវត្តិរូបសង្ខេប |
|---|---|---|---|---|
| ២៩៩ | ព្រាប គូ | ប្រុស | ១២ | ដ៤ |
| ៣០០ | ជុំ សុខន | ប្រុស | ១០ | រទេះភ្លើង ២៨.១០.៧៦ |
| ៣០១ | សៀង សុផល | ប្រុស | ៨ | មេពួក |
| ៣០២ | ឈូក ចាន់ថា | ប្រុស | ១៨ | ផ្សារតូច ៤.៨.៧៦ |
| ៣០៣ | សុក សៀត | ប្រុស | ៩ | កងរយ |
| ៣០៤ | ផួន ឈាងគីម | ប្រុស | ២២ | ប្រធានកងជួសជុល ៦.៩.៧៦ |
| ៣០៥ | កុង ណន | ប្រុស | ៤ | ស្នងការ កងហា |
| ៣០៦ | ស៊ឹង យាន | ប្រុស | ៧ | យុទ្ធជន ១៥ ៨.១១.៧៦ |
| ៣០៧ | អែម វ៉ាន់សី | ប្រុស | ១០ | ប្រធានក្រុម |
| ៣០៨ | យស់ ឈិន | ប្រុស | ២០ | ប្រធាន វ,ត |
| ៣០៩ | អ៊ុង សុន | ប្រុស | ៤ | បញ្ជាការ វ,ត |
| ៣១០ | ប៊ុន លាង | ប្រុស | ? | កងពលទី៣ ៣១.៨.៧៦ |
| ៣១១ | ទេព លន | ប្រុស | ? | ស-២១យ |
| ៣១២ | ញឹក ហនរ៉េន | ប្រុស | ២៣ | ពាណិជ្ជកម្ម |
| ៣១៣ | ម៉ើ ភា | ប្រុស | ៩ | មេក្រុម ៥០២ |
| ៣១៤ | សឹន សុវ៉ាន់ថា | ប្រុស | ២ | រទេះភ្លើង |
| ៣១៥ | ស៊ិន សុន | ប្រុស | ១១ | វ,ត |
| ៣១៦ | សរិទ្ធ សាយ | ប្រុស | ? | កង១៣ |
| ៣១៧ | ស្រុន អៀងឡាយ | ស្រី | ? | កូនកម្មករចាស់ |
| ៣១៨ | ឡុង វ៉ានី | ស្រី | ១១ | ប្រពន្ធ មួង សារឿន ២៩.១០.៧៦ |
| ៣១៩ | ប៉ុល ខាត់ | ប្រុស | ? | កងពល ៧០៣ ១.៩.៧៦ |
| ៣២០ | សូសយ សៀក | ប្រុស | ? | អនុក្រុម |
| ៣២១ | វឿ វឿន | ប្រុស | ២ | កងសាលា ដ(?) |
| ៣២២ | ម៉ៅ ទី | ប្រុស | ២២ | យុទ្ធជន |

| | | | | |
|---|---|---|---|---|
| ៣២៣ | ចេង ស៊ីយ៉មប៊ិន | ប្រុស | ១៩ | ស័ក្តិប្រាំ |
| ៣២៤ | កែវ គីម | ប្រុស | ? | គ្រូបង្រៀនបុរីកីឡា, ស័ក្តិបី |
| ៣២៥ | ឡុង ឡេង | ប្រុស | ១៣ | រោងចក្រស្រាបៀរ |
| ៣២៦ | នួន ទន់ | ប្រុស | ? | យោធាកងពល១៧០ |
| ៣២៧ | ឯម សន (សុត) | ប្រុស | ១១ | អនុរយ |
| ៣២៨ | ឈុន សារុន | ប្រុស | ? | កងហា |
| ៣២៩ | យន អួន | ប្រុស | ១ | វរធំ ១២១ |
| ៣៣០ | ស៊ឹម ស៊ីឡេណ | ប្រុស | ៧ | ស័ក្តិមួយ តំបន់២៥ |
| ៣៣១ | កែន ខុន | ប្រុស | ? | មេក្រុម ១៦៤ |
| ៣៣២ | ហៃ ឡេង | ប្រុស | ១៩ | យុទ្ធជន ១៣ ស-២១យ ៩.១១.៧៦ |
| ៣៣៣ | ឈុំ ឈន | ប្រុស | ២១ | យុទ្ធជន ១៣ ស-២១យ ៩.១១.៧៦ |
| ៣៣៤ | យិន យី | ប្រុស | ? | ស-២១យ |
| ៣៣៥ | ញឹក ជ្រា | ប្រុស | ? | ប្រធានកងហា |
| ៣៣៦ | នួន អុន | ប្រុស | ? | ១៧០ |
| ៣៣៧ | ចាន់ ដាន | ប្រុស | ? | ១៧០ |
| ៣៣៨ | សុក អឿន | ប្រុស | ? | បញ្ជាការ វ,ត |
| ៣៣៩ | ប៉ុក ប៉ុញ | ប្រុស | ? | យោធាស្រុក (ហង សារិន) |
| ៣៤០ | វង់ សេន | ប្រុស | ? | អនុកងសេនាតូច ១៧០ |
| ៣៤១ | ចាន់ ស៊ីណាត | ប្រុស | ? | ចក្រអង្រែ ៤.៨.៧៦ |
| ៣៤២ | ហាក់ ហៀន | ស្រី | ១ | ហៀង ៣១០ ២២.៩.៧៦ |
| ៣៤៣ | សួស ម៉ត់ (មុត) | ប្រុស | ១១ | ស្រែអំបិល |
| ៣៤៤ | អ៊ុយ ឡេង | ប្រុស | ? | ប្រ,ជនេសាទត្រី |
| ៣៤៥ | ឡុង លន | ប្រុស | ? | ស-២១យ |
| ៣៤៦ | អ៊ឹម សួរ | ប្រុស | ? | កងពល១៧០, អ៊ឹមវ៉ាន់ |
| ៣៤៧ | ចាង សេងណុង | ប្រុស | ២ | គ្រូបង្រៀនមកពីស្រុកបារាំង |
| ៣៤៨ | សុក សាន | ប្រុស | ១៩ | ស័ក្តិមួយ |
| ៣៤៩ | មាស់ ម៉ុន | ប្រុស | ១៨ | ១៧០ |
| ៣៥០ | ពត សុដន | ប្រុស | ១៤ | ស-២១យ ៨.១១.៧៦ |
| ៣៥១ | អ៊ួច ដា | ប្រុស | ១០ | ស្រែអំបិល |
| ៣៥២ | ហង់ សារិន | ប្រុស | ? | ប៉ក់ ប៉ូច |
| ៣៥៣ | ទ្រី មួយ | ស្រី | ៨ | ប្រពន្ធកម្មករ |
| ៣៥៤ | ឡាយ ប៉ៃ | ប្រុស | ? | កង១៣ |

| | | | | |
|---|---|---|---|---|
| ៣៥៥ | ស្រ៊ិន ស្រេង | ប្រុស | ២ | ៨.១១.៧៦ យុទ្ធជន ១២ |
| ៣៥៦ | ជា មរ៉ាំ | ប្រុស | ? | មេក្រុម |
| ៣៥៧ | អ៊ឹម ខុក | ប្រុស | ? | គ៤ |
| ៣៥៨ | កេត ស៊ុម | ប្រុស | ? | វើត |
| ៣៥៩ | មោក មេដា | ប្រុស | ១ | រោងចក្រកៅស៊ូ |
| ៣៦០ | នូ ផុល | ប្រុស | ? | មន្ទីរពេទ្យ ស-២១យ ១៧.៨.៧៦ |
| ៣៦១ | ញយ ដេង | ប្រុស | ? | ប្រ,ជ |
| ៣៦២ | សូ ឯម | ស្រី | ២១ | សំអាត អនុកងរយ |
| ៣៦៣ | យុ មៀងប៊ួរ | ប្រុស | ? | ក.០៧ |
| ៣៦៤ | អាន ហៀវ | ប្រុស | ? | នង សំអឿន ទាហានអាត់សាដង់ |
| ៣៦៥ | លាង ស្រេង | ប្រុស | ២៤ | យុទ្ធជន ១៣ ស-២១យ |
| ៣៦៦ | ឡេង ដឿន | ប្រុស | ១ | ស-២១យ |
| ៣៦៧ | សូ វ៉ា | ប្រុស | ១៣ | ស-២១យ ១៣.១០.៧៨ (ក្មេង) |
| ៣៦៨ | ស៊ិន គួរ | ស្រី | ៣០ | ម្តាយកង សារឿន ២៩.១០.៧៦ |
| ៣៦៩ | ខែក សៀន | ប្រុស | ១២ | ចិញ្ចឹមសត្វ (រូបថតញញឹម) |
| ៣៧០ | អ៊ូ ខន | ប្រុស | ១ | ខ.០៤.៣ |
| ៣៧១ | នាក់ ស៊ីន | ប្រុស | ៥ | ប្រធានក្រុមយ |
| ៣៧២ | ស្រី ដឿន | ប្រុស | ១៨ | យុទ្ធជន |
| ៣៧៣ | ហួត សិត | ប្រុស | ? | កងពល១៧០ |
| ៣៧៤ | ហម អៀម | ប្រុស | ២ | នីរសារ |
| ៣៧៥ | ឌុប យ៉ុន | ប្រុស | ២២ | ជួសជុលយន្តហោះ ព្រិនបាលត្រី |
| ៣៧៦ | កង់ ហ៊ត | ប្រុស | ១៨ | ស័ក្តិពីរ កាំភ្លើងធំ |
| ៣៧៧ | ឌី សាយ | ប្រុស | ? | កូនសិស្សស្វាយរៀង |
| ៣៧៨ | សួង ភុំ | ប្រុស | ៨ | កម្មករចាស់ |
| ៣៧៩ | កែវ មុត | ប្រុស | ៨ | កម្មករទំនប់ |
| ៣៨០ | អៀង ឡាំង | ស្រី | ? | កម្មករ |
| ៣៨១ | ធួន ចុល | ប្រុស | ? | ប្រេងកាត |
| ៣៨២ | ហ៊ីង ស៊ីមង៉ាន់ | ប្រុស | ? | ជួសជុល ជ២៥ ស័ក្តិមួយ |
| ៣៨៣ | ឡេង ប៊ុនណា | ប្រុស | ? | គួយ កំពង់សោម |
| ៣៨៤ | នង សារ៉ាន | ប្រុស | ៦ | មេក្រុម |
| ៣៨៥ | កង ចាន់នី | ស្រី | ៦ | កូនកម្មករ |
| ៣៨៦ | ជែង ភាព | ប្រុស | ៥ | បច្ចេកទេសពុម្ពអក្សរ |

| | | | | |
|---|---|---|---|---|
| ៣៨៧ | ម៉ម កេង | ប្រុស | ២ | ម៉ម សាក់ អនុសេនាធំតំបន់១៥ |
| ៣៨៨ | ឃឹម សាប៊ូន | ប្រុស | ៤ | កងហា |
| ៣៨៩ | កិច មួយ | ស្រី | ៩ | ប្រពន្ធកម្មករ |
| ៣៩០ | កង សារឿន | ស្រី | ២ | ប្រពន្ធ យស់ សារឿន ២៩.១០.៧៦ |
| ៣៩១ | ឌី ហេង | ប្រុស | ២ | គ្មានព័ត៌មាន |
| ៣៩២ | នៅ លឹមអេង | ប្រុស | ២៤ | រទេះភ្លើង ២៨.១០.៧៦ |
| ៣៩៣ | ប៉ាល់ សំបូរ | ប្រុស | ៥ | អនុកងហា |
| ៣៩៤ | ទិត ឡៃ | ប្រុស | ១០ | សាមីន |
| ៣៩៥ | គង់ ជា | ប្រុស | ១២ | មេក្រុម៥ ៨.១១.៧៦ |
| ៣៩៦ | ជាប ឡាំង | ប្រុស | ៥ | កងពល ១៧០ |
| ៣៩៧ | ចក់ ហុន | ប្រុស | ៣ | ប្រធានកងហា |
| ៣៩៨ | វន ដួន | ប្រុស | ១៩ | យុទ្ធជន ៥០២ |
| ៣៩៩ | ឡាយ គីមហេង | ស្រី | ១ | ប្រពន្ធ ព្រាប គូ ២០.១០.៧៦ |
| ៤០០ | ឡាយ សឿន | ប្រុស | ១២ | នីរសារ |
| ៤០១ | សុខ ស៊ិនប៊ុន | ប្រុស | ? | ទ័ព ដុះ០៧ |
| ៤០២ | ម៉ូត ហេន | ប្រុស | ? | ស៊ើង ប្រេងកាត |
| ៤០៣ | គ្រី ជា | ប្រុស | ? | មន្ទីរពិកា |
| ៤០៤ | គីម សាង | ប្រុស | ? | ទាហានស័ក្តិបី |
| ៤០៥ | ទា ខេង | ប្រុស | ៣ | រោងចក្រ |
| ៤០៦ | ឡាយ ផ្សេង | ស្រី | ២០ | ប្រពន្ធស័ក្តិបួន |
| ៤០៧ | អ៊ុក សាវី | ស្រី | ១៨ | ប្រពន្ធកម្មករ |
| ៤០៨ | ប៉ាង សុខុន | ស្រី | ១ | ប្រពន្ធកម្មករ |
| ៤០៩ | ពេញ លាងអួន | ស្រី | ៣ | រោងចក្រ គ៣ |
| ៤១០ | នេត ប៊ុន នឿង | ប្រុស | ១៩ | ដេត មន្ទីរផ្គត់ផ្គង់ |
| ៤១១ | នួន ស៊ាម | ប្រុស | ? | ដាន ១.៨.៧៦ |
| ៤១២ | ដួន វួន | ប្រុស | ១២ | អនុកងហា ថាមពល |
| ៤១៣ | ម៉ៅ សេង | ប្រុស | ? | វ,ត កងពល ១៧០ |
| ៤១៤ | សៀង ចិន | ស្រី | ៦ | ប្រពន្ធ អ៊ូ ខុន |
| ៤១៥ | ស្រេង ណាំ | ប្រុស | ? | ទាហានជើងទឹក |
| ៤១៦ | ភួង ថាញ់ | ប្រុស | ? | ស័ក្តិបួនកន្ទះ |
| ៤១៧ | ហ៊ីង ស៊ីផាត | ប្រុស | ? | គឹម សុត ស័ក្តិពីរ |
| ៤១៨ | ស៊ិន សារឿន | ប្រុស | ? | ជំនួយកងពល ២៤.៧.៧៦ **(នៅមានត)** |

# មិនដែលភ្លេចបងប្អូនដែលបានស្លាប់ក្នុងរបបខ្មែរក្រហម

សូរ រចនា មានអាយុ៥០ឆ្នាំ ជាប្រធានរមណីយដ្ឋានវត្តភ្នំ ។ រចនា មានស្រុកកំណើតនៅភូមិអំពិលក្រោម ឃុំអំពិលក្រោម ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

រចនា ជាកូនប្រុសទីពីរ ក្នុងចំណោមប្អូនបង្កើតប្រាំនាក់ ។ រចនា មានឪពុកឈ្មោះ សូ គឹមសេង អតីតធ្វើការនៅរោងចក្រតម្បាញ ក្រុងកំពង់ចាម និងមានស្រុកកំណើតនៅឃុំសាន់គរ ស្រុកកំពង់សា្វយ ខេត្តកំពង់ធំ ។ ចំណែកម្តាយគាត់មានឈ្មោះ សូ រ៉េត (បច្ចុប្បន្ន អាយុប្រមាណជាង៧០ឆ្នាំ) អតីតធ្វើការនៅរោងចក្រតម្បាញជាមួយឪពុកគាត់ដែរ ។

កាលពីកុមារភាព រចនា បានចូលរៀននៅសាលាបឋមសិក្សាក្នុងភូមិអំពិលក្រោម ។ រៀនបានរយៈពេលបីឆ្នាំ (ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៣) គាត់ក៏ឈប់រៀនដោយសារមានការវាយប្រយុទ្ធគ្នារវាងយោធារំដោះខ្មែរក្រហម និងកងទ័ពរបស់លោកសេនាប្រមុខលន់នល់ ។ នៅក្នុងហេតុការណ៍នោះ កងយោធាខ្មែរក្រហមវាយយកបានភូមិ និងតំបន់ជាច្រើនទៀតដែលនៅព័ទ្ធជុំវិញក្រុងកំពង់ចាម មកគ្រប់គ្រង រួមទាំងតំបន់ដែល រចនា រស់នៅ ។

ដោយទទួលបានដំណឹងនោះ បងជីដូនមួយរបស់ រចនា ឈ្មោះ ឃុន ប្រកបរបរនេសាទ និងជាឈ្មួញរកស៊ីនៅភូមិសាន់គរ (ស្ថិតនៅជាប់បឹងទន្លេសាប) ដែលជួយឧបត្ថម្ភចលនាខ្មែរក្រហម បានទាក់ទងជាមួយខ្មែរក្រហមដើម្បីយកគ្រួសារ រចនា ពីភូមិអំពិលប្រាំ មកនៅភូមិសាន់គរ ជាមួយគាត់វិញ ។



សូ រចនា ថតពេលសម្ភាសន៍នៅរមណីយដ្ឋានវត្តភ្នំ កាលពីថ្ងៃទី២០ ខែមករាកន្លងទៅ

ឪពុកម្តាយរបស់ រចនា មិនមានមុខរបររកស៊ីនៅក្នុងភូមិសាន់គរទេ ដូច្នេះគាត់ត្រូវយកលុយកាក់ដែលសន្សំបានបន្តិចបន្តួចដើម្បីទិញអាហារសម្រាប់កូនៗ និងគ្រួសារទាំងមូល ។ ដូច្នេះហើយទើបឪពុកម្តាយរបស់ រចនា បានធ្វើស្រែបន្ថែមដើម្បីផ្គត់ផ្គង់ជីវភាព ។ ប៉ុន្តែ មិនយូរប៉ុន្មាន ឪពុករបស់ រចនា ចាប់ផ្តើមធ្លាក់ខ្លួនឈឺធ្ងន់ ហើយគាត់ក៏ស្លាប់នៅទីនោះទៅ ។ បន្ទាប់ពីស្នាក់នៅភូមិសាន់គរបានរយៈពេលប្រាំពីរខែ គឺនៅដើមឆ្នាំ១៩៧៤ ម្តាយរបស់ រចនា បានទៅនិយាយជាមួយក្មួយឈ្មោះ ឃុន ដើម្បីសុំចេញទៅរស់នៅតំបន់ លន់ នល់ វិញ ព្រោះគាត់មិនអាចស៊ូទ្រាំនឹងការងារស្រែចម្ការនិងការខ្វះខាតអាហារហូបចុកបាន ។ ដោយសារអាណិតអាសូរម្តាយរបស់គាត់ ឃុន ក៏បានទៅទាក់ទងជាមួយខ្មែរក្រហមដែលគ្រប់គ្រងក្នុងភូមិដើម្បីអនុញ្ញាតឲ្យគ្រួសារ រចនា បានចាកចេញពីភូមិ ។

រចនា នៅចងចាំថា «នៅថ្ងៃនោះម្តាយរបស់គាត់បានប្រាប់កូនៗទាំងអស់ឲ្យរៀបចំស្លៀកពាក់ដើម្បីចាកចេញ» ប៉ុន្តែ រចនា មិនបានសួរម្តាយគាត់ថាទៅណាទេព្រោះគាត់នៅក្មេងពេក ។ រចនា រង់ចាំរហូតដល់ម៉ោងប្រាំបួនយប់ ទើបម្តាយរបស់គាត់នាំកូនទាំងអស់ទៅជិះទូករបស់ជនជាតិវៀតណាមប្រកបរបរនេសាទត្រីដែលម្តាយគាត់ បានជួលទុករួចហើយ ។ អ្នកបើកទូកនោះបានឲ្យម្តាយរបស់គាត់ រួមទាំងបង

ប្អូនគាត់ទាំងអស់ដេកតម្រៀបនៅខាងក្រោមបាត់ទូកដើម្បីការពារកុំឲ្យឈ្លបខ្មែរក្រហមមើលឃើញ ។

នៅតាមផ្លូវ រចនា បានដេកលក់ទោះបីពេលនោះសំឡេងម៉ាស៊ីនទូករោទ៍ឮយ៉ាងណាក៏ដោយ ។ គាត់បានភ្ញាក់ឡើងពេលទូកមកចតនៅប្រាំងទន្លេក្រុងកំពង់ឆ្នាំង ។ បន្ទាប់មកម្ដាយរបស់ រចនា បាននាំកូនទាំងប្រាំទៅជិះឡានដើម្បីធ្វើដំណើរសំដៅទៅខេត្តបាត់ដំបង ។ ប៉ុន្តែពេលមកដល់ស្រុកក្រគរ ខេត្តពោធិ៍សាត់ អ្នកបើកបរឡានក៏ឈប់នៅទីនោះ ព្រោះផ្លូវនៅខាងមុខត្រូវយោធាខ្មែរក្រហមវាយកាត់ផ្ដាច់ និងគ្រប់គ្រងហើយ ។ ខណៈនោះ ម្ដាយរបស់ រចនា បានទាក់ទងទៅបងប្អូនជីដូនមួយរបស់គាត់ឈ្មោះ ស្រី មាស ជាឧត្ដមសេនីយ៍ក្នុងរដ្ឋាភិបាល លន់ នល់ ដើម្បីរកមធ្យោបាយធ្វើដំណើរឲ្យដល់ខេត្ត ។ នៅថ្ងៃដដែល ស្រី មាស បានឲ្យគ្រួសារ រចនា ឡើងជិះយន្តហោះយោធា ឬហៅថា «អាដំរី» ទៅទីរួមខេត្តបាត់ដំបងនៅពេលរសៀល ។

នៅទីរួមខេត្តបាត់ដំបងបានរយៈពេលបីថ្ងៃ ម្ដាយរបស់ រចនា បានទាក់ទងសុំលោក សុគុន (អតីតចាងហ្វាងសាលាដំបូងនៅខេត្តកំពង់ចាម និងជាមន្ត្រីមានបុណ្យស័ក្តិខ្ពស់ក្នុងរបប លន់ នល់ ដែលត្រូវជាបងប្អូនរបស់គាត់) ចូលធ្វើការនៅរោងចក្រកាត់ដេរខោអាវដើម្បីយកលុយចិញ្ចឹមកូន ។ ម្ដាយរបស់ រចនា ត្រូវបានជ្រើសរើសឲ្យចូលធ្វើការនៅរោងចក្រកាត់ដេរ ដែលមានទីតាំងស្ថិតនៅក្នុងភូមិគីស៊ុនហ៊ី ទីរួមខេត្តបាត់ដំបង ដោយពេលនោះម្ដាយគាត់បានយកកូននិងយាយរបស់ រចនា មករស់នៅក្នុងផ្ទះមួយទល់មុខរោងចក្រដែលសង់ឡើងសម្រាប់ឲ្យកម្មករស្ត្រីស្នាក់នៅ ។

នៅប្រហែលពាក់កណ្ដាលឆ្នាំ១៩៧៤ រចនា និងយាយរបស់គាត់បានទៅលេងលោក សុគុន នៅភ្នំពេញ ដែលពេលនោះលោក សុគុន មានផ្ទះវីឡាពីរគឺមួយនៅទីក្រុងតាខ្មៅ និងមួយទៀតនៅបឹងកេងកង ។ រចនា និងយាយរបស់គាត់បានមកស្នាក់នៅផ្ទះវីឡានៅបឹងកេង ។ នៅទីនោះ រចនា មិនសូវទម្លាប់ខ្លួនទេ ព្រោះផ្ទះលោក សុគុន មានសណ្ដាប់ធ្នាប់ និងវិន័យតឹងរឹង ព្រមទាំងមានភ្ញៀវទាំងស៊ីវិល មន្ត្រីរាជការ និងទាហានចេញចូលមិនលុះពេលឡើយ ។ ភ្ញៀវទាំងនោះតែងតែហៅលោក សុគុន ថា «តេជគុណៗ!» ហើយសូម្បីតែយាយរបស់ រចនា ក៏ហៅលោក សុគុន ថា «លោកប្រុស» ដែរ ។ រៀងរាល់ថ្ងៃ រចនា មើលទូរទស្សន៍នៅក្នុងផ្ទះ ព្រោះមិនមានអ្នកជូនគាត់ដើរលេង ម្យ៉ាងទៀតគាត់ក៏មិនហ៊ានដើរចេញទៅលេងនៅខាងក្រៅដោយគ្មានការអនុញ្ញាតតែឯងបានដែរ ។ រចនា និងយាយរបស់គាត់បានស្នាក់នៅផ្ទះលោក សុគុន រហូតដល់ដើមឆ្នាំ១៩៧៥ ទើបគាត់ត្រឡប់ទៅបាត់ដំបងវិញដោយគាត់ត្រូវជិះយន្តហោះឈ្នួល ។

រចនា បានរស់នៅជាមួយម្ដាយ រហូតដល់កងយោធាខ្មែរក្រហមចូលមកដល់ទីរួមខេត្តបាត់ដំបង នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ រចនា ឃើញយោធាខ្មែរក្រហមពាក់អាវខ្មៅ និងកាន់កាំភ្លើងគ្រប់ដៃ ហើយពេលនោះ គាត់រួមទាំងក្មេងជាច្រើនទៀតបាននាំគ្នាទះដៃ និងស្រែកអបអរយោធាទាំងនោះ ដោយសេចក្ដីរីករាយ ។ ប៉ុន្តែមួយរយៈខ្លីក្រោយមក រចនា បានឃើញយោធាខ្មែរក្រហមជម្លៀសប្រជាជនដែលរស់នៅក្នុងទីក្រុង គ្រូបង្រៀន មន្ត្រីរាជការ និងទាហានឲ្យចាកចេញទាំងអស់ ។ ដោយឡែកខ្មែរក្រហម មិនបានបណ្ដេញកម្មកររោងចក្រចេញទេគឺឲ្យនៅធ្វើការងារដដែល ។ ស្របពេលនោះ ប្រធានរោងចក្រដែលចូលមកគ្រប់គ្រងថ្មី បានជ្រើសរើសម្ដាយរបស់ រចនា ឲ្យធ្វើជាមេក្រុម និងបង្ហាត់បង្រៀនកម្មករក្មេងៗដែលទើបចូលមកថ្មីថែមទៀត ។

នៅដើមឆ្នាំ១៩៧៦ ខ្មែរក្រហមបានប្រមូលក្មេងចាស់រួមទាំង រចនា និងបងប្អូនគាត់ឲ្យចូលធ្វើការនៅរោងចក្រដោយ រចនា មានភារកិច្ចខារអំបោះ ដើម្បីត្បាញជាក្រណាត់ផាឌិប ។ ថ្ងៃខ្លះ រចនា ធ្វើការងាររហូតដល់ម៉ោងដប់យប់ ប៉ុន្តែប្រធានរោងចក្របានផ្ដល់របបអាហារឲ្យគាត់ហូបគ្រប់គ្រាន់គឺមួយថ្ងៃហូបបីពេល ។ នៅទីនោះ ប្អូនប្រុសពៅរបស់ រចនា ម្នាក់បានកើតពិសអាចម៍កុក និងមិនមានពេទ្យព្យាបាលជំងឺនេះឲ្យជាទេ ទើបម្ដាយគាត់សម្រេចចិត្តជួសពិសនោះដោយខ្លួនឯង ។ ប៉ុន្តែ ដោយសារជំងឺប្អូនប្រុសរបស់គាត់ធ្ងន់ធ្ងរពេកក៏ស្លាប់នៅពេលនោះទៅ ។

បន្ទាប់ពីប្អូនស្លាប់ ប្រធានរោងចក្របានរៀបចំធ្វើការជម្លៀសអ្នកធ្វើការនៅរោងចក្រតម្បាញទាំងអស់ឲ្យចាកចេញបណ្ដោះអាសន្ន ដោយសន្យាថាឲ្យចេញរយៈពេលបីខែប៉ុណ្ណោះ ។ ព្រដូច្នេះ បងប្រុសរបស់ រចនា ម្នាក់បានស្ម័គ្រចិត្តចេញទៅមុនគេ ដោយពេលនោះខ្មែរក្រហមបញ្ជូនគាត់ទៅស្រុកមោងឫស្សី ។

ប៉ុន្តែក្រោយមកបងប្រុសរបស់ រចនា បានស្លាប់នៅទីនោះដោយសារឈឺរាក ។

រហូតដល់ដើមឆ្នាំ១៩៧៧ ខ្មែរក្រហមបានបន្តជម្លៀសក្រុមគ្រួសាររបស់ រចនា រួមមានយាយ ម្តាយ និងប្អូនពីរនាក់ ចេញពីរោងចក្រឲ្យទៅរស់នៅសហករណ៍ប្រណាក ស្ថិតនៅក្នុងភូមិព្រៃស្វាយ ឃុំធ្នុងកញ្ចុះ ស្រុកមោងឫស្សីទៀត ។ នៅទីនោះ ខ្មែរក្រហមចាត់តាំងឲ្យម្តាយរបស់ រចនា ស្ទូងស្រូវ និងប្រូតស្រូវនៅក្នុងភូមិ ប្អូនគាត់កាប់ទន្រ្ទានខែត្រ ចំណែកគាត់ត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅនៅក្នុងកងស្រួចលើកទំនប់មួយកន្លែងនៅភូមិព្រៃខ្ទុត ដែលមានចម្ងាយប្រមាណជាង១០គីឡូម៉ែត្រពីភូមិរបស់គាត់ ។ នៅទីនោះ ក្រោយពេលសម្រាកពីការងារម្តងៗ រចនា តែងតែដើរចូលទៅព្រៃដើម្បីរកដើមព្រិចដែលមានរស់ជាតិផ្អែមមកហូបបន្ថែមពីលើរបបដែលចុងភៅចែកឲ្យ ។

រចនា លើកទំនប់នៅភូមិព្រៃខ្ទុត បានរយៈពេលប្រាំបីខែ គាត់ក៏សុំប្រធានកងមកលេងផ្ទះ ក្រោយពីបញ្ចប់ការងារនៅពេលរសៀល ដោយគាត់លួចយកកណ្តុរស្រែដែលរកបាន ហើយបានប្រឡាក់ទុកយកទៅផ្ញើឲ្យក្រុមគ្រួសារគាត់ ។ ប៉ុន្តែពេលមកដល់ផ្ទះ រចនា តក់ស្លុតយ៉ាងខ្លាំង ព្រោះគាត់ឃើញតែម្តាយដែលមានរូបរាងស្គមស្គាំង និងប្អូនស្រីតូចប៉ុណ្ណោះ ។ ក្រោយមក ទើបម្តាយគាត់ប្រាប់ថា យាយរបស់គាត់និងប្អូនប្រុសស្លាប់ហើយដោយសារអត់អាហារហូប ហើយខ្មែរក្រហមយកអ្នកទាំងពីរទៅកប់នៅវត្តរុន (ព្រោះវត្តរុនជាព្រៃ និងកម្រមានមនុស្សទៅដល់ ហើយសាកសពដែលកប់នៅទីនោះ តែងតែមានសត្វឆ្កែចចកមកខាំហែកស៊ីនៅពេលយប់) ។

នៅពេលនោះ ទោះបី រចនា សោកស្តាយ និងចង់នៅកំដរម្តាយយ៉ាងណាក៏ដោយ ក៏គាត់មិនហ៊ាននៅយូរដែរ ព្រោះគាត់ខ្លាចត្រឡប់ទៅធ្វើការមិនទាន់ ហើយម្យ៉ាងទៀតខ្លាចមេកងរកមិនឃើញ និងដាក់ពិន័យគាត់ ។ បន្ទាប់ពីលើកទំនប់នៅព្រៃខ្ទុតចប់ កងរបស់ រចនា បានផ្លាស់ទៅលើកទំនប់រំចេក ទំនប់ត្រដាក់ចិត្ត និងទំនប់រំលេចដែលស្ថិតនៅតំបន់៣វិញ ។ កងស្រួចរបស់ រចនា មានសមាជិកទាំងអស់១០០នាក់ និងបែងចែកជាពីរក្រុម ។ កងរបស់ រចនា បានសង់ខ្ទមរស់នៅបណ្តោះអាសន្នតាមបណ្តោយមាត់ស្ទឹងលាច ដោយមានប្រធានកងឈ្មោះ ម៉ៅ ជាអ្នកគ្រប់គ្រង ។ ការងាររបស់ រចនា គឺរែកដីទប់ស្ទឹង ដើម្បីរក្សាទឹកទុកធ្វើស្រែ ។ ជារឿយៗ សមាជិកកងចល័តបានធ្លាក់ខ្លួនឈឺ ដោយសារការងារធ្ងន់ធ្ងរ និងហូបមិនគ្រប់គ្រាន់ ហើយអ្នកទាំងនោះតែងតែបាត់ខ្លួនក្រោយពេលបញ្ជូនចេញពីកងទៅព្យាបាលនៅមន្ទីរពេទ្យ ។ ដោយសារខ្វះខាតដូច្នេះហើយ ទើបក្រោយពីសម្រាកពីការងារ រចនា តែងតែដើររកសត្វខ្ទង ដែលធ្វើសំបុកនៅក្នុងដំបូក ដើម្បីយកទឹកលំអង (មានរស់ជាតិជូរអែម) មកផឹកដើម្បីឲ្យមានកម្លាំងធ្វើការងារបន្តទៀត ។

នៅល្ងាចថ្ងៃមួយ រចនា បានលួចលូនចូលទៅបេះសណ្តែកគួរដែលខ្មែរក្រហមដាំនៅចម្ការ ស្រាប់តែឈ្លបខ្មែរក្រហមដែលចាំឃ្លាំមើលពីលើចុងត្នោតបានចុះមកទាត់ធាក់ និងជាន់កគាត់ជាប់រួចហើយស្រែកហៅឈ្លបខ្មែរក្រហមផ្សេងទៀតមកចាប់គាត់ចង ។ ព្ធដូច្នេះ រចនា មានការភិតភ័យយ៉ាងខ្លាំង ហើយបានខិតខំរើបម្រះរហូតរួចខ្លួន ។

រចនា លើកទំនប់លាច រហូតកងទ័ពវៀតណាមវាយចូលនៅខែមករា ឆ្នាំ១៩៧៩ ទើបយោធាខ្មែរក្រហមកៀរគាត់ និងកងចល័តឲ្យទៅរលាក់កងដើង ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ ។ នៅទីនោះ រចនា ត្រូវស្នាក់នៅក្នុងព្រៃតែម្តង ចំណែកអាហារគឺមានតែអង្ករដែលគាត់ប្រមូលបានពីកងចល័ត និងសាច់សត្វ ដើមឈើផ្លែឈើដែលរកបានក្នុងព្រៃប៉ុណ្ណោះ ។ រចនា រស់នៅក្នុងព្រៃអស់រយៈពេលជិតបីឆ្នាំ ទើបយោធា និងកងឈ្លបខ្មែរក្រហមរំសាយគាត់ និងកងចល័តឲ្យត្រឡប់ទៅរកបងប្អូនវិញ ព្រោះកងទ័ពវៀតណាមព័ទ្ធជិតអស់ហើយ ។

រចនា បានដើរកាត់តាមទំនប់លាចដើម្បីតាមរកម្តាយ និងប្អូនស្រី ។ រចនា ទៅដល់ភូមិព្រៃស្វាយ (ជាកន្លែងដែលខ្មែរក្រហមជម្លៀសគាត់មកដំបូង) នៅម៉ោងប្រាំមួយល្ងាច ស្រាប់តែគាត់ឃើញប្អូនស្រីរបស់គាត់ដើរចេញពីខ្ទមតូចមួយ ។ រចនា បានជួបជុំម្តាយ និងប្អូនឡើងវិញ ជាមួយនឹងការរំជួលចិត្ត និងការយំខ្សឹកខ្សួល ។ ក្រោយមក ដោយមិនមានបងប្អូនអាចពឹងពាក់បាន ទើបម្តាយគាត់ នាំគាត់និងប្អូនស្រីទៅរស់នៅជំរំចាស់ (នៅម្តុំជំរំណងចាន់) ដោយប្រកបរបរអាំងមាន់លក់ ។ ប៉ុន្តែមិនយូរប៉ុន្មាន កងទ័ព

វៀតណាមបានវាយបែកជំរំចាស់ ទើបក្រុមគ្រួសារ រចនា វិលត្រឡប់មករស់នៅទីរួមខេត្តកំពង់ធំវិញ ។ រចនា បានដើររែកទឹក (ដែលបន្សល់ទុកនូវស្លាកស្នាមលើស្មារបស់គាត់រហូតមកដល់សព្វថ្ងៃ) លក់ឲ្យប្រជាជននៅក្នុងក្រុងកំពង់ធំ ដើម្បីយកលុយផ្គត់ផ្គង់ម្តាយ និងដើម្បីទិញសម្ភារសិក្សា ព្រោះពេលនោះគាត់បានចូលរៀននៅសាលាមធ្យមសិក្សាកំពង់ធំ រហូតដល់រៀនចប់ថ្នាក់វិទ្យាល័យ ។

នៅឆ្នាំ១៩៩៣ រចនា បានផ្លាស់មកស៊ីឈ្នួលដឹកទឹកកកលក់នៅម៉ុំសណ្ឋាគារកាំបូឌីយ៉ាណា ក្រុងភ្នំពេញ ប៉ុន្តែក្រោយមកដោយសារមានការលំបាកខ្លាំងពេកទើបបងប្អូនជីដូនមួយរបស់គាត់បានហៅគាត់ឲ្យទៅជួយលក់ម៉ាញ៉េ និងទូរទស្សន៍នៅផ្សារអូរឫស្សីយកលុយចូលរៀនបន្តនៅមហាវិទ្យាល័យបុរាណវិទ្យា ។

ក្រោយពី រចនា រៀនចប់នៅឆ្នាំ១៩៩៧ គាត់បានចូលបម្រើការងារនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ហើយមកដល់ឆ្នាំ២០០៩ ក្រសួងបានចាត់តាំងគាត់ឲ្យធ្វើជាប្រធានរមណីយដ្ឋានវត្តភ្នំ ។

សព្វថ្ងៃ រចនា មានកូនពីរនាក់ រស់នៅក្រុងតាខ្មៅ ខេត្តកណ្តាល ។ រចនា បានបញ្ជាក់ថា របបខ្មែរក្រហមបានធ្វើឲ្យគាត់បាត់បង់យាយ បងប្អូនបីនាក់ រួមទាំងគ្រួសារ សុគុន និង ស្រី មាស ។ រឿងរ៉ាវនៃការស្លាប់នេះមិនអាចធ្វើឲ្យគាត់បំភ្លេចបានទេរហូតមកដល់បច្ចុប្បន្ន ហើយនៅពេលនេះ ទោះបីជាតុលាការកំពុងកាត់ទោសមេដឹកនាំខ្មែរក្រហមក៏ដោយ ក៏មិនអាចធ្វើគាត់ស្ងប់ចិត្តដែរ ។

**សោម ប៊ុនថន**

## ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ១៩៧៥-១៩៧៩» ចាប់តាំងពីឆ្នាំ២០០៧មកនិងបានចែកចាយដល់សិស្ស-និស្សិតនិងសាធារណជនទូទាំងប្រទេសជាងមួយលាននាក់ ។ ជាមួយគ្នានោះដែរ សៀវនេះត្រូវបានបកប្រែជាច្រើនភាសា ហើយអាចរកបានតាមរយៈ

*http://dccam.org/Projects/Genocide/A Hisotry of DK 2007.htm*

## ខ្សែភាពយន្តឯកសាររឿងក្បង់ទឹកទន្លេ



“ក្បង់ទឹកទន្លេ” គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ ភាពយន្តឯកសារនេះ ក៏ទទួលបានពានរង្វាន់លំដាប់ពិភពលោកនៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០១៣ ។ “ក្បង់ទឹកទន្លេ” បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាលនិងមិនធ្លាប់មានពីមុនមកដែលផ្តើមចេញពីតំបន់ជនបទចុងកាត់មាត់ញក ព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ សាវសាម្មួន រស់នៅកណ្តាលព្រៃភ្នំដាច់ស្រយាលនៃភាគឦសានប្រទេសកម្ពុជា ។ ម៉ុក ខៀវ ដើម្បីរកលុយសងបំណុលត្រូវបង្ខំចិត្តមកធ្វើការនៅរោងចក្រនៅភ្នំពេញ ។ សារី ម៉ាត់ ដើម្បីសម្រួលបន្ទុកគ្រួសារត្រូវឈប់រៀនមកជួយនេសាទត្រីឪពុក ។ ខ្សែភាពយន្តឯកសារនេះមានចាក់បញ្ចាំងជូនទស្សនារាល់ថ្ងៃសុក្រ ។

ព័ត៌មានបន្ថែមសូមទាក់ទងកញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខ: ០១២ ៥១១ ៩១៤

អ៊ីមែល : *truthfatily.s@dccam.org* គេហទំព័រ : *www.ariverchangescourse.com*

# ជីវិតក្មេងកំព្រា



រស់ សំណាង មានតួនាទីជាអនុប្រធានសារមន្ទីរខេត្តពោធិ៍សាត់ ។ សំណាង កើតភូមិបឹងកេងកង សង្កាត់លេខ៦ ក្រុងភ្នំពេញ ។

សំណាង មានឪពុកឈ្មោះ រស់ ជុំ (ស្លាប់) និងម្តាយឈ្មោះ រស់ ម៉ាក (ស្លាប់) ។ សំណាង មានបងប្អូនប្រាំពីរនាក់ ប្រុសបីនាក់ និងស្រីបួននាក់ ហើយគាត់គឺជាកូនទីប្រាំ ។

កាលពីក្មេង សំណាង បានសិក្សានៅសាលាវិចិត្រសិល្បៈផ្នែករបាំ ក្រុងភ្នំពេញ ។ ក្រោយពេលព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ ក្រុមគ្រួសាររបស់ សំណាង បានធ្វើដំណើរកាត់តាមផ្លូវអូរបែកក្អមទៅរស់នៅជាមួយបងប្អូនរបស់គាត់នៅកៀនស្វាយមួយរយៈ ដោយសារមានការច្របូកច្របល់ និងការទម្លាក់គ្រាប់បែករបស់ទាហានអាមេរិកកាំង ។

សំណាង នៅចងចាំថា ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកគ្រប់គ្រងនៅភ្នំពេញ ។ ខណៈពេលនោះ ក្រុមគ្រួសាររបស់គាត់បាននាំគ្នាប្រមូលរបស់របរមួយចំនួនដូចជាសម្លៀកបំពាក់ ចានឆ្នាំង អង្ករ និងរបស់មានតម្លៃខ្លះយកទៅតាមខ្លួន ។ សំណាង ភ័យយ៉ាងខ្លាំងនៅពេលដែលឃើញយោធាខ្មែរក្រហមចូលមកដល់ផ្ទះគាត់ជាមួយសម្លៀកបំពាក់ពណ៌ខ្មៅ បង់កក្រមា និងមានស្ពាយកាំភ្លើងជាប់នឹងដៃហើយបានប្រាប់ទៅឪពុករបស់គាត់ថា «នៅពេលនេះទីក្រុងភ្នំពេញត្រូវសម្អាត ដូច្នេះសូមបងប្អូននាំគ្នាត្រឡប់ទៅរស់នៅស្រុកកំណើតរយៈពេលបីថ្ងៃសិនទើបឲ្យត្រឡប់មកវិញ» ។

ក្រុមគ្រួសាររបស់ សំណាង ត្រូវបានខ្មែរក្រហមជម្លៀសទៅនៅភូមិល្វាឯម ខេត្តកណ្តាល ។ ក្រុមគ្រួសាររបស់គាត់ត្រូវបានអង្គការចាត់តាំងឲ្យរស់នៅ និងធ្វើការនៅក្នុងសហករណ៍ភូមិល្វាឯមជាមួយប្រជាជនដែលជម្លៀសមកពីតំបន់ផ្សេងៗ ។

ក្នុងឆ្នាំ១៩៧៦ គ្រួសាររបស់គាត់ត្រូវបានបញ្ជូនទៅកាន់ខេត្តពោធិ៍សាត់ ។ គាត់ចាំថា ក្រុមគ្រួសាររបស់គាត់បានធ្វើដំណើរតាមរថភ្លើងជាមួយនឹងប្រជាជនជម្លៀសជាច្រើនទៀត ដោយម្នាក់ៗមានស្ពាយអីវ៉ាន់សំពីងសំពោង ប្រកបដោយទឹកមុខក្រៀមក្រំ ។ អ្នកខ្លះយំស្រែកសួររកកូន ហើយអ្នកខ្លះបានវង្វេងម្តាយ និងគ្រួសារ ។

មកដល់វត្តស្រះស្រង់ ខេត្តពោធិ៍សាត់ សំណាង បានឃើញយោធាខ្មែរក្រហមជាច្រើននាក់នៅចាំទទួលរួចជាស្រេច ។ ក្រោយមក ក្រុមគ្រួសាររបស់គាត់បានធ្វើដំណើរបន្តទៅមុខដោយជិះរទេះគោទៅកាន់សហករណ៍ល្វេស ។ នៅទីនោះ ក្រុមគ្រួសាររបស់គាត់បានបែកគ្នា ដោយអង្គការចាត់តាំងគាត់ឲ្យរស់នៅសហរណ៍ល្វេស ចំណែកបងប្អូនទៅនៅភូមិផ្សេង ។

នៅទីនោះ សំណាង ត្រូវអង្គការចាត់តាំងឲ្យចូលកងចល័តដែលមានសមាជិកចំនួនសាមសិបនាក់ក្នុងមួយក្រុម ហើយបង្ខំឲ្យធ្វើការជីកប្រឡាយ លើកទំនប់ និងរែកដី ទាំងយប់ទាំងថ្ងៃគ្មានពេលសម្រាក ។ ចំណែករបបអាហារមិនគ្រប់គ្រាន់ឡើយដែលធ្វើឲ្យ សំណាង ធ្លាក់ខ្លួនឈឺ ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏គាត់នៅតែទៅធ្វើការឲ្យទាន់តាមផែនការរបស់អង្គការដែរ ។

រដូវវស្សាបានចូលមកដល់ សំណាង ត្រូវអង្គការចាត់តាំងឲ្យទៅស្ទូងស្រូវជាមួយមិត្តភក្តិដែលនៅកងចល័តជាមួយគ្នា ។ ការងារនៅទីនោះមានការលំបាកកាន់តែខ្លាំង ម្យ៉ាងទៀត សំណាង រស់នៅម្នាក់ឯងដោយគ្មានបងប្អូនទៅជាមួយ ។ សំណាង តែងតែនឹកដល់គ្រួសាររបស់គាត់ជានិច្ច ។

ថ្ងៃមួយ សំណាង បានសុំការអនុញ្ញាតពីប្រធានកងដើម្បីទៅលេងម្តាយ ហើយដោយមានការអាណិតអាសូរគាត់ ប្រធានសហករណ៍បានយល់ព្រម ។ សំណាង បានដើរកាត់ព្រៃ និងឆ្លងពីភូមិមួយទៅភូមិមួយទៀត ។ នៅពេលទៅដល់ សំណាង បានសម្លឹងមើលមុខម្តាយដោយសេចក្តីត្រេកអរយ៉ាងខ្លាំង ។ ការជួបនោះមានរយៈពេលខ្លីប៉ុណ្ណោះ ព្រោះ សំណាង ត្រូវស្រូតដំណើរទៅកាន់សហករណ៍របស់ខ្លួនវិញឲ្យទាន់ពេលធ្វើការងារ ។

ក្នុងឆ្នាំ១៩៧៧ សំណាង ត្រូវអង្គការផ្លាស់ទៅកាន់សហករណ៍សែនជ័យ ។ ការរស់នៅទីនោះ កាន់តែលំបាកខ្លាំងឡើងៗ ព្រោះចុងភៅបបរមួយខ្ទះដាក់អង្ករតែបីកំប៉ុងប៉ុណ្ណោះ ។ ដោយសារតែការហូបមិនគ្រាន់ សំណាង បានដើរបេះស្លឹកណាដែលអាចហូបបាន ធ្វើយ៉ាងណាបំពេញក្រពះឲ្យឆ្អែតដើម្បីឲ្យមានកម្លាំងធ្វើការ ។ សមាជិកកងចល័តរបស់គាត់ខិតខំប្រឹងប្រែងរៀងៗខ្លួន ។

សំណាង បានបន្ថែមថា អ្វីដែលគាត់ឈឺចាប់ជាងគេនោះ គឺប្អូនស្រីរបស់គាត់ឈ្មោះ រស់ សំបូរ បានស្លាប់ដោយសារតែអត់អាហារហូប ។ ចំណែកប្អូនប្រុសពៅរបស់គាត់ឈ្មោះ រស់ សំបូណា ដែលរស់នៅមណ្ឌលកុមារ បានលួចទៅលេងម្តាយរបស់គាត់ ។ ក្រោយមក អង្គការដឹងហើយធ្វើទារុណកម្មលើប្អូនគាត់ដោយវាយជាច្រើនរំពាត់ ។ សំណាង បានចូលមកមណ្ឌលកុមារ រួចសុំការអនុញ្ញាតពីប្រធានមណ្ឌលដើម្បីយកប្អូនប្រុសទៅនៅជាមួយនៅឯកងចល័តវិញ ។ សំណាង រស់នៅជាមួយប្អូនប្រុសពៅបានមួយរយៈ អង្គការបានផ្លាស់គាត់ទៅនៅកងក្សួរនៅត្រឡោកភ្នុង និងនៅដំណាក់ឈើក្រូម ស្រុកភ្នំក្រវ៉ាញ ដែលពេលនោះគាត់ត្រូវបែកពីប្អូនប្រុសម្តងទៀត ។

ចុងឆ្នាំ១៩៧៨ ពេលកងទ័ពវៀតណាមវាយនៅតាមបណ្តាខេត្តមួយចំនួន ខ្មែរក្រហមបានកៀរប្រជាជនជម្លៀសជាច្រើននាក់ទៅជាមួយ ។ សំណាង បានបន្ថែមថា យោធាខ្មែរក្រហមបានប្រមូលប្រជាជនប្រហែលជាហាសិបនាក់មកពីខេត្តស្វាយរៀងដែលម្នាក់ៗមានកាន់ក្រម៉ាពណ៌ខៀវ រួចហើយបណ្តើរយកទៅកាន់រណ្តៅមួយដែលមានប្រវែងប្រាំម៉ែត្រ ស្ថិតនៅឃុំតាឡូ ដើម្បីសម្លាប់ចោល ។ តំបន់នោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ វី ជាបញ្ជាកង ឈូប ដែលតែងតែយកប្រជាជនទៅសម្លាប់ជារៀងរាល់ថ្ងៃ ។

នៅក្នុងឆ្នាំ១៩៧៩ នៅពេលដែលវៀតណាមបានរំដោះ សំណាង បានវិលត្រឡប់មកកាន់ស្រុកកំណើតនៅភ្នំពេញវិញ ។ ប៉ុន្តែដោយសារតែឪពុកម្តាយបានស្លាប់អស់ សំណាង បានសម្រេចចិត្តរស់នៅភូមិពាលញ៉ែក សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ។ សំណាង បានចូលរៀនបន្ត ហើយក្រោយមកគាត់បានក្លាយជាគ្រូបង្រៀនរបាំនៅមន្ទីរឃោសនាការ វប្បធម៌ និងព័ត៌មាន តាមការចាត់តាំងរបស់ស្រុក ។ សព្វថ្ងៃសំណាង គឺជាអនុប្រធានសារមន្ទីរខេត្តពោធិ៍សាត់ ។ **ស៊ិន សុធីតា**

## ដំណឹងស្វែងរកប្អូន

នាងខ្ញុំឈ្មោះ ហង្ស ហួន និងប្តីឈ្មោះ សរ មឿន រស់នៅភូមិត្រពាំងសិរិត សង្កាត់គងនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ នាងខ្ញុំសូមប្រកាសរកប្អូនពីរនាក់ គឺ ៖ ◆ ប្អូនស្រី ហង្ស ហ៊ីម និងប្តីឈ្មោះ មុំ ភីន ។ អ្នកទាំងពីរមានកូនបួននាក់ ទី១) ស្រីញឹប, ទី២) សុភី, ទី៣) សុជាត និង ទី៤) អាចក់ ◆ ប្អូនប្រុស ហង្ស សំណាង ហៅ គ្រីម និងប្រពន្ធឈ្មោះ សយ យឿន ។ អ្នកទាំងពីរមានកូនពីរនាក់ ទី១) ណាក់ និង ទី២) ណូត ។

សូមបញ្ជាក់ថា គ្រួសារប្អូនៗទាំងពីរបែកគ្នាជាមួយនាងខ្ញុំនៅម៉ុំអួរបែកក្អមក្នុងឆ្នាំ១៩៧៥ ក្រោយពេលដែលខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ ។ មួយរយៈក្រោយមកនាងខ្ញុំពុំដំណឹងថា គ្រួសារប្អូនទាំងពីរត្រូវខ្មែរក្រហមជម្លៀសទៅខេត្តបាត់ដំបង ប៉ុន្តែមិនដឹងថាទៅនៅភូមិស្រុកអ្វីនោះទេ ហើយក៏បាត់ដំណឹងរហូតមកដល់ពេលនេះ ។

អាស្រ័យហេតុនេះ បើបងប្អូនណាបានដឹង និងស្គាល់ឈ្មោះដែលបានរៀបរាប់ខាងលើសូមទំនាក់ទំនងមកតាមរយៈអាសយដ្ឋានផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬតាមរយៈទូរស័ព្ទលេខៈ ០១៦ ៨៩៦ ៦៩២ ។

**សូមអរគុណ!**



# ការកេណ្ឌយុវជន និងមនោគមវិជ្ជា

អត្ថបទនេះ ស្វែងយល់អំពីប្រវត្តិនៃការកេណ្ឌ និងការចាត់តាំងយុវជនកម្ពុជាដើម្បីបម្រើកិច្ចការងារផ្សេងៗចាប់ពីឆ្នាំ១៩៤១ដល់ឆ្នាំ១៩៧៩ ដើម្បីកំណត់ប្រវត្តិតួនាទីសំខាន់ៗរបស់យុវជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រៅពីរឿងរ៉ាវផ្ទាល់របស់អ្នករស់រានមានជីវិត មិនមានសំណេរជាប្រវត្តិសាស្ត្រណាមួយមានលក្ខណៈជាប្រពន្ធ័ស្តីពីគោលនយោបាយយុវជន ឬការកេណ្ឌយុវជនក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ឬ សម័យ ប៉ុល ពត ទេ ។ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតនៅសម័យ ប៉ុល ពត បានសង្កត់ធ្ងន់ពីការផ្លាស់ប្តូរនយោបាយដែលយុវជនត្រូវបានបង្ខំឲ្យប្រព្រឹត្តកាលពីអតីតកាល ។ ផ្ទុយទៅវិញ អត្ថបទស្រាវជ្រាវនេះនិងពណ៌នាពីការកេណ្ឌយុវជនចាប់តាំងពីសម័យអណានិគមរហូតដល់របបក្រោយអាណានិគមដ៏រីកវរតាមរយៈការភ្ជាប់អង្គការចាត់តាំងសង្គមទៅនឹងមនោគមវិជ្ជាកសិកម្ម និងមនោគមវិជ្ជាទំនើបកម្មប្រតិកិរិយា ។ ក្នុងចន្លោះពីឆ្នាំ១៩៤១ ដល់ឆ្នាំ១៩៧៩ មេដឹកនាំកម្ពុជានិងអ្នកគ្រប់គ្រងរដ្ឋបានដាក់មនោគមវិជ្ជា និងរចនាសម្ព័ន្ធសង្គមដែលមានបំណងកេណ្ឌយុវជនក្នុងគោលដៅបម្រើនយោបាយ ។ ក្រោមរបបអណានិគមនិយមបារាំងវីជីនៅចន្លោះពីឆ្នាំ១៩៤០និង១៩៤៥ យុវជនត្រូវបានកេណ្ឌឲ្យធ្វើកងស្វ័យត្រាណដោយទទួលបានការគាំទ្រពីរដ្ឋ ។ វិធីសាស្ត្រនេះត្រូវបានប្រើរហូតដល់សម័យ លន់ នល់ ខណៈដែលវិធីសាស្ត្រកេណ្ឌយុវជននេះប្រែក្លាយទៅជាការកេណ្ឌយោធាដែលបង្កឲ្យមានអំពើប្រល័យពូជសាសន៍ក្នុងរបប ប៉ុល ពត ។

នៅក្នុងអត្ថបទនេះ យុវជនត្រូវបានយកមកសិក្សាជាអង្គភាពចាត់តាំងដែលបង្កើតឡើងដោយលោកខាងលិចដែលជាផ្នែកមួយនៃចលនាផ្លាស់ប្តូរក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលរងអាណានិគម ។ ក្នុងចំណោមចលនាផ្លាស់ប្តូរទាំងនោះ ការចូលរួមដោយស្ម័គ្រចិត្តក្នុងអង្គការចាត់តាំងយុវជន មិនផ្អែកលើសមាជិកភាពឡើយ ។ នៅប្រទេសកម្ពុជា ការចូលរួមនេះ បានបង្កើតមាគ៌ាថ្មីមួយសម្រាប់អំណាចអាណានិគម និងរបបក្រោយអាណានិគមក្នុងការចាត់តាំងក្រុមធំៗដែលក្រៅពីគ្រួសារ ក្រុមព្រះសង្ឃ ឬសហគមន៍ព្រះពុទ្ធសាសនា ហើយការចូលរួមនេះ គឺជាមធ្យោបាយមួយដែលរដ្ឋអាចកេណ្ឌយុវជនដើម្បីប្រឆាំងតបនឹងការគំរាមកំហែងក្នុង និងក្រៅប្រទេស ។

## យុវជន ជាផ្នែករបស់សង្គម

ជាដំបូង មុនយើងចាប់ផ្តើមវិភាគ យើងត្រូវពិនិត្យមើលពាក្យ “យុវជន” ថាជាទស្សនៈមួយ ។ និយមន័យនៃពាក្យ “យុវជន”

ក្នុងសម័យអាណានិគមនិយមបារាំង គឺមិនសូវផ្តោតលើអាយុរបស់បុគ្គលជាជាងតួនាទីនិងកាតព្វកិច្ចឡើយ ។ ការចាត់ទុកបែបនេះនៅតែរក្សាជានិច្ចក្នុងរបបនយោបាយក្រោយៗមកទៀត ។ ការផ្សារក្នុងការកេណ្ឌយុវជនរួមមានការរឹតចំណងយុវជនតាមរយៈទង្វើជាក់ស្តែងនិងមនោគមវិជ្ជានិងបណ្តុះគំនិតយុវជនពីគោលការណ៍នៃការបម្រើនិងការពារប្រទេស ។ និយមន័យពាក្យ "យុវជន" ថាជាផ្នែកមួយរបស់សង្គមបានផ្លាស់ប្តូរតាមសម័យកាល ។ ក្នុងសម័យអាណានិគម និងក្រោយអាណានិគមយុវជនត្រូវបានចាត់ថ្នាក់ថាជាមនុស្សមិនទាន់រៀបការនៅពេលដែលបុគ្គលនោះមិនស្ថិតក្រោមការទទួលខុសត្រូវរបស់ប្តីប្រពន្ធ ។ សម្រាប់រដ្ឋដែលស្ថិតក្រោមអាណានិគមបារាំង ការចាត់ថ្នាក់យុវជនផ្អែកលើអាយុចាប់ពី៧ឆ្នាំដល់២១ឆ្នាំ ។ ក្រោយមកពេលដែលរបប ប៉ុល ពត ព្យាយាមកេណ្ឌមនុស្សដែលមានវ័យចំណាស់ជាងយុវជនដែលយល់ថាមានកម្លាំងគឺជាការចាំបាច់ដើម្បីសម្រេចបានបដិវត្តន៍និងការពាររបបពីសត្រូវ ។ ពេលនោះ យុវជនត្រូវបានចាត់ថ្នាក់សាជាថ្មីដោយផ្អែកលើអាយុចាប់ពី១៨ឆ្នាំដល់៣០ឆ្នាំ ។

ភាពស្មុគស្មាញនៃការកំណត់និយមន័យពាក្យ "យុវជន" គឺទាក់ទងទៅនឹងទស្សនៈនៃកុមារភាព ។ ក្នុងសម័យ ប៉ុល ពត កុមារនិងយុវជនគឺជាវ័យដែលមានភាពប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ជាពេលវេលាមួយដែលបុគ្គលអាចកែកំហុសពីអតីត មិនដូចទៅនឹងមនុស្សជាន់ដើមដែលត្រូវពន្ធកដោយរបបចាស់រួចហើយ ។ ក្នុងទិដ្ឋភាពនេះ យុវជនតំណាងឲ្យសម័យកាលនយោបាយមួយ ។ ដើម្បីទទួលបានការគាំទ្រពីសំណាក់យុវជននិងដើម្បីបង្កើតសាមគ្គីភាព មេដឹកនាំនយោបាយ ជាទូទៅជំរុញយុវជនឲ្យគិតថាខ្លួនគឺជាផ្នែកមួយការផ្សារដ៏មានអត្ថន័យ ។

យុវជនភាគច្រើនក្នុងរបបអណានិគម របបសង្គមរាស្ត្រនិយម និងរបប លន់ នល់ គឺជាបុគ្គលដែលមកពីទីប្រជុំជនតូច និងធំនានាទូទាំងប្រទេស ។ ផ្ទុយទៅវិញ ខ្មែរក្រហមបានយកកូនកសិករធ្វើជាគោលដៅ ដែលតំណាងឲ្យវណ្ណៈកម្មករ ។ ក្រុមយុវជនទាំងអស់ រួមមាន សមាជិកនារី និងបុរស ។ ចាប់តាំងពីសម័យអាណានិគមរហូតដល់សម័យ លន់ នល់ មានសេចក្តីថ្លែងការណ៍ជាផ្លូវការជាច្រើនដែលធ្វើឡើងដោយថ្នាក់ដឹកនាំរដ្ឋ ជាញឹកញយបានគូសបញ្ជាក់ថា យុវជនគឺជាអត្តសញ្ញាណសង្គមដ៏សំខាន់និងមានប្រយោជន៍ដែលមិនផ្អែកលើឋានានុក្រមសង្គមយេនឌ័រ និងលក្ខណៈរបស់សង្គមទីក្រុងនិងជនបទទេ ។

## ការកេណ្ឌយុវជន និងមនោគមវិជ្ជា បំផ្លាញដ៏មានឥទ្ធិពល



ការប្រមូលផ្តុំប្រជាជនក្នុងចលនាឥស្សរៈ

ដូចលោក ណាស័រ អាប់ឌុល ការរីម (Nasir Abdul-Carime) កត់សម្គាល់ក្នុងការសិក្សាអត្តសញ្ញាណខ្មែររបស់គាត់ ការប្រឈមដ៏សំខាន់មួយក្នុងប្រទេសកម្ពុជានាអំឡុងរបបក្រោយអាណានិគម គឺការបង្កើតស្មារតីរួបរួមនៃប្រទេសមួយក្នុងបណ្តាប្រជាជនកម្ពុជាទូទៅដែលមិនមែនជាសមាជិកគ្រួសារ និងមានជាតិពន្ធុផ្សេងៗពីគ្នា ។ ការកេណ្ឌយុវជនចាប់ពីសម័យអាណានិគមរហូតដល់ឆ្នាំ១៩៧៩ គឺជាការឆ្លើយតបរបស់រដ្ឋចំពោះសេចក្តីចាំបាច់របស់ប្រវត្តិសាស្ត្រក្នុងការជំរុញឲ្យមានការប្តេជ្ញាខាងនយោបាយដ៏ធំមួយចំពោះរបបដែលប្រឈមមុខនឹងការគំរាមកំហែងដល់ជាតិខ្មែរ ។ ការកេណ្ឌយុវជនបែបនេះគឺដើម្បីពង្រឹងស្មារតីស្នេហាជាតិឬជាតិនិយមចំពោះទឹកដីកំណើត ។

ឆ្នាំ១៩៤១ ជាពេលដែលដែនដីអាណានិគមប្រឈមនឹងការត្រួតត្រារបស់ទាហានជប៉ុន និងគោលនយោបាយវាតទីនិយមរបស់ថៃ ។ បារាំងបានបង្កើតចលនាយុវជនកម្ពុជាដ៏ធំមួយដែលហៅថា “យុវ័ន” ដែលមានសម្តេចព្រះ នរោត្តម សីហនុ ជាប្រមុខ ។ យុវ័ន បានចូលរួមក្នុងសកម្មភាពសង្គមជាច្រើន ។ ក្រោយមក សម្តេចព្រះ នរោត្តម សីហនុ បានប្រើចលនានេះជាឧបករណ៍ដើម្បីក្តោបអំណាចរបស់ព្រះអង្គដោយបង្កើត “យុវជនសង្គមរាស្ត្រនិយមខ្មែរ” ក្នុងឆ្នាំ១៩៥៧ ដើម្បីគាំទ្រចលនានយោបាយធំថ្មីរបស់ព្រះអង្គគឺសង្គមរាស្ត្រនិយម ។ សង្គមរាស្ត្រនិយមមានបំណងបង្រួបបង្រួមខ្មែរទាំងអស់ក្រោមរូបភាពសហភាពជាតិតែមួយក្រោមការដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ ។ ក្នុងឆ្នាំ១៩៥៥ ជ័យជម្នះនៃការបោះឆ្នោតរបស់ចលនានោះបានដាក់អំណាចក្នុងកណ្តាប់ដៃរបស់ព្រះអង្គសម្រាប់អាណត្តិប្រាំឆ្នាំបន្ទាប់ ។

ការតស៊ូដោយអាវុធដែលបង្កដោយបក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងសម្តេចព្រះ នរោត្តម សីហនុ បានបង្កឲ្យមានការត្រួតត្រាដោយជនបះបោរលើទឹកដីកម្ពុជាស្ទើរតែ១ភាគ៥ ។ ក្នុងសម័យសង្គមរាស្ត្រនិយម ការចូលជាសមាជិករបស់យុវជនគឺធ្វើការដោយស្ម័គ្រចិត្ត ។ ប៉ុន្តែក្រោយមក ការចូលជាសមាជិកបានប្រែក្លាយជាការបង្ខំចាប់ពីចន្លោះឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៧០ ខណៈដែលសម្តេចព្រះ នរោត្តម សីហនុ ស្វះស្វែងរកការគាំទ្រពីយុវជនទាំងស្រុង ។ ក្នុងខែមីនា ឆ្នាំ១៩៧០ សម្តេចព្រះ នរោត្តម សីហនុ ត្រូវបានទម្លាក់ពីអំណាច ហើយ លន់ នល់ បានកាន់តំណែងជំនួស ។ មានការអំពាវនាវដល់យុវជនដើម្បីឲ្យចូលបម្រើយោធា ។ អាស្រ័យហេតុនេះ ការកេណ្ឌយុវជនកាន់តែធ្វើឡើងក្នុងទ្រង់ទ្រាយយោធាអំឡុងសម័យ លន់ នល់ ។ ក្នុងខែមេសា ឆ្នាំ១៩៧៥ លន់ នល់ បានចុះចេញពីអំណាចហើយបានធ្វើនិរទេសនៅពេលដែលកម្លាំងកុម្មុយនីស្តរបស់ ប៉ុល ពត បានត្រួតត្រាភ្នំពេញ ។ ខ្មែរក្រហមដែលគ្រប់គ្រងកម្ពុជារហូតដល់ខែមករា ឆ្នាំ១៩៧៩ បានខិតខំកម្ចាត់ចោលអង្គការចាត់តាំងយុវជនដែលមានស្រាប់ចំពេលដែលកាលនោះខ្មែរក្រហមបានកេណ្ឌយុវជនសាជាថ្មីដោយផ្អែកលើទស្សនកសិកម្មតាមការស្រមើស្រមៃ ប៉ុន្តែការកេណ្ឌយុវជនក្នុងរបប ប៉ុល ពតនោះគឺជាការបង្ខំ ។

ទោះបីជាការកេណ្ឌយុវជនត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត ឬដោយបង្ខំក្នុងចន្លោះឆ្នាំ១៩៤០-៧៩ ក្រុមយុវជនបានតំណាងឲ្យផ្នែកមួយនៃការធ្វើទំនើបកម្មសង្គម ជាពេលដំបូងដែលកម្ពុជាជារដ្ឋស៊ីវិល័យ ។ ទោះបីជាយ៉ាងនេះក៏ដោយ ទម្រង់ថ្មីនៃការចាត់តាំងយុវជននេះគឺមិនមានលក្ខណៈខុសគ្នាទាំងស្រុងពីការចាត់តាំងយុវជនពីអតីតកាលឡើយ ។ ជាការពិតណាស់ គោលការណ៍កសិកម្មដែលមានស្រាប់កាលពីមុន មានបំណងធ្វើសង្គមនីយកម្មយុវជន ។ គោលការណ៍កសិកម្មដែលមានស្រាប់នេះ រួមមាន ការរំពឹងទុកដែលយុវជនគួរតែចូលរួមក្នុងកម្លាំងផលិតកម្មដើម្បីរួមចំណែកដល់សង្គម ហើយថា ការគោរព និងការប្រព្រឹត្តរវាងយុវជន និងអ្នកកាន់អំណាចគួរតែត្រូវបានធ្វើឡើង ។ សម្រាប់យុវជន ជនដែលកាន់អំណាចគួរតែណែនាំយុវជនពីសីលធម៌ និងឧត្តមគតិ ។ រដ្ឋបានដើរតួនាទីជំនួសគ្រួសារដែលជាអ្នកអប់រំបណ្តុះបណ្តាលនោះតាមរយៈការផ្តល់ការបណ្តុះបណ្តាលដល់យុវជនក្នុងការផលិតស្បៀងអាហារដោយដើរតួនាទីជាអ្នកគ្រប់គ្រង និងដោយលើកស្ទួយទស្សនៈ ដូចជា ការពឹងផ្អែកខ្លួនឯង ការលះបង់ និងការគោរពចំពោះមេដឹកនាំ ។ ចាប់តាំងពីសម័យអាណានិគមរហូតដល់សម័យសង្គមរាស្ត្រនិយម (ក្នុងចន្លោះពីឆ្នាំ១៩៤១-១៩៧០) មេដឹកនាំដែលយល់ថាប្រទេសរបស់ខ្លួនរងការគំរាមកំហែងទាំងក្នុង និងក្រៅប្រទេស បានសង្កត់ធ្ងន់លើមនោគមវិជ្ជាកសិកម្មបម្រើរដ្ឋ ។ ការកេណ្ឌយុវជន បានប្រើរូបភាពជាការចូលរួមចំពោះកាតព្វកិច្ចជាប្រជាពលរដ្ឋក្នុងការងារកសិកម្ម ។ នៅចុងឆ្នាំ១៩៧២ អស្ថិរភាពនយោបាយបានធ្វើឲ្យខ្មែរក្រហមអាចគ្រប់គ្រងទឹកដីកម្ពុជាជាងពាក់កណ្តាល ។ ប្រការនេះ បានធ្វើឲ្យ លន់ នល់ ផ្តោតចំណាប់អារម្មណ៍លើមនោគមវិជ្ជាយោធាកសិកម្មដែលយុវជនត្រូវបានរំពឹងថានឹងធ្វើការងារកសិកម្មនិងធ្វើជាទាហានក្នុងពេលដំណាលគ្នាក្នុងបុព្វហេតុសង្រ្គាម ។ បន្ទាប់ពីការផ្តួលរំលំរបប លន់ នល់ របប ប៉ុល ពត បានកេណ្ឌយុវជនតាមរយៈមនោគមវិជ្ជាបដិវត្តន៍កសិកម្ម ដែលមានបំណងកសាងសង្គមជនបទតាមការស្រមើស្រមៃ ។ សរុបមក មនោគមវិជ្ជាកសិកម្មដ៏មានឥទ្ធិពលបានបង្កើតជំនឿនយោបាយរបស់មេដឹកនាំនិងកម្មាភិបាលប្តូរផ្តាច់ ។

មនោគមវិជ្ជាកសិកម្មបានផ្សារភ្ជាប់ទៅនឹងបញ្ហាជាតិ

និយមនិងទំនើបកម្មគ្រប់របបនយោបាយ ។ ដោយពិចារណាលើមនោគមវិជ្ជារបស់លោក សើត រិច, លោក ចាហ្វ៊ើយ ហើរ បានប្រើពាក្យ "ទំនើបកម្មប្រតិកិរិយា" ដើម្បីពិពណ៌នាទស្សនៈនៃមនោគមវិជ្ជាប្រតិកិរិយាដែលជាទស្សនៈពីអតីត ហើយជំទាស់ទៅនឹងលទ្ធិប្រជាធិបតេយ្យសេរីក្នុងការធ្វើទំនើបកម្មបច្ចេកវិទ្យា ។ លោក ចាហ្វ៊ើយ ហើរ មិនលើកឡើងថា បច្ចេកវិទ្យាកើតឡើងដោយមូលធននិយមឡើយ ប៉ុន្តែបច្ចេកវិទ្យាមានទំនាក់ទំនងជាមួយស្មារតីនិងឆន្ទៈ ។ តាមរយៈស្នាដៃរបស់លោក ចាហ្វ៊ើយ ហើរ អត្ថបទនេះប្រើពាក្យ "ទំនើបកម្មប្រតិកិរិយា" ដើម្បីសំដៅទៅរកការប៉ុនប៉ងរបស់របបនីមួយៗក្នុងការកេណ្ឌយុវជនតាមរយៈអង្គការចាត់តាំងសង្គម ដោយរួមបញ្ចូលទាំងប្រពៃណីក្នុងតំបន់ ព្រះពុទ្ធសាសនា ឧត្តមគតិនិយកម្មអតីតភាព និងការបង្កើតមនុស្សថ្មី ពីព្រោះប្រការនេះ តំណាងឲ្យជំហានមួយដែលឆ្ពោះទៅមុខក្រៅពីគ្រួសារនិងសាសនា ។ ស្របពេលនេះដែរ ប្រការនេះជំទាស់ទៅនឹងការធ្វើឧត្តមគតិនីយកម្មអតីតភាព ។ ការធ្វើអន្តរាគមន៍របស់រដ្ឋចំពោះការកេណ្ឌយុវជនគឺខុសពីការធ្វើទំនើបកម្មប្រតិកិរិយា ។

## សម័យអាណានិគម ៖ ភាពប្រទាក់ក្រឡារបស់ជាតិ និងមនោគមវិជ្ជាកសិកម្មបម្រើរដ្ឋ

ក្នុងឆ្នាំ១៩៤១ ស្ថានភាពទាំងមូលនៅឥណ្ឌូចិនកាន់តែដុនដាប ដោយសារនិគមជនបារាំងរងការបរាជ័យក្រោមកណ្តាប់ដៃនៃការឈ្លានពានរបស់ជប៉ុន ។ មួយផ្នែកគឺថា មានទាហានជប៉ុនចំនួន៣៥.០០០នាក់ បានឈ្លានពាន ហើយឈរជើងនៅឥណ្ឌូចិនជាពិសេសនៅតាមទីក្រុងធំៗ ។ មួយផ្នែកទៀតគឺថាជនជាតិបារាំងចង់រក្សាអធិបតេយ្យភាពជាតិ ។ ដោយសារអទិភាពរបស់ជប៉ុន គឺដើម្បីបន្តការឈ្លានពាន ជប៉ុនក៏បានអនុញ្ញាតឲ្យនិគមជនបារាំងបន្តការគ្រប់គ្រងតំបន់នោះ ។ ដោយសារតែតុល្យភាពអំណាចមិនស្ថិតស្ថេរក្នុងតំបន់ អគ្គទេសាភិបាលឥណ្ឌូចិន លោក ហ្សង់ ឌឺកូដ បានគាំទ្រការពង្រីកវិសាលភាពយ៉ាងរហ័សនៃការកេណ្ឌយុវជន ។ រដ្ឋត្រូវបានប្រកាសអាសន្នក្រោមការត្រួតត្រារបស់ជប៉ុន ។ ដោយសារជនឈ្លានពានជប៉ុនកំពុងតែកេណ្ឌយុវជន ដូច្នេះ បារាំងបានកេណ្ឌយុវជនឲ្យបានច្រើនតាមតែអាចធ្វើទៅបានដែរ ។ គោលបំណងនៃការពង្រីកកងយុវជនត្រូវធ្វើឡើងដោយទន្ទឹងដែលឆ្លុះបញ្ចាំងពីសង្គម តាមរូបភាពសាមញ្ញចំពេលដែលកាលនោះ គម្រោងការនៃការពង្រីកកងយុវជន គឺពង្រីកវិសាលភាពគ្រប់គ្រងយុវជន និងជំរុញស្មារតីស្នេហាជាតិចំពោះទឹកដីកំណើត ។

ការគំរាមកំហែងដែលមានសក្តានុពលខ្លាំងក្លាជាងការឈ្លានពានរបស់ជប៉ុនមកលើប្រទេសកម្ពុជា គឺមហិច្ឆតាវាតទីនិយមរបស់ថៃមកលើប្រទេសជិតខាងរបស់ខ្លួន ។ នាចុងឆ្នាំ១៩៤០ សង្គ្រាមបានផ្ទុះឡើងរវាងបារាំងនិងថៃ ។ ដោយកេងចំណេញផលប្រយោជន៍នៃភាពកំសោយខាងយោធារបស់បារាំង ប្រទេសថៃ បានវាយប្រហារបារាំងដោយគោលបំណងចង់ក្តោបក្តាប់ទឹកដីកម្ពុជា និងលាវ សារជាថ្មី ។ បារាំងបានទទួលជ័យជម្នះផ្លូវទឹក ប៉ុន្តែបរាជ័យផ្លូវគោក ដោយយល់ព្រមប្រគល់ខេត្តភាគខាងលិចភាគច្រើនទៅឲ្យប្រទេសថៃដោយមិនរាប់បញ្ចូលប្រាសាទអង្គរវត្ត ។

មានការលើកឡើងចំពោះការគំរាមកំហែងដោយគួរឲ្យកត់សម្គាល់ក្នុងឯកសារផ្លូវការបានកើតឡើងដំណាលគ្នាទៅនឹងការគំរាមកំហែងដ៏ជាក់លាក់ទាំងនោះ ។ ជារឿយៗ និគមជនបារាំងបានហៅជនជាតិកម្ពុជាថាជាប្រជាជនខ្ជិលច្រអូស ទន់ខ្សោយ និងគ្មានប្រសិទ្ធភាព ហើយការយល់ឃើញបែបនេះ ត្រូវអគ្គទេសាភិបាលឥណ្ឌូចិន លោក ហ្សង់ ឌឺកូដ ទទួលយក ។ នៅពេលដែលលោក ហ្សង់ ឌឺកូដ បានចារសំណេរទៅកាន់លោករ៉េស៊ីដង់ស៊ុបពែរីយើនៅកម្ពុជាទាក់ទងនឹងគោលនយោបាយយុវជន គាត់បានដាស់តឿនថា "កាតព្វកិច្ចចម្បងគឺត្រូវបន្តខិតខំធ្វើឲ្យប្រទេសរស់ឡើងវិញ ឬត្រូវទប់ស្កាត់ប្រទេសពីការធ្លាក់ចូលក្នុងភាពចលាចលនិងទុទិដ្ឋិនិយម ឬត្រូវរក្សាទំនុកចិត្តចំពោះខ្លួន" ។ ក្នុងការឆ្លើយតបផ្សេងនោះ លោករ៉េស៊ីដង់ស៊ុបពើរីយើកម្ពុជាបានពិពណ៌នាថា មានភាពចាំបាច់ក្នុងការសង្គ្រោះនិងធ្វើឲ្យប្រទេសរស់ឡើងវិញដែលកំពុងប្រឈមនឹងការវាតទីនិយមរបស់ប្រទេសថៃ ។

## មនោគមវិជ្ជា ៖ កសិកម្មបម្រើរដ្ឋ និងទំនើបកម្មប្រតិកិរិយា

ក្នុងផ្នែកនេះ ដំបូងយើងក្រឡេកមើលទិដ្ឋភាពនៃមនោគមវិជ្ជាកសិកម្មបម្រើរដ្ឋដែលបានដាក់បញ្ចូលការកេណ្ឌយុវជនអំឡុងសម័យអាណានិគម ។ ចំពោះមនោគមវិជ្ជាកសិកម្មបម្រើរដ្ឋ សកម្មភាពកសិកម្មតាមជនបទដែលរបបអាណានិគមយល់ថាមានសារ

សំខាន់ចំពោះយុវជនក្នុងការធ្វើការជាមួយធម្មជាតិដែលនឹងបង្កើតនូវលក្ខណៈសម្បត្តិបុគ្គល សុខភាព សកម្មភាពដោយដៃនិងស្មារតីក្រុម ។ ការធ្វើសង្គមនីយកម្មយុវជនគឺផ្អែកលើការចង្អុលបង្ហាញតាមរយៈគោលការណ៍កសិកម្មក្នុងរបបនយោបាយផ្សេងៗដែលមានក្នុងការសិក្សានេះ ។

ការសិក្សារបស់លោក ដេនី អេតវើដ និង អាហ្គាត លេតច័រហ្គូសា ស្តីពីប្រទេសកម្ពុជា និងឥណ្ឌូចិនបារាំងក្នុងទសវត្សរ៍២០និង៣០បង្ហាញថា ការកេណ្ឌយុវជន និងការសង្កត់ធ្ងន់លើផ្នែកសង្គមយុវជនបានកើតមុនសម័យវីជីទៅទៀត ។ បើតាមលោក ដេនី អេតវើដ កីឡា និងការឈ្លបយកការណ៍គឺពេញនិយមណាស់នៅកម្ពុជាកាលពីទសវត្សរ៍៣០ដោយសារទទួលបានការគាំទ្រពីរាជវង្សានុវង្ស និងប្រទេសអាណាព្យាបាល ។ មេដឹកនាំយុវជនក្នុងចលនាពីរដែលប្រកាន់ជំហរដូចគ្នា បានយល់ឃើញថា កីឡាគឺជាមធ្យោបាយមួយឆ្ពោះទៅរកទស្សនៈគាំទ្ររបស់ជាតិកម្ពុជាដោយពង្រឹងស្មារតី និងរាងកាយ ។ ការឈ្លបយកការណ៍បានរឹតចំណងយុវជនទៅនឹងប្រទេសជាតិរបស់ខ្លួន និងសង្គមកសិកម្ម ។

បើប្រៀបធៀបទៅនឹងដើមកំណើតនៃមនោគមវិជ្ជានេះ ការកេណ្ឌយុវជនកម្ពុជាអំឡុងសង្គ្រាមលោកលើកទី២ មានទ្រង់ទ្រាយធំ ហើយកាន់តែពុះកញ្ជ្រោលខណៈដែលប្រទេសកម្ពុជាប្រឈមនឹងការគំរាមកំហែងពីប្រទេសជប៉ុន និងប្រទេសថៃ ។ ខណៈដែលក្រុមយុវជនក្នុងទសវត្សរ៍៣០ និងក្នុងរបបវីជី ចង់បង្រៀនជនជាតិកម្ពុជាឲ្យចេះស្រលាញ់ជាតិ និងប្រទេសរបស់ខ្លួន បារាំងចាប់ផ្តើមបង្កើតមហាចលនាយុវជនក្នុងឆ្នាំ១៩៤១ ហើយបានស្នើសុំឲ្យមានវត្តមានរបស់សម្តេចព្រះ នរោត្តម សីហនុ ជាប្រមុខរដ្ឋនៃចលនាដែលស្គាល់ថាជា យុវ័ន ។

សុន្ទរកថាមួយចំនួនរបស់សម្តេចព្រះ នរោត្តម សីហនុ ក្នុងសម័យវីជី បានសង្កត់ធ្ងន់ពីគោលការណ៍នៃការគោរព និងការស្តាប់បង្គាប់មេដឹកនាំ ។ ការលះបង់ចំពោះមេដឹកនាំបានប្រែក្លាយជាទំនាក់ទំនងរវាងប្រជាជន និងសម្តេចព្រះ នរោត្តម សីហនុ ដែលត្រូវបានលើកឡើងថា ព្រះអង្គកើតចេញពីរាជវង្សានុវង្សកាន់ព្រះពុទ្ធសាសនាថេរវាទ ហើយការលះបង់នេះត្រូវបានប្រើប្រាស់សម្រាប់លើកស្ទួយស្មារតីជាតិនិយមក្នុងចំណោមយុវជន ។ ឧទាហរណ៍ អំឡុងពេលថ្លែងសុន្ទរកថាជាសាធារណៈក្នុងឆ្នាំ១៩៤២ សម្តេចព្រះ នរោត្តម សីហនុ បានមានព្រះបន្ទូលថា យុវជនត្រូវតែស្តាប់បង្គាប់ គោរពវិន័យ និងត្រូវមានកាតព្វកិច្ចដូចគ្នា ។ ពាក្យស្លោកថា "បម្រើ" ត្រូវបានលើកឡើងចំពោះក្រុមយុវជនដែលមានសមាជិករបស់ខ្លួនចំនួន២.០០០នាក់ ។ ការបម្រើគ្រួសារគឺជាមូលដ្ឋានគ្រឹះរបស់សង្គមនិងប្រទេសជាតិ ។ យុវជនចាំបាច់ត្រូវធ្វើសមាហរណកម្មក្នុងក្រុមដែលយុវជនទាំងនោះអាចធ្វើការរួមគ្នា គិតជាមួយគ្នា និងចូលរួមលេងល្បែងកម្សាន្តរួមគ្នា ។ យុវជនអាចប្រឈមនឹងការងារស្តារប្រទេសជាតិដ៏អស្ចារ្យដែលនេះគឺជាវិន័យ ។

ទង្វើទាំងនោះបានបម្រើជនអាណាព្យាបាលបារាំង និងប្រទេសបារាំង ។ ក្រៅពីនេះ ប្រជាជនកម្ពុជានឹងរួបរួមគ្នាក្នុងដំណើរកសាងប្រទេស ។ វិធានការផ្សេងទៀតទាក់ទងនឹងយុវជនបានកាត់បន្ថយគម្លាតខាងប្រពៃណីរវាងព្រះមហាក្សត្រ និងប្រជារាស្ត្រ ។ ឧទាហរណ៍ មុនឆ្នាំ១៩៤១ ពិធីចម្រើនព្រះជន្មព្រះមហាក្សត្រត្រូវបានប្រារព្ធឡើងក្នុងពិធីដ៏តូចមួយក្នុងរាជវាំង ។ ក្នុងឆ្នាំ១៩៤២ និងក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីរៀបចំព្រះរាជពិធី របបវីជីបានរៀបចំពិធីចម្រើនព្រះជន្មរបស់ សម្តេចព្រះ នរោត្តម សីហនុ ក្នុងពិធីសាធារណៈដ៏ធំមួយក្រៅរាជវាំង អំឡុងពេលនោះដែរ សម្តេចព្រះ នរោត្តម សីហនុ បានដើរត្រួតពលដោយកងយុវ័នចំនួន១៥.០០០នាក់ ដែលបង្ហាញពីការយល់ចិត្តគ្នារវាងមេដឹកនាំនិងយុវជន ។ ការបញ្ជ្រាបការយល់ដឹងគឺជារឿងមួយដែលសម្តេចព្រះ នរោត្តម សីហនុ ត្រូវធ្វើតាមរយៈដំណើរទស្សនកិច្ចរបស់ព្រះអង្គទៅសួរសុខទុក្ខប្រជារាស្ត្រពេញផ្ទៃប្រទេស ។

លោក រ៉ូប៊ើត លីវីន និង ម៉េរី វាយ បានបញ្ជាក់នៅក្នុងសៀវភៅរបស់គាត់ថា ចំណុចស្នូលនៃសង្គមកសិកម្ម គឺយុវជនខ្លួនឯងយល់ថាខ្លួនមានតម្លៃខាងសេដ្ឋកិច្ច និងគួរតែផ្តល់ការចូលរួមខាងសេដ្ឋកិច្ចដល់គ្រួសារ និងសង្គម ។ ការប្រព្រឹត្តតបពីជំនាន់មួយទៅជំនាន់មួយគឺជាគោលគន្លឹះនៃជីវិតប្រចាំថ្ងៃក្នុងប្រទេសកម្ពុជា ។ បច្ចុប្បន្ន រដ្ឋបានលើកស្ទួយទស្សនៈនេះប្រឆាំងទៅនឹងប្រវត្តិនៃស្ថានភាពសង្គ្រាម ។ ឧទាហរណ៍ ឥណ្ឌូចិន មានតម្រូវការដំណាំល្ហុង

ប្រេងក្នុងឆ្នាំ១៩៤២ អាស្រ័យហេតុនេះ មេបញ្ជាការដែលជាប្រមុខនៃយុវជនឥណ្ឌូចិន និងជាអ្នកផ្តួចផ្តើមគំនិតបង្កើតកីឡា បានខិតខំកេណ្ឌយុវជនឥណ្ឌូចិនឲ្យចូលរួមបោះជំរំវិស្សមកាលដែលយុវជនអាចដាំដុះដំណាំល្ហុងប្រេងបាន ។ រដូវប្រាំងឆ្នាំ១៩៤២ មេដឹកនាំជាច្រើនបានដាក់ផែនការឲ្យក្រុមយុវជនបម្រើជាកម្លាំងជំនួយបុព្វហេតុសង្គ្រាម ។ ដោយសារតែស្ថានភាពកាន់តែដុនដាប អគ្គទេសាភិបាលឥណ្ឌូចិនបាននិយាយថា៖

*យុវជន ត្រូវតែបានចង្អុលបង្ហាញបន្ថែមទៀតចំពោះការសម្រេចបាននូវប្រយោជន៍ និងជាពិសេសចំពោះការងារកសិកម្ម តាមរយៈការបង្កើតទីផ្សារ និងចម្ការដំណាំ ព្រមទាំងកន្លែងបង្កាត់ពូជបសុសត្វដែលអាចបម្រើយ៉ាងប្រសើរដល់សមូហភាព ។*

គម្រោងយុវជនទាំងនោះ បានបំពេញតួនាទីឪពុកម្តាយដោយផ្អែកលើកសិកម្មដែលជាអ្នកចិញ្ចឹមបីបាច់និងជាអ្នកគ្រប់គ្រង ដោយសារតែវិធីចិញ្ចឹមជីវិតតាមប្រពៃណីត្រូវបានបន្តពីឪពុកម្តាយដល់កូននៅពេលដែលអ្នកទាំងអស់នោះបានធ្វើការរួមគ្នា ។ សម្រាប់ក្រុមយុវជន រដ្ឋបានជួយទំនុកបម្រុង សកម្មភាពខាងក្រៅចំពោះយុវជនទីក្រុងដូចជា ការដើរកម្សាន្ត ការហែលទឹក និងកីឡាជាក្រុម ។ ចំណុចស្នូលនៃមនោគមវិជ្ជាកសិកម្មគឺជាជំនឿរបស់មន្ត្រីនៃរបបផ្តាច់ការវិឝីដែលទាក់ទងផ្ទាល់ជាមួយធម្មជាតិដែលជួយធ្វើឲ្យយុវជនអាចពឹងផ្អែកខ្លួនឯង មានសេចក្តីក្លាហាន និងសេចក្តីថ្លៃថ្នូរ ។ កម្មាភិបាលរបស់អង្គការចាត់តាំងដែលគាំទ្រដោយរដ្ឋបានផ្តល់ការបណ្តុះបណ្តាលស្របពេលនឹងផ្តល់សកម្មភាពកម្សាន្តដល់យុវជន ។ ដូចគ្នានេះដែរ អ្នកកាន់អំណាចនៅសម័យអាណានិគមបានជំរុញយ៉ាងខ្លាំង ឲ្យមានការបោះជំរំកម្សាន្តដល់យុវជន ។ សារព័ត៌មាន *Sports Jeunesse d'Indochine* បានកត់ត្រាសកម្មភាពបោះជំរំយុវជនចំនួន២៨.០០០នាក់ ក្នុងប្រទេសកម្ពុជាក្នុងអំឡុងរដូវក្តៅនៅឆ្នាំ១៩៤២ ។ សកម្មភាពបោះជំរំ គឺជាមធ្យោបាយមួយដើម្បីបង្រៀនយុវជនអំពីអតីតកាលរបស់ខ្លួន ។

ដើមទសវត្សរ៍១៨៧០ អ្នកវិទ្យាសាស្ត្រជនជាតិបារាំង បានកសាងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាក្នុងមជ្ឈិមសម័យឡើងវិញ ។ អ្នកវិទ្យាសាស្ត្រទាំងនោះបានបង្ហាញពីសម័យកាលនៃភាពអស្ចារ្យរបស់ជាតិ និងការទទួលស្គាល់វប្បធម៌ដ៏រុងរឿងក្នុងសតវត្សរ៍ទី១២ និងទី១៣ ដែលមានមេដឹកនាំដ៏កៀវក្លា សិល្បៈអស្ចារ្យ និងមហិច្ឆតារបស់ចក្រពត្តិហើយក្រោយមកភាពអស្ចារ្យនោះបានធ្លាក់ចុះវិញ ។ ជនជាតិបារាំងបាននិយាយពោលលើកហេតុផលថា ការធ្លាក់ចុះនោះ គឺដោយសារតែអសមត្ថភាពរបស់ប្រជាជនកម្ពុជាក្នុងការយកគំរូតាមសម័យអង្គរ ។ មួយក្នុងចំណោមគោលបំណងរបស់ផែនការយុវជនសម័យសង្គ្រាមលោកលើកទី២ គឺដើម្បីរឹតចំណងមនុស្សបច្ចុប្បន្នទៅនឹងអតីតកាលរបស់ខ្លួនដែលជាមធ្យោបាយនៃការជំរុញលើកទឹកចិត្តក្រោមការចង្អុលបង្ហាញរបស់បារាំង ។ ខ្លឹមសារនយោបាយរបស់បារាំង រួមមានការធ្វើឲ្យរស់ឡើងវិញនូវការចងចាំ និងការទទួលស្គាល់អតីតកាលដ៏អស្ចារ្យក្នុងមជ្ឈិមសម័យរបស់ប្រទេស ។ បទភ្លេងជាតិថ្មីរបស់កម្ពុជាដែលបង្កើតឡើងក្នុងឆ្នាំ១៩៤១ ក្រោមការចាត់ចែងរបស់បារាំងបានលើកឡើងថា ដំណោះស្រាយចំពោះការប្រឈមទាំងនោះគឺត្រូវដាស់ស្មារតីខ្មែរអង្គរឲ្យងើបឡើងវិញ ដោយសារអង្គរ គឺជាវត្ថុតាងនៃភាពរុងរឿងពីអតីតកាលរបស់ពូជសាសន៍ខ្មែរ៖

*ប្រាសាទសិលា កំបាំងកណ្តាលព្រៃ គួរឲ្យស្រមៃនឹកដល់យសស័ក្តិ មហានគរ ជាតិខ្មែរដូចថ្ម គង់វង្សនៅល្អរឹងប៉ឹងជំហរ យើងសង្ឃឹមពរ ភ័ព្វព្រេងសំណាងរបស់កម្ពុជា ។*

ក្នុងខែសីហា ឆ្នាំ១៩៤២ ជំរំយុវជនដែលមានមនុស្សប្រហែលជិត៥០០នាក់ ដែលគ្រប់គ្រងដោយសាលាបារាំងចុងបូព៌ាបានប្រមូលផ្តុំគ្នាដើម្បីជួយស្តារផ្នែកខ្លះរបស់ប្រាសាទអង្គរ ។ គោលបំណង គឺមិនត្រឹមតែដើម្បីបង្កើតស្មារតីក្រុម និងរឹតចំណងសមាជិកក្រុមតាមរយៈសកម្មភាពជាក់លាក់នោះទេ ថែមទាំងដើម្បីបង្រៀនយុវជនឲ្យបម្រើប្រទេសរបស់ខ្លួន និងផ្សារភ្ជាប់ខ្លួនទៅនឹងអតីតកាលដ៏រុងរឿង ។ ការឃោសនានៅក្នុងសម័យអាណានិគមបានថ្លែងថា យុវជនកម្ពុជាមានការស្រលាញ់យ៉ាងជ្រាលជ្រៅចំពោះ សម្តេច សីហនុ ដែលត្រូវបានមើលឃើញថាជាគំរូនៃជាតិនិយមដោយផ្អែកលើកម្ពុជាដ៏ពិតប្រាកដមួយ ។ ជាក់ស្តែងជាងនេះទៅទៀត ពាក្យទំនើបកម្មប្រតិកិរិយាបានឆ្លុះបញ្ចាំងថា សម្តេចព្រះ នរោត្តម សីហនុ គឺជាអ្នកស្នងអាណាចក្រ

អង្គរដែលត្រូវយកគំរូតាមព្រមទាំងជានិមិត្តរូបរបស់កម្ពុជាសម័យបច្ចុប្បន្ននិងពេលអនាគត ដែលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាជាប្រទេសទំនើប និងស៊ីវិល័យ ។ ភាពទំនើបស្តែងឲ្យឃើញតាមរយៈការអភិវឌ្ឍដូចជា ប្រព័ន្ធកសិកម្ម ។ ឧទាហរណ៍ ក្រុមយុវជនកម្ពុជា ដែលហៅថា យុវ័ន រួមមានកងចល័តដែលក្នុងចំណោមយុវជនទាំងនោះមានភាតព្វកិច្ចចែករំលែកបច្ចេកវិទ្យាកសិកម្មថ្មីៗដើម្បីបង្កើនផលិតកម្ម ។ យុវជនគឺជាកត្តាគន្លឹះក្នុងដំណើរការធ្វើទំនើបកម្មដែលដឹកនាំដោយរដ្ឋ ។ បើតាមការឃោសនាជាផ្លូវការមួយមិនត្រឹមតែជនអាណានិគមទេថែមទាំងពលរដ្ឋកម្ពុជាលែងទទួលស្គាល់ការដែលថា មានភាពខុសគ្នារវាងកម្ពុជាក្នុងការសញ្ជឹងគិតជាមួយនឹងកម្ពុជាក្នុងសកម្មភាព ប្រការនេះ ជំទាស់ទៅនឹងប្រពៃណីនិងអ្នកដែលចង់បានភាពប្លែកនិងថ្មី ។

លោក ហ្សាក លីបាស ដែលជាប្រមុខយុវជននៅឥណ្ឌូចិន ដែលបានកាន់តួនាទីរបស់ខ្លួនរហូតដល់ខែធ្នូ ឆ្នាំ១៩៤១ បានកត់សម្គាល់ថា "នៅតំបន់មេត្រូប៉ូល ដូចនៅគ្រប់អាណាចក្រទាំងអស់ដែរ មេដឹកនាំដែលមានឋានៈខ្ពស់ប្តេជ្ញាស្វែងរកនូវមធ្យោបាយសមស្របក្នុងការបណ្តុះបណ្តាលយុវជន និងកសាងមនុស្សថ្មីពីព្រោះឥទ្ធិពលរបស់យុវជនអាចត្រូវបានពិចារណាប្រសិនបើការបណ្តុះបណ្តាលនោះប្រព្រឹត្តទៅយ៉ាងល្អ" ដែលនេះគឺជាការធ្វើយុវកម្មសង្គម ។ ទស្សនៈបែបនេះបានឆ្លុះបញ្ចាំងពីការនិយាយលើកឡើងមួយនៅមេត្រូប៉ូល ដែលមន្ត្រីបារាំងបានដាក់ការស្តីបន្ទោសដល់របបមុនចំពោះការបរាជ័យក្នុងឆ្នាំ១៩៤០ ហើយជាពិសេស បានដាក់ការស្តីបន្ទោសដល់គ្រូបណ្តុះបណ្តាលដោយចោទប្រកាន់ថាបានបំបាក់ភាពក្លាហាននិងភាពស្នេហាជាតិរបស់យុវជនតាមរយៈការបង្រៀន ។ ឆន្ទៈរបស់យុវជន ត្រូវបានបំបាក់ជាមួយរាងកាយផងដែរដោយចាំបាច់ត្រូវធ្វើការអប់រំឡើងវិញ ។ ដូច្នេះហើយ ទស្សនៈនោះ គឺដើម្បីបង្កើតមនុស្សថ្មីដែលមានរាងកាយមាំមួនព្រមទាំងមានការប្តេជ្ញាចំពោះរបបថ្មី ។ យុវជនត្រូវបានរំពឹងគិតថានឹងក្លាយជាអ្នកនាំសាររបស់គម្រោងយុវជនរបស់របបផ្តាច់ការវីជី ប៉ុន្តែរដ្ឋប្រហាររបស់ប្រទេសជប៉ុន នៅខែសីហា ឆ្នាំ១៩៤៥ បានបញ្ចប់ការប៉ងប្រាថ្នានេះ ។

## របបសង្គមរាស្ត្រនិយមៈ មនោគមវិជ្ជាកសិកម្ម

## បម្រើរដ្ឋ និងមហានគរ

បន្ទាប់ពីរដ្ឋប្រហាររបស់ប្រទេសជប៉ុននៅខែសីហា ឆ្នាំ១៩៤៥ ដែលផ្តួលរំលំការគ្រប់គ្រងរបស់បារាំង និន្នាការរបស់សម្តេចព្រះ នរោត្តម សីហនុ ក្នុងការដោះស្រាយជាជាងការប្រឆាំងនឹងបារាំង បានបង្កឲ្យមានការវាយប្រហាររវាងអ្នកដែលចង់បានឯករាជ្យភ្លាមៗពីអំណាចអាណានិគម និងអ្នកដែលចង់គិតគូរដិតដល់ពីរបបនោះ ។ ក្រៅពីនេះ ការគំរាមកំហែងពិតប្រាកដមួយចំពោះអំណាចរបស់សម្តេចសីហនុ កើតចេញពីអ្នកដែលគាំទ្រការដាក់បញ្ហាឲ្យស្ថិតក្រោមការពិចារណារបស់សភា ជាជាងការអនុញ្ញាតិឲ្យស្តេចធ្វើការសម្រេចចិត្តលើជោគវាសនារបស់ប្រទេសជាតិ ។

អំឡុងពេលដែល សឺង ង៉ុកថាញ់ ជានាយករដ្ឋមន្ត្រីកាលនោះ ជនជាតិអង់គ្លេស និងទ័ពបារាំង បានវាយចូលប្រទេសកម្ពុជាក្នុងខែកញ្ញា ឆ្នាំ១៩៤៥ ។ ដោយមានការវិលត្រឡប់របស់ជនជាតិបារាំង សម្តេចព្រះ នរោត្តម សីហនុ បានរក្សាអំណាចរបស់ព្រះអង្គ ហើយ សឺង ង៉ុកថាញ់ បានធ្វើនិរទេសទៅបារាំង ។ បារាំងនិងសម្តេចព្រះ នរោត្តម សីហនុ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ម៉ូដូស វីវីនឌី នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៤៦ ដោយផ្តល់ឯករាជ្យឲ្យកម្ពុជា ។ កិច្ចព្រមព្រៀងនេះធានាឲ្យមានរដ្ឋធម្មនុញ្ញមួយ និងអនុញ្ញាតិឲ្យមានការបង្កើតគណបក្សនយោបាយជាលើកដំបូង ។ ប្រទេសបារាំងបន្តគ្រប់គ្រងគោលនយោបាយបរទេសរបស់កម្ពុជា ទោះបីជារក្សាទំនាក់ទំនងក្នុងការប្រឹក្សាយោបល់ជាមួយរដ្ឋាភិបាលរបស់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត ក៏ដោយ ។ ក្នុងខែកញ្ញា ឆ្នាំ១៩៤៦ បន្ទាប់ពីគណបក្សនយោបាយថ្មីត្រូវបានបង្កើតឡើងការបោះឆ្នោតសម្រាប់ក្រុមប្រឹក្សាសភាត្រូវបានប្រារព្ធឡើងដើម្បីរៀបចំទីប្រឹក្សារបស់ព្រះមហាក្សត្រយោងតាមរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ។ គណបក្សប្រជាធិបតេយ្យបានឈ្នះ៥០អាសនៈក្នុងចំណោម៦៧អាសនៈ ។ សេចក្តីព្រៀងរដ្ឋធម្មនុញ្ញក្នុងឆ្នាំ១៩៤៦ បានកាត់បន្ថយអំណាចរបស់សម្តេចព្រះ នរោត្តម សីហនុ រីឯរដ្ឋធម្មនុញ្ញឆ្នាំ១៩៦៧ បានផ្តល់អំណាចដល់សភាជាតិ និងគណបក្សប្រជាធិបតេយ្យ ។ ស្ថានភាពនេះបានបង្កើតរបបនយោបាយក្រឡាប់ចាក់មួយអស់រយៈពេលជាច្រើនឆ្នាំដែលប្រឆាំងនឹងប្រទេសបារាំងនិងសម្តេចព្រះ នរោត្តម សីហនុ ។



សម្តេច នរោត្តម សីហនុ និងកងយុវ័ននៅក្នុងសម័យសង្គមរាស្ត្រនិយម

ការគំរាមកំហែងដទៃទៀតសម្រាប់សម្តេចព្រះ នរោត្តម សីហនុ គឺការវិលត្រឡប់របស់ សឺង ង៉ុកថាញ់ មកប្រទេសកម្ពុជាក្នុងឆ្នាំ១៩៥១ ដែលបានបង្កើតចលនាទ័ពព្រៃប្រឆាំងនឹងសម្តេចព្រះនរោត្តម សីហនុ និងបារាំង ។ ឆ្នាំ១៩៥២ សិស្សជាច្រើនបានធ្វើបាតុកម្មប្រឆាំងនឹងរាជវង្សានុវង្ស និងជំទាស់នឹងចំណាត់ការរបស់សម្តេចព្រះ នរោត្តម សីហនុ លើបញ្ហាទាមទារឯករាជ្យពីបារាំង ។ ក្នុងខែមករាឆ្នាំដដែលនោះ សឺង ង៉ុកថាញ់ បានបង្កើតកាសែត ខ្មែរក្រោក ដែលបានថ្កោលទោសកម្ពុជាដែលខ្វះឯករាជ្យនៅក្នុងរង្វង់សហភាពបារាំង ខណៈដែលលោកបានបញ្ចេះភ្លើងក្រុមប្រឆាំង ។ ខែកុម្ភៈ ឆ្នាំ១៩៥២ ភ្នំពេញ បានជួបប្រទះមហាបាតុកម្មមួយដែលដឹកនាំដោយសិស្សសាលាដែលទាមទារឯករាជ្យកម្ពុជា ។ ការកេណ្ឌនិស្សិត ដែលកើតឡើងដោយឯកឯងនេះបានគំរាមកំហែងដល់សម្តេចព្រះ នរោត្តម សីហនុ និងប្រទេសជាតិរបស់ព្រះអង្គ ។ ការកេណ្ឌយុវជនរបស់រដ្ឋត្រូវបានបង្កើតឡើងដើម្បីបញ្ចៀសយុវជនពីការប្រដែងនឹងក្រុមនយោបាយ ដោយសារជាមធ្យោបាយមួយក្នុងការរារាំងកម្លាំងបដិវត្តន៍ដែលប្រឈមអំណាចរបស់ព្រះអង្គ ។ សម្តេចព្រះ នរោត្តម សីហនុ បានធ្វើដំណើរបេសកកម្មទៅកាន់ប្រទេសបារាំង និងប្រទេសដទៃក្នុងការស្វែងរកឯករាជ្យភាពឲ្យប្រទេសរបស់ព្រះអង្គ ។ ក្នុងឆ្នាំ១៩៥៣ សម្តេចព្រះ នរោត្តម សីហនុ បានសម្រេចគោលដៅរបស់ព្រះអង្គហើយ កម្ពុជាបានក្លាយជាប្រទេសឯករាជ្យ ។ ដោយមានឯករាជ្យបន្ទាប់ពីជាងពាក់កណ្តាលសតវត្សរ៍នៃការគ្រប់គ្រងរបស់បារាំង កម្ពុជាត្រូវប្រឈមនឹងការបង្កើតស្ថាប័ននយោបាយដែលនឹងមានមុខងារ និងប្រសិទ្ធភាព ។ ចុងឆ្នាំ១៩៦០ សម្តេចព្រះ នរោត្តម សីហនុ ដឹកនាំប្រទេសដែលកំពុងប្រឈមបញ្ហាក្នុងស្រុកជាច្រើន ដូចជា អំពើពុករលួយ ការបង្កិតបង្ខំរបស់យោធា សេដ្ឋកិច្ចដែលកំពុងងើបឡើង ហើយនិងការខុសប្លែកគ្នានៃលទ្ធិស្តាំនិយម និងឆ្វេងនិយម ។ ការប្រឈមនៃស្ថានភាពភូមិសាស្ត្រនយោបាយរបស់កម្ពុជា រួមមានទំនាក់ទំនងយ៉ាងស្មុគស្មាញជាមួយប្រទេសវៀតណាម ប្រទេសចិន និងសហរដ្ឋអាមេរិក ។ ដោយប៉ុនប៉ងធ្វើការប្រឆាំងតបដើម្បីឲ្យមានតុល្យភាពជាមួយថៃ និងវៀតណាមខាងត្បូង សម្តេចព្រះ នរោត្តម សីហនុ បង្កើតចំណងយ៉ាងជិតស្និទ្ធជាមួយប្រទេសចិន និងប្រទេសវៀតណាមខាងជើង ។ ក្នុងឆ្នាំ១៩៦៥ ព្រះអង្គបានផ្តាច់ទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក ហើយបានខំពាំនាំកិច្ចប្រជុំ

អន្តរជាតិដើម្បីធ្វើឲ្យអាស៊ីអាគ្នេយ៍ប្រែជាតំបន់អព្យាក្រឹត្យខាងនយោបាយ ហើយបណ្តេញទាហានអាមេរិកចេញ ។ ព្រះអង្គបានធ្វើការងារនេះ ដោយចងសម្ព័ន្ធមិត្តជាមួយជនជាតិវៀតណាមជាសម្ងាត់ក្នុងឆ្នាំ១៩៦៦ ដែលជាមធ្យោបាយក្នុងការធានាឲ្យមានឯករាជ្យកម្ពុជាក្រោមការគាំទ្ររបស់វៀតណាមខាងជើងដោយសារសម្តេចព្រះ នរោត្តម សីហនុ យល់ថា ជនកុម្មុយនីស្តវៀតណាមគឺជាអ្នកដែលនឹងឈ្នះសង្គ្រាម ។ ដោយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយកម្ពុជា កងទ័ពវៀតណាមខាងជើងត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិការលើទឹកដីកម្ពុជា ហើយបានអនុញ្ញាតឲ្យទទួលសព្វាវុធតាមរយៈកំពង់ផែព្រះសីហនុ ។ ចំណាត់ការដ៏ចម្រូងចម្រាសនេះបង្កឲ្យមានការទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីអំណាចប៉ុន្មានឆ្នាំបន្ទាប់ ។ ការគំរាមកំហែងនោះ ត្រូវបានស្តែងឲ្យឃើញតាមរយៈការធ្លាក់ចុះពូជសាសន៍ខ្មែរ ។ យោងតាមសម្តេចព្រះ នរោត្តម សីហនុ អរិយធម៌ខ្មែរឈានដល់ដំណាក់កាលរុងរឿងអំឡុងសម័យអង្គរ មុនពេលឈានដល់សម័យកាលធ្លាក់ចុះជាបន្តបន្ទាប់ដោយក្រោយមកមានសម័យកាលងើបឡើងវិញ នៅពេលដែលឯករាជ្យរបស់កម្ពុជានាំទៅរកការវិវឌ្ឍរបស់ប្រទេសក្រោមរបបសង្គមរាស្ត្រនិយម ដែលជាចលនានយោបាយដែលបង្កើតដោយ សម្តេចព្រះ នរោត្តម សីហនុ ។ សម្តេចព្រះ នរោត្តម សីហនុ បានយល់ថា កម្ពុជាគឺជាប្រជាជាតិដែលជិតស្លាប់ ហើយក្រោយមកងើបឡើងវិញដោយផ្អែកលើរបបដែលកាន់អំណាច ។ ការគិតចំណុចទាំងពីរនេះ (ប្រទេសកម្ពុជាដែលជិតស្លាប់ និងប្រទេសកម្ពុជាដែលងើបឡើងវិញ) បានបង្ហាញទស្សនៈស្តីពីកម្ពុជារបស់ជនអណានិគមបារាំង ។

## មនោគមវិជ្ជា ៖ កសិកម្មបម្រើរដ្ឋ សង្គមនិយមព្រះពុទ្ធសាសនា និងទំនើបកម្មប្រតិកិរិយា

មនោគមវិជ្ជាកសិកម្មបម្រើរដ្ឋរបស់សម្តេចព្រះ នរោត្តម សីហនុ គឺអាស្រ័យលើមនោគមវិជ្ជាដែលត្រូវបានបង្កើតអំឡុងសម័យអណានិគម ។ ទាំងរបបបារាំង និងរបប សីហនុ បានយល់ឃើញថាធម្មជាតិ ជាកន្លែងសម្រាប់កសាងយុវជន ។ នៅក្នុងឆ្នាំ១៩៦០ សម្តេចព្រះ នរោត្តម សីហនុ បានថ្លែងអំណរគុណចំពោះទង្វើ ដូចជា «ភាពស្មោះត្រង់ ការបើកចំហគំនិត ការវិនិច្ឆ័យច្បាស់លាស់ ការយោគយល់គ្នាទៅវិញទៅមក និងការអត់ឱន ដែលទង្វើទាំងនោះ កើតឡើងដោយសកម្មភាពកីឡានៅខាងក្រៅ» ។ ក្រៅពីនេះរបបទាំងពីរមានបំណងឲ្យអង្គការចាត់តាំងគិតប្រយោជន៍ធម្មជាតិ ។ ឧទាហរណ៍ ក្រោមរបប សីហនុ «យុវជនកម្ពុជាបានចូលរួមការងារដោយដៃដែលជាការងារសាងសង់ផ្លូវ ជីកប្រឡាយ សាងសង់ផ្ទះសម្រាប់អ្នកស្រុក» ។

យុវជនត្រូវបានជំរុញលើកទឹកចិត្តយ៉ាងខ្លាំងដើម្បីចូលរួមការធ្វើអណានិគមកិច្ចទឹកដីថ្មី ។ បណ្តាញសារព័ត៌មានផ្លូវការបានយល់ថាសមាជិករបស់យុវជនខ្មែរសង្គមរាស្ត្រនិយមជានិគមវ័យក្មេង ។ សិក្ខាសាលាដែលប្រព្រឹត្តិឡើងនៅខែមករា ឆ្នាំ១៩៦៩ ដោយបានរៀបចំដោយប្រមុខយុវជនសង្គមនិយមខ្មែរ ក្រសួងកសិកម្មនិងមន្ត្រីជាច្រើន បានគូសបញ្ជាក់តួនាទីរបស់យុវជនសង្គមនិយមខ្មែរក្នុងការធ្វើទំនើបកម្មកសិកម្មដូចជា ការជ្រើសរើសពូជ ការជ្រើសរើសដី និងការប្រើប្រាស់ទឹកដែលជាមធ្យោបាយបង្កើនផលិតកម្មស្រូវ ។ ដោយសារជាផ្នែកនៃផែនការធ្វើទំនើបកម្មរបស់សម្តេចព្រះ នរោត្តម សីហនុ ការកេណ្ឌយុវជន គឺជាការឆ្លើយតបទៅនឹងតម្រូវការកសិកម្មក្នុងការជំរុញកំណើនសេដ្ឋកិច្ចនិងបង្កើតការផ្លាស់ប្តូរសង្គមសេដ្ឋកិច្ច ។ ជាងនេះទៅទៀត សកម្មភាពកសិកម្មត្រូវបានលើកទឹកចិត្តជាការឆ្លើយតបទៅនឹងភាពគ្មានការងារធ្វើនៅទីក្រុង ។ ប៉ុន្តែសម្តេចព្រះ នរោត្តម សីហនុ បានលើកទឹកចិត្តការអភិវឌ្ឍផ្នែកអប់រំដោយគ្មានការធ្វើផែនការរកការងារឲ្យធ្វើ ។ ដូច្នេះហើយ ប្រព័ន្ធអប់រំបានបង្កើតថ្នាក់អប់រំជាច្រើនសម្រាប់ជនដែលអសមត្ថភាព ។ សិស្សដែលបញ្ចប់ការសិក្សាសង្ឃឹមថានឹងស្វែងរកការងារតាមផ្នែកឯកជន និងផ្នែករដ្ឋ ដោយរំពឹងថាការងារទាំងនោះ នឹងអាចធ្វើឲ្យមានជីវិតរស់នៅទីក្រុងបែបលោកខាងលិចដោយសារជនទាំងនោះមិនចង់ត្រឡប់ទៅធ្វើការនៅស្រែវិញនោះទេ ។

ទស្សនវិស័យរបស់ សម្តេចព្រះ នរោត្តម សីហនុ ចំពោះកម្ពុជាគឺជាប្រទេសអព្យាក្រឹត្យដែលរួចពីការបង្កមហន្តរាយនៃសង្គ្រាមវៀតណាម ។ សម្តេចព្រះ នរោត្តម សីហនុ មានបំណងចាប់ផ្តើមគម្រោងការធ្វើទំនើបកម្មដើម្បីទទួលការទទួលស្គាល់ពីសហគមន៍អន្តរជាតិ ដូច្នេះហើយព្រះអង្គសង្ឃឹមថា នឹងបង្កើត

កម្ពុជាមួយដែលនឹងមិនប្រជែងអំណាចរបស់ព្រះអង្គ ។ យុវជនសង្គមនិយមខ្មែរត្រូវបានបង្កើតក្នុងឆ្នាំ១៩៥៧ ដើម្បីដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចឲ្យបានអនាគតដ៏ត្រចះត្រចង់នេះ ។ សម្តេចព្រះ នរោត្តម សីហនុ មានព្រះរាជបន្ទូលថា ឧត្តមគតិដ៏សំខាន់របស់ជាតិដែលការចាត់តាំងយុវជននេះត្រូវការលើកស្ទួយ និងរក្សា រួមមាន រាជវង្សានុវង្ស អព្យាក្រឹតភាពរបស់ប្រទេសដែលជាមធ្យោបាយសម្រាប់ការពារឯករាជ្យជាតិ សាសនា ស្ថាប័នប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេស និងកិច្ចខិតខំប្រឹងប្រែងធ្វើទំនើបកម្ម ។ ព្រះអង្គបានបន្ថែមថា ៖ យុវជនសង្គមនិយមខ្មែរត្រូវតែឆ្ពោះទៅរកការវិវឌ្ឍ ការយោគយល់គ្នា ការជ្រួលជ្រាបពីវប្បធម៌ បច្ចេកវិទ្យា និងវិទ្យាសាស្ត្ររបស់ខ្លួន ដោយមិនព្រមប្រគល់ប្រពៃណី និងទ្រព្យរបស់ពូជសាសន៍របស់ខ្លួន និងស្ថាប័នជាតិណាមួយទៅឲ្យពូជសាសន៍ដទៃ ប្រសិនបើខ្លួនមិនចង់ឈប់ធ្វើជាខ្មែរ ប៉ុន្តែបើមិនដូច្នេះទេ ប្រទេសយើងនឹងមិនអាចតាមទាន់ប្រទេសជិតខាង និងរងការជ្រួតជ្រាបពីប្រទេសជិតខាង ។

ក្នុងឆ្នាំ១៩៦៤ ថ្ងៃរំឭកឯករាជ្យត្រូវបានគ្រោងឡើង ប៉ុន្តែសម្តេចព្រះ នរោត្តម សីហនុបដិសេធមិនឲ្យយុវជនឈានមុខបរទេសចូលរួមនោះទេ ដោយសារអ្នកទាំងនោះ គឺជាអង្គការចាត់តាំងនយោបាយបរទេសជាជាងអង្គការចាត់តាំងនយោបាយជាតិ ។ ព្រះអង្គបានអះអាងថា ក្រុមឈានមុខទាំងនោះបានធ្វើឲ្យមានការបែកបាក់ក្នុងចំណោមយុវជនតាមរយៈការបង្វែរយុវជនចេញពីការចូលរួមចលនាយុវជនខ្មែរសង្គមរាស្ត្រនិយមដែលបានផ្តល់ការអប់រំស្រដៀងគ្នាដល់ក្រុមឈានមុខទាំងនោះ ។ ដូច្នេះហើយ ក្រុមឈានមុខនោះបានសម្រេចចិត្តបំបែកចលនារបស់ខ្លួនហើយចូលរួមជាមួយចលនាយុវជនសង្គមរាស្ត្រនិយមខ្មែរវិញ ដោយបង្ហាញពីការគោរពរបស់ខ្លួននិងជួយកសាងជាតិនិយមរបស់ សម្តេចព្រះ នរោត្តម សីហនុ ។ ជាតិនិយមដែលមានការស្រុះស្រួលគ្នាត្រូវបានបង្កើតឡើងជាថ្មីម្តងទៀត ពេលដែលយុវជនចំនួន៧០.០០០នាក់ បានប្រារព្ធថ្ងៃរំឭកខួបឯករាជ្យជាតិកម្ពុជាក្នុងឆ្នាំ១៩៦៨ ។ គោលរឿងសំខាន់នៃព្រឹត្តិការណ៍នោះ គឺស្តីពី «ជាតិខ្មែរ នឹងមិនស្លាប់នោះទេ» ដែលបានសង្កត់ធ្ងន់លើប្រវត្តិសាស្ត្ររបស់កម្ពុជា ដែលប្រមូលផ្តុំមនុស្សការពារអំណាចរបស់ សម្តេចព្រះ នរោត្តម សីហនុ ដែលបានរក្សាឯករាជ្យរបស់ប្រទេសនេះ ។ សម្តេចព្រះ នរោត្តម សីហនុ បានពង្រឹងការគោរពចំពោះមេដឹកនាំក្នុងឆ្នាំ១៩៦៧ ពេលដែលព្រះអង្គប្រកាន់ភ្ជាប់ចលនាយុវជនសង្គមរាស្ត្រនិយមខ្មែរ ។

ដោយបញ្ចូលបញ្ហានយោបាយជាមួយនឹងការវិវឌ្ឍខាងបច្ចេកវិទ្យា ឧទាហរណ៍ ដូចជាការ សម្លឹងមើលអាណាចក្រអង្គរជាគំរូដ៏ឧត្តម មនោគមវិជ្ជាទំនើបកម្មប្រតិកិរិយាផ្សេងជាបន្តបន្ទាប់ត្រូវ សម្តេចព្រះ នរោត្តម សីហនុ លើកឡើងក្នុងសុន្ទរកថារបស់ព្រះអង្គ ។ ក្នុងការផ្សព្វផ្សាយជាខេមរភាសាដែលប្រើប្រាស់វិទ្យុទំនាក់ទំនងបែបថ្មី សម្តេចព្រះ នរោត្តម សីហនុ បានបង្កើតម៉ោងផ្សាយស្តីពីវប្បធម៌ដែលព្រះអង្គកែទម្រង់ថ្មីនូវតម្លៃដែលមានស្រាប់ដូចជាព្រះពុទ្ធសាសនា ។ ឧទាហរណ៍ការតភ្ជាប់មនោគមវិជ្ជារបស់រដ្ឋស្តីពីសង្គមនិយមព្រះពុទ្ធសាសនាទៅនឹងគុណប្រយោជន៍របស់ព្រះបាទជ័យវរ្ម័នទី៧ ដែលកាន់ព្រះពុទ្ធសាសនាមហាយាន (ឆ្នាំ១១៨១-១២២០) គឺជាគំរូមួយនៃអំពើល្អនិងការអភិវឌ្ឍជាតិ ។ ក្នុងសុន្ទរកថាមួយដែល ថ្លែងទៅកាន់យុវជនសម្តេច សីហនុ ថ្លែងថា «ព្រះបាទជ័យវរ្ម័នទី៧ បានបង្កើតមន្ទីរពេទ្យប្រហែលជា ២០០កន្លែង ខណៈដែលសម័យសង្គមរាស្ត្រនិយមបានបង្កើតជិតដល់៦០០កន្លែង» ។ កិច្ចខិតខំប្រឹងប្រែងទាំងស្រុងបានលើកស្ទួយគម្រោងការធ្វើទំនើបកម្ម (ការអភិវឌ្ឍផ្នែកកសិកម្មក្រោមការដឹកនាំរបស់រដ្ឋ) ហើយការវិលត្រឡប់ទៅរកអតីតកាលរបស់ប្រទេសដែលជាដំណើរឆ្ពោះទៅរកការអភិវឌ្ឍ សេដ្ឋកិច្ច និងសង្គមសម្រាប់ប្រទេសកម្ពុជា ។

មនោគមវិជ្ជារដ្ឋរបស់សម្តេចព្រះ នរោត្តម សីហនុ គឺជាទម្រង់នៃសង្គមនិយមបែបព្រះពុទ្ធសាសនា ដែលមានលក្ខណៈជាតិមិនមែនបរទេសក្នុងលក្ខណៈដែលមនោគមវិជ្ជានោះបានបូកបញ្ចូលក្តីមេត្តារបស់ព្រះពុទ្ធសាសនា និងទិដ្ឋភាពចែករំលែករបស់សង្គមរាស្ត្រនិយម ។ ដូចដែលការឃោសនាបានលើកឡើងថា «អ្នកខ្លាំងត្រូវតែជួយអ្នកខ្សោយ ហើយអ្នកមានជីវភាពធូរធារត្រូវតែជួយលើកកម្ពស់ជីវភាពអ្នកខ្វះខាតខ្សោយឲ្យទទួលបាននូវកម្រិតជីវភាពមួយដ៏សមស្រប» ។ ដោយផ្អែកលើសីលធម៌ជួយគ្នាទៅវិញទៅមក សង្គមនិយមព្រះពុទ្ធសាសនាបង្កើតស្មារតី

ការតភាពក្នុងចំណោមយុវជនតាមរយៈទង្វើប្រតិបត្តិ និងទង្វើមនោគមវិជ្ជា ។ ដូច្នេះហើយយុវជនត្រូវបានចាត់តាំងឲ្យធ្វើការងារសង្គម ជាពិសេសការងារកសិកម្មតាមជនបទ ដែលជាមធ្យោបាយកែប្រែជោគវាសនារបស់ប្រជាពលរដ្ឋនិងជាមធ្យោបាយដើម្បីរួមចំណែកដល់ការអភិវឌ្ឍរបស់ប្រទេសជាតិ ។ ដូចលោក យឹម ឌិត ដែលជាប្រធានចលនាយុវជនសង្គមរាស្ត្រនិយមខ្មែរបានសង្កេតឃើញថា «យុវជនរបស់យើងតម្រូវឲ្យជួយក្នុងផលិតកម្មកសិកម្មដោយផ្ទាល់និងដោយសកម្មតាមរយៈមធ្យោបាយនៃក្រុមជំនួយ» ។ ឧទាហរណ៍ យុវជនបានចូលរួមការជីកអណ្ដូងទឹកដែលជាផ្នែកនៃគោលនយោបាយជាតិថ្មីដែលបានដាក់ចេញក្នុងខែកក្កដា ឆ្នាំ១៩៥៨ ដើម្បីផ្គត់ផ្គង់ទឹកបន្ថែមតាមរយៈការកសាងអណ្ដូង អាងស្តុកទឹក ព្រែកជីក និងទំនប់ទឹក ។

ដូចទៅនឹងមនោគមវិជ្ជាកសិកម្មរបស់ប្រទេសកូរ៉េអំឡុងសម័យអាណានិគមដែរ មនោគមវិជ្ជាកសិកម្មរបស់សម្តេចព្រះនរោត្តម សីហនុ បានផ្តល់ជម្រើសរវាងកុម្មុយនីស្តនិងមូលធននិយមដោយអំពាវនាវឲ្យមានសហគមន៍មួយដែលមានភាពម្ចាស់ការលើខ្លួនឯងដែលផ្អែកលើភូមិកសិកម្ម និងចូលរួមក្នុងវប្បធម៌តំបន់ (ដូចជាព្រះពុទ្ធសាសនា និងប្រាសាទអង្គរដែលជាតំបន់ស្តារជាតិកម្ពុជា) ដែលនឹងធ្វើឲ្យយុវជនមានការលះបង់ចំពោះជម្រើសនេះ ។ ការនិយាយសំដៅរកព្រះពុទ្ធសាសនាគឺមិនសំខាន់នោះទេ ដោយសារកម្ពុជា គឺជាប្រទេសកាន់ព្រះពុទ្ធសាសនា ។ រដ្ឋធម្មនុញ្ញបានចាត់ទុកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។ ដូច្នេះហើយ ដោយផ្អែកទៅលើគោលការណ៍ដែលមានស្រាប់សម្តេចនរោត្តម សីហនុ បានខិតខំបង្កើតទំនាក់ទំនងរវាងទស្សនៈនយោបាយ និងលទ្ធិព្រះពុទ្ធសាសនា ។ ដោយសារ សម្តេចព្រះ នរោត្តម សីហនុ ជាអ្នកអប់រំខាងនយោបាយ ព្រះអង្គអាចទាក់ទងជាមួយអ្នកស្រែដែលមានជីវិតផ្អែកលើការសុំសីល ។

សម្តេចព្រះ នរោត្តម សីហនុ បានកសាងអំណាចរបស់ព្រះអង្គដោយផ្អែកលើវប្បធម៌ដែលមានស្រាប់ ដូចជាសារសំខាន់នៃការនិយាយទាក់ទងនឹងពាក្យពេចន៍ជាលាយលក្ខណ៍អក្សរក្នុងវប្បធម៌កម្ពុជា ។ កាលគ្រានោះ ទស្សនាវដ្តីរបស់កម្ពុជាបង្ហាញថា សម្តេចព្រះ នរោត្តម សីហនុ បានទៅសួរសុខទុក្ខក្រុមយុវជនផ្សេងៗជាច្រើន និង ជំរំយុវជន ហើយបានបង្ហាញថា សម្តេចព្រះនរោត្តម សីហនុ បានថ្លែងសុន្ទរកថាជាច្រើនស្តីពីយុវជនដែលជាក្រុមពិសេស ។ ដូចព្រះសង្ឃព្រះពុទ្ធសាសនា ឬបុគ្គលដ៏ឧត្តម សម្តេចព្រះ នរោត្តម សីហនុ បានធ្វើអត្ថាធិប្បាយនិងពន្យល់បកស្រាយព្រឹត្តិការណ៍សម្រាប់ប្រជាពលរដ្ឋ ។

ទោះបីជាយ៉ាងនេះក៏ដោយ នយោបាយបែបនោះមិនបានរារាំងផ្នែកមួយនៃការបង្កើតកម្ពុជាដែលកើតចេញពីការទាញការគាំទ្រសម្រាប់សម្តេចព្រះ នរោត្តម សីហនុ ដែលនៅទីបញ្ចប់នាំទៅរកវិបត្តិនយោបាយដែលបណ្តាលឲ្យមានការទម្លាក់ព្រះអង្គចេញពីអំណាច ។

***(នៅមានត)***

**អាន វ៉ាហ្វីន**


កងសិល្បៈខ្មែរក្រហម

# ព្រះរាជពិធីបុណ្យព្រះបរមសព ព្រះករុណា ព្រះបាទសម្តេចព្រះ











# ះ នរោត្តម សីហនុ ពីថ្ងៃទី១ ដល់ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣











# ពិធីរំឭកវិញ្ញាណក្ខន្ធដល់អ្នកសារព័ត៌មានដែលបានបាត់



ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន (រូបឆ្វេង) និង ឆាំង សុង (លើរទេះ) អតីតរដ្ឋមន្ត្រីក្រសួងព័ត៌មានពីឆ្នាំ១៩៧៤-១៩៧៥ នៅវត្តពោធិ៍ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ



ពីឆ្វេងទៅស្តាំ ៖ ធីមផេច, ម៉ៃ ម៉ូរ៉ូ, ម៉ាទីន ស្ទួត ហុក, ឆាំង សុង, ជន



ពិធីសូត្រមន្តរបស់ព្រះសង្ឃវត្តពោធិ៍នៅទីតាំងដែលអ្នកសារព័ត៌មានត្រូវបានសម្លាប់







អ្នកភូមិដែលបានឃើញហេតុការណ៍សម្លាប់អ្នកសារព័ត៌មានក្នុងឆ្នាំ១៩៧០

ស្តូបរំឭកវិញ្ញាណក្ខន្ធដល់អ្នកសារព័ត៌មានដែលបានស្លាប់នៅវត្ត

# ន់បង់ជីវិតក្នុងសង្គ្រាមនៅកម្ពុជាពីឆ្នាំ១៩៧០ដល់១៩៧៥



ណគស់, ឃឹត ហូសហុល, ម៉ែន សាម៉ន, រ៉ូឡង់ ណឺវី និង អៀន រ៉ាយត៍



អ្នកសារព័ត៌មានដែលធ្លាប់រាយការណ៍ពីសង្គ្រាមនៅកម្ពុជា




ពោធិ៍ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ កាលពីខែឧសភា ឆ្នាំ១៩៧០



ធីម ភេច

# អៀង ធីរិទ្ធ ៖ អតីតកាលនៅតែអន្ទោល



***មិនចាំអ្វីទាំងអស់*** ៖ *អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច (សុខាភិបាល) នៃរបបកម្ពុជាប្រជាធិបតេយ្យ អៀង ធីរិទ្ធ អង្គុយប្រកបដោយទឹកមុខយ៉ាងមាំនៅក្នុងបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រង់ចាំស្តាប់ការពិភាក្សាអំពីសម្បទាខាងបញ្ញាស្មារតីក្នុងការជំនុំជម្រះក្នុងសវនាការរបស់ខ្លួននៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ ។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២ អង្គជំនុំជម្រះសម្រេចដោះលែង អៀង ធីរិទ្ធ ដោយសារមានជំងឺវង្វេងវង្វាន់ធ្ងន់ធ្ងរ ហើយមិនអាចចូលរួមក្នុងដំណើរការកាត់ទោសបាន ។ រូបថតៈ ម៉ាក ភីទ័រ (ប្រភពៈ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) ។*

# តុលាការផ្តល់ក្តីករុណាចំពោះជនដែលប្រឆាំងក្តីមេត្តា

## អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់មិនអាចចូលរួមកិច្ចដំណើរការស្វែងរកយុត្តិធម៌បាន

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានជូនដំណឹងថា ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងករណី០០២មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមកិច្ចដំណើរការតុលាការបានទេ ដោយសារតែជនជាប់ចោទរូបនេះមានជំងឺវង្វេងវង្វាន់ស្មារតីក្នុងកម្រិតមួយដ៏ធ្ងន់ធ្ងរ ។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២ នេះ ប្រធានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រេចថា អៀង ធីរិទ្ធ ត្រូវដោះលែងជាមួយលក្ខខណ្ឌបណ្តោះអាសន្នមួយចំនួន ដូចជា ១) ជនជាប់ចោទត្រូវជូនដំណឹងដល់អង្គជំនុំជម្រះអំពីអាសយដ្ឋានដែលខ្លួនត្រូវស្នាក់នៅ ហើយមិនត្រូវផ្លាស់ប្តូរទីលំនៅ ដោយមិនមានការអនុញ្ញាតពីអង្គជំនុំជម្រះឡើយ ២) ជនជាប់ចោទត្រូវប្រគល់លិខិតឆ្លងដែននិងឯកសារធ្វើដំណើរពាក់ព័ន្ធដទៃទៀត ហើយមិនត្រូវចេញក្រៅព្រំប្រទល់ដែនដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ និង៣) ជនជាប់ចោទត្រូវគោរពតាមដីកាកោះដែលចេញដោយតុលាការ ។ ទោះបីជាមានការរំពឹងទុកបែបនេះជាយូរមកហើយយ៉ាងណាក៏ដោយ ដំណឹងអំពីការមិនមានសម្បទាគ្រប់គ្រាន់របស់ជនជាប់ចោទ និងការដោះលែងបែបនេះ នៅតែជាតថភាពមួយដែលជនរងគ្រោះនៃរបបខ្មែរក្រហមពិបាកនឹងទទួលយក ។

នេះគឺជាការពិត នៅពេលដែលតួនាទីពិសេសរបស់ អៀង ធីរិទ្ធ នៅក្នុងចលនាខ្មែរក្រហមត្រូវបានលើកមកនិយាយ ។ អៀង ធីរិទ្ធ ត្រូវបានលើកសរសើរជារឿយៗនៅក្នុងសារព័ត៌មានបរទេសថាជា“ស្ត្រីទីមួយ” ។ ការឲ្យឈ្មោះជា “ស្ត្រីទីមួយ” បែបនេះគឺឋានៈមួយមិនត្រឹមត្រូវទាល់តែសោះ ហើយធ្វើឲ្យមានការយល់ខុស ។ អៀង ធីរិទ្ធ មិនមែនជាបុគ្គលមួយរូបដែលបានចូលរួមពាក់ព័ន្ធក្នុងរបបខ្មែរក្រហមដោយសារតែឋានៈរបស់ខ្លួនជាប្រពន្ធរបស់ អៀង សារី និងជាប្អូនថ្លៃរបស់ ប៉ុល ពត តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង អៀង ធីរិទ្ធ គឺជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាដ៏មានឥទ្ធិពលមួយរូប ដែលមានអំណាចនៅទូទាំងប្រទេសទៀតផង ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងតួនាទីបែបនេះ អៀង ធីរិទ្ធ បានបដិសេធផ្តល់ការព្យាបាលសុខភាពជាមូលដ្ឋានដល់ប្រជាជនកម្ពុជាគ្រប់រូប ក្នុងអំឡុងពេលដែលខ្លួនកំពុងមានអំណាចនៅក្នុងរបបខ្មែរក្រហម ។ ហេតុដូច្នេះ សម្រាប់ជនរងគ្រោះការដែល អៀង ធីរិទ្ធ មានលទ្ធភាពទទួលបានការថែទាំសុខភាពលំដាប់អន្តរជាតិ និងទទួលបានការព្យាបាលពីវេជ្ជបណ្ឌិតជំនាញជាច្រើនរូបបែបនេះ គឺជាការផ្ទុយគ្នាស្រឡះទៅនឹងអ្វីដែល អៀង ធីរិទ្ធ ធ្លាប់បានធ្វើនិងអ្វីដែលខ្លួនធ្លាប់ហៅថា “ការថែទាំសុខភាពប្រជាជន” នៅក្នុងរបបខ្មែរក្រហម ។

បន្ថែមទៅនឹងសេវាសុខភាពយ៉ាងវិសេសវិសាលដែល អៀង ធីរិទ្ធ បានទទួល វាជាការលំបាកសម្រាប់ជនរងគ្រោះ និងប្រជាជនកម្ពុជាទាំងអស់ក្នុងការទទួលយកនូវការលើកកម្ពស់សិទ្ធិរបស់ អៀង ធីរិទ្ធ ដែលកើតឡើងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សិទ្ធិការពារខ្លួនជាមូលដ្ឋាននៅតែជាទស្សនៈមួយពិបាកយល់នៅក្នុងតុលាការកម្ពុជា ។ ដូច្នេះ សេចក្តីប្រកាសរបស់

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអំពីសិទ្ធិទទួលបានយុត្តិធម៌ និងសិទ្ធិរបស់ជនជាប់ចោទគឺនៅតែជារឿងចម្លែក ហើយដែលជាទស្សនៈរបស់បរទេសដែលបានបញ្ចូលក្នុងសង្គមប្រជាជនកម្ពុជាជាទូទៅ ។ ជាថ្មីម្តងទៀត ភាពទន់ខ្សោយនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់កម្ពុជា គឺជាកេរដំណែលនៃរបបខ្មែរក្រហម ដែលបានបំផ្លិចបំផ្លាញស្ថាប័នសំខាន់ៗ និងស្ថាប័នសង្គមស៊ីវិលរបស់កម្ពុជាដែលបង្កឲ្យមានភាពអយុត្តិធម៌ដ៏ជាក់ច្បាស់នៅក្នុងស្មារតីនៃភាពអយុត្តិធម៌សម្រាប់ជនរងគ្រោះដែលមើលឃើញថា អៀង ធីរិទ្ធ បានទទួលនូវកម្រិតយុត្តិធម៌ដ៏ត្រឹមត្រូវខាងផ្លូវច្បាប់ ដែលមិនមានជនជាប់ចោទកម្ពុជាណាម្នាក់អាចរំពឹងថានឹងទទួលបានដូច្នេះទេ នៅពេលប្រជាជនកម្ពុជាត្រូវបានកាត់ទោសនៅក្នុងតុលាការកម្ពុជា សូម្បីតែបទឧក្រិដ្ឋដ៏តូចតាចក៏ដោយ ។

ប្រសិនបើ អៀង ធីរិទ្ធ នៅទីបំផុតអាចប្រណាំងឈ្នះនឹងពេលវេលានិងឈ្នះក្តីដែលការទទួលខុសត្រូវរបស់ខ្លួននៅក្នុងរបបខ្មែរក្រហមមិនដែលទទួលបាននូវការកាត់ទោស ហេតុការណ៍ជាអកុសលបែបនេះអាចនឹងប្រើប្រាស់ជាផ្នែកមួយនៃដំណើរការយុត្តិធម៌អន្តរកាល ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។

ទីមួយ ការមិនមានសម្បទាគ្រប់គ្រាន់និងការដោះលែង អៀង ធីរិទ្ធ មិនបង្កជាឧបសគ្គខ្លាំងដល់ដំណើរការស្វែងរកយុត្តិធម៌អន្តរកាលក្នុងកម្រិតទ្រង់ទ្រាយធំ ដែលកំពុងតែដំណើរការក្នុងករណី០ ០២នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះទេ ហើយសង្ឃឹមថានឹងបង្កើនសេចក្តីប្រាថ្នាចង់បានបន្ថែមទៀតដល់តុលាការក្នុងការជំរុញកិច្ចដំណើរការទៅមុខជាបន្ទាន់ក្នុងករណីប្រឆាំងមេដឹកនាំខ្មែរក្រហមដទៃទៀត ។

សេវាថែទាំសុខភាពផ្លូវចិត្តដែល អៀង ធីរិទ្ធ បានទទួលគឺជាសញ្ញាណមួយនៃសេចក្តីមេត្តា ករុណាប្រសិនបើប្រៀបធៀបទៅនឹងកង្វះខាតទាំងស្រុងនៃសេចក្តីករុណាបែបនេះក្នុងរបបខ្មែរក្រហម ។ ភាពពេញចិត្តមួយចំនួនអាចនឹងទទួលបានពីជនរងគ្រោះដែលត្រូវបានដកហូតឱកាសក្នុងការដាក់ អៀង ធីរិទ្ធ ឲ្យទទួលខុសត្រូវតាមច្បាប់តុលាការ ដោយជំទាស់មិនទទួលយកបទដ្ឋានតុលាការយុត្តិធម៌ជាមូលដ្ឋានមួយ សូម្បីតែនៅចំពោះមុខឧក្រិដ្ឋកម្មដ៏ព្រៃផ្សៃដែល អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ក៏ដោយ ។ លើសពីនេះទៅទៀត បញ្ហាសុខភាពផ្លូវចិត្តដ៏ស្មុគស្មាញដែលកើតមាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចនឹងត្រូវបានយកមកប្រើប្រាស់ដើម្បីពង្រីងវិស័យសុខភាពផ្លូវចិត្តនៅប្រទេសកម្ពុជាដែលជាកេរដំណែលនៃរបបខ្មែរក្រហម ។

ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រើអំពើហិង្សាប្រឆាំងនឹងអារម្មណ៍ ព្រមទាំងមនោសញ្ចេតនាជាមូលដ្ឋានរបស់មនុស្ស ហើយខ្មែរក្រហមបានចាត់ទុកអាការនៃរោគសញ្ញាសាមញ្ញ ដូចជា ឈឺក្បាលថាជាភាពទន់ខ្សោយ និងថាជាជំងឺរបស់ចក្រពត្តិនិយម ។ អ្នកដែលមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរដូចអ្វីដែល អៀង ធីរិទ្ធ កំពុងទទួលរងសព្វថ្ងៃ នឹងត្រូវបានកម្ចាត់ចោលភ្លាមដោយរបបខ្មែរក្រហមដែលបានចាត់ទុកថាជាសញ្ញាណនៃភាពទន់ខ្សោយនៃសង្គមដែលត្រូវតែចាត់វិធានការ ។

នៅពេលនេះ អៀង ធីរិទ្ធ ត្រូវបានផ្តល់នូវក្តីមេត្តាករុណា ដែលក្តីមេត្តាករុណានេះ ខ្លួនបានធ្វើការយ៉ាងសកម្មដើម្បីបំបាត់ចោលក្នុងនាមជារដ្ឋមន្ត្រីខ្មែរក្រហមមួយរូប ។ ខណៈពេលដែលការធ្វើបែបនេះគឺជាទង្វើដ៏ឈឺចាប់មួយសម្រាប់ជនរងគ្រោះ ស្របពេលជាមួយគ្នានោះដែរ យើងក៏មានក្តីសង្ឃឹមយ៉ាងមុតមាំក្នុងផ្លូវដ៏វែងឆ្ងាយទៅមុខថាទង្វើនេះនឹងត្រូវបានមើលឃើញថាជាភាពជោគជ័យដ៏តូចមួយសម្រាប់ភាពយុត្តិធម៌ និងភាពថ្លៃថ្នូររបស់មនុស្សជាតិ ។ **ឆាំង យុ**



**ទទួលវត្ថុអនុស្សាវរីយ៍ ៖** អៀង ធីរិទ្ធ ជួបជាមួយគណៈប្រតិភូស៊ុយអែដក្នុងអំឡុងដំណើរទស្សនកិច្ចនៅប្រទេសជប៉ុននារបបកម្ពុជាប្រជាធិបតេយ្យ ។ យោងតាមលោក សួង ស៊ីគឿន បញ្ញវន្តមកពីប្រទេសបារាំង ហើយក្រោយមកធ្វើការនៅក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យបានឲ្យដឹងថា គណៈប្រតិភូជនជាតិស៊ុយអែដបានប្រគល់វត្ថុអនុស្សាវរីយ៍ជូន អៀង ធីរិទ្ធ នៅក្នុងជំនួបនោះ ក្រោយពីពិភាក្សានិងពិសារភេសជ្ជៈរួចមក ។ ស្ត្រីម្នាក់ឈ្មោះ សែម (ខាងស្តាំបំផុត) ដែលជាអ្នកសិល្បៈធ្វើការនៅក្រសួងវប្បធម៌អប់រំនិងសិក្សាធិការនៃរបបកម្ពុជាប្រជាធិបតេយ្យបានរួមដំណើរជាមួយ អៀង ធីរិទ្ធ ទៅកាន់ប្រទេសជប៉ុនដែរ ។

(ប្រភពៈ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)



***ស្ត្រីមេម៉ាយក្រោយសង្គ្រាម*** ៖ *រូបគំនូរគូរដោយវិចិត្រករខ្មែរ ស្វាយ កេន ក្នុងឆ្នាំ១៩៩៩ ដែលមានចំណងជើងថា វាលស្ត្រីមេម៉ាយ ។ រូបគំនូរនេះបង្ហាញពីស្ថានភាពប្រទេសកម្ពុជានាសម័យក្រោយរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ដែលស្ត្រីមួយចំនួនធំក្លាយជាស្ត្រីមេម៉ាយដោយសារតែស្វាមីត្រូវបានខ្មែរក្រហមសម្លាប់ ។ ស្ត្រីបានដើរតួនាទីដ៏សំខាន់ដើម្បីស្តារប្រទេសឡើងវិញក្រោយពីខ្ទេចខ្ទីដោយសង្គ្រាម ។ វិចិត្រករ ស្វាយ កេន បានទទួលមរណភាពប្រាំបួនឆ្នាំក្រោយពីគូរគំនូរនេះ គឺនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ ពេលដែលគាត់មានអាយុ៧៦ឆ្នាំ ។ រូបគំនូរនេះគឺជាអំណោយផ្ទាល់ខ្លួនពីលោកស្រី ឡាទីត្យា វ៉ាន់ដេន អាសាម អតីតឯកអគ្គរដ្ឋទូតហូឡង់ ប្រចាំប្រទេសកម្ពុជាផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ។ រូបថតនៃរូបគំនូរនេះត្រូវបានបោះពុម្ពនៅក្នុងសៀវភៅមួយដែលមានចំណងជើងថា «នាំយកខ្មែរក្រហមទៅប្រឈមមុខនឹងយុត្តិធម៌» ដែលរៀបរៀងដោយសាស្ត្រាចារ្យ ចាយ៉ា រ៉ាមជី និង ប៉ែក វ៉ាន់ស្កាក់ ។ សៀវភៅនេះពិនិត្យទៅលើបញ្ហាច្បាប់ជុំវិញការដាក់ឲ្យទទួលខុសត្រូវទៅលើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមនិងឧក្រិដ្ឋកម្មនៃអំពើហិង្សាទ្រង់ទ្រាយធំជាទូទៅ ។*



***ដំណើរទស្សនកិច្ចចុងក្រោយ*** : *អៀង ធីរិទ្ធ (ខាងឆ្វេង) ជាមួយនឹងស្វាមី អៀង សារី (ខោអាវពណ៌ខ្មៅ ឈរកណ្តាល) អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស និងគណៈប្រតិភូចិនដែលដឹកនាំដោយលោក វ៉ាង ដុងស៊ីង (ខាងស្តាំ) កំពុងឈរស្តាប់ការរៀបរាប់ពី អៀង សារី នៅលើស្ពានព្រះមុនីវង្ស ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អំឡុងពេលធ្វើដំណើរទស្សនកិច្ចនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៧៨ គណៈប្រតិភូចិនបានទទួលការស្វាគមន៍ពីសំណាក់ ប៉ុល ពត នៅអាកាសយានដ្ឋានពោធិចិនតុង ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចិន គឺជាប្រទេសមួយក្នុងចំណោមប្រទេសដ៏តិចតួចដែលមានទំនាក់ទំនងការទូតល្អប្រសើរជាមួយប្រទេសកម្ពុជា ។ ស្ត្រីឈរបែរខ្នងគឺសមមិត្ត ស៊ៀ អ្នកបកប្រែភាសាខ្មែរ-ចិន ។ (ប្រភព: បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)*



**កុមារកម្ពុជានៅក្នុងឆ្នាំ១៩៧៩ :** *បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅនៅខែមករា ឆ្នាំ១៩៧៩ កុមារជាងមួយសែននាក់បានក្លាយខ្លួនជាកុមារកំព្រា ដោយសារតែឪពុកម្តាយកុមារទាំងអស់នោះបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ ចាប់ពីឆ្នាំ១៩៧៥-១៩៧៩ ខ្មែរក្រហមបានដឹកនាំប្រទេសទាំងមូលឲ្យធ្លាក់ទៅក្នុង «ឋាននរកនៅលើផែនដី» ដែលបណ្តាលឲ្យប្រជាជនស្លាប់ជិតពីរលាននាក់ ។ រូបភាពនេះត្រូវបានថតដោយក្រុមអ្នកសារព័ត៌មានរបស់ស្ថានីយទូរទស្សន៍ទីក្រុងហូជីមិញ ។ អ្នកសារព័ត៌មាននេះបានមកដល់ប្រទេសកម្ពុជា ហើយចាប់យករូបភាពដែលបង្ហាញពីជីវិតដ៏ខ្លោចផ្សាររបស់កុមារកម្ពុជាក្រោយពីបានឆ្លងកាត់របបខ្មែរក្រហមនេះ ។ ខែមករា ឆ្នាំ១៩៧៩ ។ (ប្រភព : បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ប្រតិកម្មរបស់ប្រជាជនចំពោះការដោះលែង អៀង ធីរិទ្ធ

ការបញ្ជាក់ឡើងវិញរបស់អង្គជំនុំជម្រះទៅលើការដោះលែង អៀង ធីរិទ្ធ ដែលជាជនជាប់ចោទម្នាក់ក្នុងចំណោមបួននាក់ នៅក្នុងសំណុំរឿង០០២ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ បានក្លាយជាសញ្ញាណមួយក្នុងការជំរុញឲ្យមានការពិនិត្យមើលទៅលើអារម្មណ៍ជារួមរបស់សាធារណជន ចំពោះដំណើរការនីតិវិធីច្បាប់នេះ ។ អត្ថបទនេះមិនសំដៅឆ្លើយតប ឬចោទសួរពីឆន្ទានុសិទ្ធិរបស់តុលាការទេ ប៉ុន្តែចង់ឲ្យសំឡេងសង្គមស៊ីវិល សាស្ត្រាចារ្យ និងសាធារណជន ត្រូវបានស្តាប់ឮអំពីការពិតដែលថា អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីសង្គមកិច្ចក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ត្រូវបានរកឃើញថាគ្មានសម្បទាគ្រប់គ្រាន់ក្នុងការជំនុំជម្រះ ដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រចំនួនប្រាំនាក់ ដែលតែងតាំងដោយសាលាក្តី ។ "ការសន្និដ្ឋានជាឯកច្ឆ័ន្ទ" បានបញ្ជាក់ថា អៀង ធីរិទ្ធ រងផលប៉ះពាល់ដោយសារ "ស្ថានភាពនៃការធ្លាក់ចុះបញ្ញាស្មារតីដែលចេះតែវិវដ្តទៅមុខ" ។

ក្នុងបទសម្ភាសន៍ចំនួន២៧ជាមួយដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ និងសាស្ត្រាចារ្យ ទស្សនៈរបស់អ្នកទាំងអស់ត្រូវបានបង្ហាញក្នុងអត្ថន័យមួយចំនួន មានដូចជា "ពេញចិត្ត" "សោកស្តាយ" "មិនសប្បាយចិត្ត" និង "ព្រួយបារម្ភ" ជាដើម បើទោះជាទស្សនៈជាទូទៅហាក់ដូចជាពិបាកទទួលយកថា ជនសង្ស័យម្នាក់ក្នុងចំណោមជនសង្ស័យមួយចំនួនតូចស្រាប់ហើយនេះ កំពុងត្រូវបានដោះលែងពីមន្ទីរឃុំឃាំងបណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយឥតកំណត់ ។ ខាងក្រោមនេះជាការដកស្រង់សម្តីទាំងស្រុង ។

◆ **ឡុញ ញ៉ាំ** : ដើមបណ្តឹងរដ្ឋប្បវេណីនិយាយថា "នេះជាការសម្រេចរបស់តុលាការ ។ តុលាការនេះអនុវត្តតាមច្បាប់ជាធរមាន ។ ខ្ញុំគ្មានបញ្ហាជាមួយនឹងការដោះលែងនេះទេ ដោយសារ អៀង ធីរិទ្ធ មានជំងឺផ្លូវចិត្ត ។ ប៉ុន្តែ ប្រសិនបើ អៀង ធីរិទ្ធ ជាសះស្បើយឡើងវិញ គាត់គួរត្រូវបាននាំយកមកកាត់ទោសវិញ ។ ខ្ញុំគ្រាន់តែជាពលរដ្ឋសាមញ្ញម្នាក់ប៉ុណ្ណោះ ។ ខ្ញុំគ្មានសិទ្ធិសម្រេចទេ ប៉ុន្តែគោរពតាមឆន្ទានុសិទ្ធិរបស់តុលាការ" ។

◆ **ចៅ ឃីម** : ដើមបណ្តឹងរដ្ឋប្បវេណីនិយាយថា "យើងលែងអាចកាត់ទោស អៀង ធីរិទ្ធ ទៀត ហើយដោយសារក្រុមអ្នកជំនាញបាននិយាយថា អៀង ធីរិទ្ធ មិនអាចចូលរួមក្នុងសវនាការ ។ ខ្ញុំមិនមានបញ្ហាជាមួយនឹងការសម្រេចនេះទេ ។ តាមពិត អៀង ធីរិទ្ធ ក៏មានប្តីគាត់ប្រឈមមុខទៅនឹងការចោទប្រកាន់ដែរ នៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ។

◆ **លី ប៉ាត់** : ដើមបណ្តឹងរដ្ឋប្បវេណី និយាយថា "និយាយតាមត្រង់ទៅ ខ្ញុំមិនសប្បាយចិត្តទេ ជាមួយនឹងការដោះលែង អៀង ធីរិទ្ធ ។ ខ្ញុំគិតថា អៀង ធីរិទ្ធ អាចធ្វើពុត ។ នេះជាការសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ខ្ញុំទទួលស្គាល់ថារឿងនេះជាការត្រឹមត្រូវ ដូចដែលខ្ញុំបានស្តាប់វិទ្យុអាស៊ីសេរី និងវិទ្យុបារាំងអន្តរជាតិ ។ ចំពោះខ្ញុំផ្ទាល់ ខ្ញុំចង់ឲ្យតុលាការដាក់គុកគាត់ ។ អៀង ធីរិទ្ធ មិនអាចគិតនិងផ្តោតអារម្មណ៍បាន ។ បើទោះជាក្រុមអ្នកជំនាញបានផ្តល់ការបកស្រាយដែលអាចទទួលយកបានអំពីសុខភាពរបស់ អៀង ធីរិទ្ធ ក៏ដោយ ខ្ញុំចេះតែមានអារម្មណ៍ថា អៀង ធីរិទ្ធ ធ្វើពុត" ។

◆ **អែម អឿន** : ដើមបណ្តឹងរដ្ឋប្បវេណី និយាយថា "ខ្ញុំគិតថា គ្មានបញ្ហាសោះក្នុងការដោះលែងនេះ ។ ក្រុមជំនាញច្បាប់ប្រកាន់ខ្ជាប់តាមច្បាប់ក្នុងការស្វែងរកយុត្តិធម៌ ។ ដើម្បីជាប្រយោជន៍យុត្តិធម៌សម្រាប់ទាំងអស់គ្នា យើងមិនអាចយកអ្នកជំងឺ ឬអ្នកមានបញ្ហាផ្លូវចិត្តទៅកាត់ទោសទេ ។ អ្វីដែលតុលាការកំពុងអនុវត្តគឺជារឿងត្រឹមត្រូវ ។ វាជាការប្រសើរបំផុត ប្រសិនបើ អៀង ធីរិទ្ធ អាចនិយាយចេញនូវការពិតទាំងអស់នោះ" ។

◆ **សយ សែន** ៖ ដើមបណ្តឹងរដ្ឋប្បវេណី ដែលរស់នៅស្រុកត្រាំកក់ ខេត្តតាកែវ និយាយថា "ដោយសារតុលាការបានសម្រេចចិត្តដោះលែង អៀង ធីរិទ្ធ ខ្ញុំមានអារម្មណ៍មិនសប្បាយចិត្តទេ ។ បើទោះជា អៀង ធីរិទ្ធ មានជំងឺផ្លូវចិត្តក៏ដោយ ក៏ខ្ញុំនៅតែមិនសប្បាយចិត្តជាមួយនឹងរឿងនេះទេ ។ តុលាការគួរពិចារណាឡើងវិញចំពោះសេចក្តីសម្រេចដោះលែង អៀង ធីរិទ្ធ ពីមន្ទីរឃុំឃាំងបណ្តោះអាសន្ន ។ ដូច្នេះ យុត្តិធម៌អាចមានភាពគ្រប់គ្រាន់សម្រាប់ខ្ញុំ និងជនរងគ្រោះដទៃទៀត" ។

◆ **សាន សុខ** ៖ រស់នៅស្រុកព្រៃកប្បាស ខេត្តតាកែវ និយាយថា "ខណៈដែលខ្ញុំបានតាមដានដំណើរការតុលាការកាលពីថ្ងៃម្សិលមិញ ហើយយល់ឃើញថា អៀង ធីរិទ្ធ ត្រូវបានដោះលែង ខ្ញុំគិតថា អៀង ធីរិទ្ធ មានវ័យចំណាស់ ហើយតុលាការនឹងមិនកាត់ទោសអ្នកមានជំងឺផ្លូវចិត្តទេ ។ ដូច្នេះ ខ្ញុំគិតថា វាអាស្រ័យលើតុលាការក្នុងការដោះស្រាយជាមួយ អៀង ធីរិទ្ធ" ។

◆ **ជា យុថារុន** ៖ រស់នៅស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ និយាយថា "បើទោះជាខ្ញុំគោរពតាមដំណើរការរបស់តុលាការ ហើយដឹងថា អៀង ធីរិទ្ធ ត្រូវបានដោះលែង ខ្ញុំគិតថា អៀង ធីរិទ្ធ មិនគួរស្ថិតនៅក្រោមមន្ទីរឃុំខ្លួនបណ្តោះអាសន្ននោះឡើយ ។ អៀង ធីរិទ្ធ ជាមនុស្សម្នាក់ក្នុងចំណោមអ្នកដែលបានធ្វើឲ្យបាត់បង់ជីវិតប្រជាជនកម្ពុជា និងសាច់ញាតិរបស់ខ្ញុំ ។ ដូច្នេះខ្ញុំសោកស្តាយនៅពេលដែលបានឮពីការដោះលែងនេះ ។ ជាចុងក្រោយ ខ្ញុំសូមឲ្យតុលាការ ពិនិត្យរឿងនេះម្តងទៀត" ។

◆ **ជា ហៀប** ៖ ដើមបណ្តឹងរដ្ឋប្បវេណី និយាយថា "ខ្ញុំមិនយល់ស្របជាមួយតុលាការទេ ដែលបានសម្រេចអនុញ្ញាតឲ្យអៀង ធីរិទ្ធ នៅក្រោមមន្ទីរឃុំឃាំងបណ្តោះអាសន្ន ។ តាមទស្សនៈខ្ញុំ អៀង ធីរិទ្ធ ជាមេដឹកនាំម្នាក់ដែលបណ្តាលឲ្យមនុស្សជាច្រើនស្លាប់ ។ ខ្ញុំគិតថានៅពេល អៀង ធីរិទ្ធ ត្រូវបានដោះលែងមេដឹកនាំខ្មែរក្រហមបីនាក់ទៀត នឹងស្នើសុំដូចគ្នាដែរ ។ នៅទីបញ្ចប់ ខ្ញុំគិតថាប្រជាជនយើងមិនអាចទទួលបានយុត្តិធម៌ទេ" ។

◆ **ហ៊ុន ដឹម** ៖ ដើមបណ្តឹងរដ្ឋប្បវេណី រស់នៅខេត្តតាកែវ និយាយថា "ខ្ញុំយល់ស្របជាមួយនឹងតុលាការដែលសម្រេចដោះលែង អៀង ធីរិទ្ធ" ។

◆ **អ៊ឹម វណ្ណៈ** ៖ ដើមបណ្តឹងរដ្ឋប្បវេណីនិយាយថា "ស្របតាមសាសនាព្រះពុទ្ធគួរតែមានការអត់ឱន ។ ដូច្នេះខ្ញុំយល់ស្របជាមួយនឹងការដោះលែង អៀង ធីរិទ្ធ ។ យើងមានតុលាការដែលអនុវត្តច្បាប់ ការដោះលែងនេះគួរតែផ្អែកទៅលើច្បាប់ដែរ" ។

◆ **ចាន់ សុភាព** ៖ ដើមបណ្តឹងរដ្ឋប្បវេណី និយាយថា "ខ្ញុំយល់ស្របជាមួយនឹងការដោះលែង អៀង ធីរិទ្ធ ។ ខ្ញុំជឿលើសេចក្តីសម្រេចរបស់តុលាការដោយសារតែ អៀង ធីរិទ្ធ ពិតជាមានជំងឺផ្លូវចិត្តមែន ហើយមិនអាចចងចាំបាន ។ អាស្រ័យហេតុនេះ ខ្ញុំគិតថាការដោះលែង អៀង ធីរិទ្ធគឺត្រឹមត្រូវ ដោយសារតែថា តាមច្បាប់អ្នកមានជំងឺផ្លូវចិត្ត មិនត្រូវបានកាត់ទោសទេ" ។

◆ **ថេ អ៊ីសា** ៖ ដើមបណ្តឹងរដ្ឋប្បវេណី ដែលរស់នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម និយាយថា "បើទោះជាខ្ញុំមិនមែនជាជំនាញខាងច្បាប់ក៏ដោយ ខ្ញុំគ្មានអារម្មណ៍រីករាយជាមួយនឹងការដោះលែង អៀង ធីរិទ្ធទេ ។ ប៉ុន្តែ ខ្ញុំជឿលើការសម្រេចរបស់តុលាការ ។ តុលាការមានហេតុផលរបស់ខ្លួន និងមូលដ្ឋានច្បាប់ក្នុងការដោះលែង អៀង ធីរិទ្ធ" ។

◆ **ឃុន សាមិត** ៖ ដើមបណ្តឹងរដ្ឋប្បវេណីនិយាយថា "ខ្ញុំយល់ស្របជាមួយនឹងការដោះលែង អៀង ធីរិទ្ធ ដោយសារគាត់មានស្ថានភាពជម្ងឺផ្លូវចិត្តមិននឹងនរ ប៉ុន្តែខ្ញុំស្នើឲ្យកាត់ទោសបន្តទៀតទៅលើអ្នកដែលមានសុខភាពល្អ" ។

◆ **សុះ មីន** ៖ ដើមបណ្តឹងរដ្ឋប្បវេណីនិយាយថា "ប្រសិនបើ អៀង ធីរិទ្ធ មានជំងឺនោះមែន ខ្ញុំសប្បាយចិត្តជាមួយនឹងនីតិវិធីក្នុងការដោះលែងគាត់ដោយឥតកំណត់ ។ ខ្ញុំគ្មានអ្វីបន្ថែមទៀតទេ" ។

◆ **ម៉ាន គ្រីយ៉ះ** ៖ ដើមបណ្តឹងនិយាយថា "ខ្ញុំនឹងលើកលែង និងអត់ឱន ប្រសិន អៀង ធីរិទ្ធ មានជំងឺដែលធ្វើឲ្យគាត់មិនអាចមានលទ្ធភាពនិយាយ និងមិនអាចយល់បាន ។ ប៉ុន្តែ គាត់មានសុខភាពល្អ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គួរកាត់ទោសគាត់បន្ថែមទៀត ។ ការឈឺចាប់យ៉ាងខ្លាំងត្រូវបានបន្តឡើងដោយការសម្លាប់ឪពុកមា ម្តាយមីង និងជីដូនជីតារបស់ខ្ញុំ" ។

◆ **អ៊ុម ពិសិដ្ឋ** ៖ ដើមបណ្តឹងរដ្ឋប្បវេណីនិយាយថា «នៅពេលនិយាយដល់បញ្ហាផ្លូវច្បាប់តុលាការនឹងមិននាំយកមកកាត់ទោសចំពោះមនុស្ស ដែលគ្មានលទ្ធភាពចងចាំនិងមានជម្ងឺផ្លូវចិត្តឡើយ ។ ផ្ទុយទៅវិញ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបន្តកាត់ទោសគាត់ ការកាត់ទោសនោះនឹងមិនមានភាពយុត្តិធម៌ទេ ។ អាស្រ័យហេតុនេះហើយ ខ្ញុំយល់ស្របទាំងស្រុងជាមួយនឹងការដោះលែង អៀង ធីរិទ្ធ ។ តែទោះយ៉ាងណា ខ្ញុំបន្តចាត់ទុក អៀង ធីរិទ្ធ ថាមានកំហុស ដោយសារគាត់ជាមេដឹកនាំខ្មែរក្រហមម្នាក់ដែរ ។ ម្យ៉ាងវិញទៀត ខ្ញុំសោកស្តាយដែលមិនមានលទ្ធភាពស្តាប់ចម្លើយរបស់ អៀង ធីរិទ្ធ នៅក្នុងសវនាការ ។ វាជាការបាត់បង់យុត្តិធម៌សម្រាប់មនុស្សជំនាន់ក្រោយ» ។

◆ **ហាវ សុភា** ៖ ដើមបណ្តឹងរដ្ឋប្បវេណី និយាយថា «ខ្ញុំមិនសប្បាយចិត្តជាមួយនឹងការសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលដោះលែង អៀង ធីរិទ្ធ ទេ ។ តុលាការគួរបន្តឃុំខ្លួនគាត់ទៀត ។ អៀង ធីរិទ្ធ ជាអ្នកមានការអប់រំត្រឹមត្រូវ ដែលពូកែខាងធ្វើពុតជាមានជម្ងឺផ្លូវចិត្ត ។ ខ្ញុំក៏មិនជឿលើអ្នកជំនាញខាងវេជ្ជសាស្ត្រដែរ ។ ខ្ញុំស្នើឡើងថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគួរគិតពីអារម្មណ៍និងការឈឺចាប់របស់ជនរងគ្រោះ ដោយសារតែខ្ញុំក៏ជាជនរងគ្រោះដែលរង់ចាំការកាត់សេចក្តីនេះអស់រយៈពេលជាង ៣០ឆ្នាំមកហើយ ។ នៅទីបំផុត ជនរងគ្រោះគ្រប់រូបមិនបានទទួលយុត្តិធម៌ដ៏ពេញចិត្តទេ» ។

◆ **គេង សុភាលក្ស្មី** ៖ សាស្ត្រាចារ្យនិយាយថា «តាមន័យសាសនា យើងមិនគួរចងកំហឹងជាមួយ អៀង ធីរិទ្ធទេ ដោយសារយើងចង់បានការផ្សះផ្សា និងការអត់ឱន ដើម្បីសុភមង្គល ។ គោលការណ៍របស់ព្រះពុទ្ធសាសនាចែងថា «ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់» ម្យ៉ាងវិញទៀត អៀង ធីរិទ្ធ មានវ័យចំណាស់ហើយ និងមានជម្ងឺមនុស្សចាស់ទៀត ហើយមានបញ្ហាផ្លូវចិត្ត អាចកើតមានចំពោះរូបគាត់ ។ អាស្រ័យហេតុនេះ វាមិនជាបញ្ហាទេក្នុងការដោះលែងគាត់ពីមន្ទីរឃុំឃាំង ។ តាមផ្លូវច្បាប់អ្នកដែលប្រព្រឹត្តអំពើអាក្រក់នឹងត្រូវទទួលការកាត់ទោស ហើយប្រឈមមុខនឹងការដាក់ទោសទៀត ។ តែទោះយ៉ាងណា ការដោះលែងនេះត្រូវបានគាំទ្រដោយសហព្រះរាជអាជ្ញារជាតិ និងអន្តរជាតិ ។ តាមទស្សនៈខ្ញុំ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនចង់មានបញ្ហាលំបាកនៅក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្ន ដោយសារជំងឺរបស់គាត់» ។

◆ **ជា កល្យាណ** ៖ សាស្ត្រាចារ្យនិយាយថា «អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនគួរដោះលែង អៀង ធីរិទ្ធទេ ដោយសារតែជម្ងឺរបស់គាត់ឡើយ ។ យើងទាំងអស់គ្នាដឹងនូវអ្វីដែលគាត់បានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំគិតថាគាត់គួរតែអាចទុកនៅក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្ន ។ វាជាការប្រសើរជាង» ។

◆ **ស៊ីវ ធួន** ៖ សាស្ត្រាចារ្យ និយាយថា «ទាក់ទងនឹងការដោះលែងនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជាគួរសម្រេចរឿងនេះក្នុងលក្ខណៈបណ្តោះអាសន្ន ។ នៅពេល អៀង ធីរិទ្ធ ជាសះស្បើយពីស្ថានភាពជំងឺផ្លូវចិត្ត និងមានការចងចាំបានល្អ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គួរកាត់ទោសគាត់ឡើងវិញ ។ អៀង ធីរិទ្ធ មិនមែនជាជនសង្ស័យធម្មតាទេ ប៉ុន្តែបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងសម័យខ្មែរក្រហម ។ ម្យ៉ាងវិញទៀត ខ្ញុំចង់ឲ្យតុលាការដំណើរការឲ្យបានលឿន ដោយសារមេដឹកនាំខ្មែរក្រហមទាំងនោះចាស់ៗអស់ហើយ ។ ដំណើរការឆាប់រហ័សជាងមុន នឹងបង្កលទ្ធភាពឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបានយុត្តិធម៌» ។

◆ **គង់ ហាក់** ៖ សាស្ត្រាចារ្យនិយាយថា «នៅក្នុងករណីនេះ យើងមិនធ្វើអ្វីបានទេ ដោយសារតែសេចក្តីសម្រេចដោះលែង អៀង ធីរិទ្ធ ត្រូវបានធ្វើឡើងដោយតុលាការ ។ ម្យ៉ាងវិញទៀត យើងមិនអាចកាត់ទោសមនុស្សដែលមិនអាចមានលទ្ធភាពចងចាំបាន ។ ប្រសិនបើករណីនេះបានបន្ត វាហាក់ដូចជាដូចគ្នាទៅនឹងសម័យរបបផ្តាច់ការរបស់របបខ្មែរក្រហមហើយ» ។

◆ **ឈឹម ឌីណា** ៖ សាស្ត្រាចារ្យ និយាយថា «តាមទស្សនខ្ញុំ មិនគួរមានការតវ៉ាអំពីការដោះលែង អៀង ធីរិទ្ធ ទេ ដោយសារតែវាជាសេចក្តីសម្រេចរបស់តុលាការ ដោយមានការគាំទ្រពីសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិទៀតផង ។ ម្យ៉ាងវិញទៀត ក្នុងនាម

ជាអ្នកប្រវត្តិសាស្ត្រ ខ្ញុំតាមដានព័ត៌មានអំពីការកាត់ទោសនេះ ។ ខ្ញុំបានប្រមូលឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីបង្រៀនយុវជនអំពីអ្វីដែលបានកើតឡើងក្នុងសម័យខ្មែរក្រហម ដើម្បីជំរុញឲ្យមានការផ្សះផ្សា និងកសាងសន្តិភាព ។

◆ **ប៊ែន នាង** : សាស្ត្រាចារ្យ និយាយថា "តាមទស្សនៈខ្ញុំ ខ្ញុំយល់ស្របជាមួយនឹងការដោះលែង អៀង ធីរិទ្ធ ។ ខ្ញុំក៏មានអារម្មណ៍អាណិតអាសូរចំពោះគាត់ដែរ ដោយគាត់មានវ័យចំណាស់ហើយ ។ ខ្ញុំទទួលស្គាល់ថា គាត់ត្រូវបានស្អប់ខ្ពើមដោយសារតែបទឧក្រិដ្ឋមកលើប្រជាជនកម្ពុជា ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបគ្រប់គ្រងរបស់គាត់ ។ ប៉ុន្តែ ខ្ញុំផ្លាស់ប្តូរចិត្តវិញ ។ រឿងនេះបានកន្លងផុតទៅអស់ជាច្រើនឆ្នាំហើយ ។ ជាពិសេស ទស្សនវិជ្ជាព្រះពុទ្ធថែងថា "ពៀររំងាប់ដោយការមិនចងពៀរ" ។ តាមផ្លូវច្បាប់វិញ ស្ថានភាពសុខភាពរបស់គាត់បានធ្លាក់ចុះដុនដាប ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គួរអត់ឱនដល់គាត់ដោយមិនដាក់ពន្ធនាគារគាត់អស់មួយជីវិត ។ បច្ចុប្បន្ននេះ យើងត្រូវអប់រំយុវជនអំពីអ្វីដែលបានកើតឡើងដើម្បីជំរុញឲ្យមានការផ្សះផ្សា និងកសាងសន្តិភាព" ។

◆ **សេង ពិសិដ្ឋនារី** : សាស្ត្រាចារ្យនិយាយថា "ដូចអ្នករស់រានមានជីវិតដទៃទៀតដែរ ខ្ញុំមិនសប្បាយចិត្តជាមួយនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាក់ទងទៅនឹងការដោះលែងនេះទេ ដោយសារគាត់គឺជាអ្នកដែលបង្កឲ្យស្លាប់មនុស្សជិតពីរលាននាក់ ដោយរាប់បញ្ចូលទាំងសមាជិកក្រុមគ្រួសាររបស់ខ្ញុំក្នុងអំឡុងរបបខ្មែរក្រហម ។ ខ្ញុំគិតថា តុលាការគួរកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងនោះដើម្បីនាំយកយុត្តិធម៌មកជូនប្រជាជនកម្ពុជា ដោយរាប់បញ្ចូលទាំងខ្ញុំដែរ ។ ម្យ៉ាងវិញទៀត ខ្ញុំឆ្ងល់ថា នៅពេលដែល អៀង ធីរិទ្ធ ទទួលរងនូវស្ថានភាពផ្លូវចិត្តធ្ងន់ធ្ងរឡើង ហេតុអ្វីតុលាការមិនព្រមពន្យឿនការកាត់សេចក្តីនេះ?"

◆ **មុំ ម៉េត** : សាស្ត្រាចារ្យនិយាយថា "ខ្ញុំហាក់ដូចជាយល់ថា អៀង ធីរិទ្ធ មិនមានជំងឺផ្លូវចិត្តទេ ។ បើទោះជាម្តាយខ្ញុំមានវ័យ៨៩ឆ្នាំហើយក៏ដោយ គាត់នៅមានការចងចាំល្អ ហើយអាចនិយាយរៀបរាប់តាំងពីសម័យឥស្សរៈរហូតដល់បច្ចុប្បន្ន ។ ដូច្នេះ ខ្ញុំគិតថា អៀង ធីរិទ្ធ អាចធ្វើពុតដើម្បីគេចពីការកាត់ទោស ។ តាមពិត ខ្ញុំមិនសប្បាយចិត្តជាមួយនឹងការដោះលែងនេះទេ ដោយសារប្រជាជនជិតពីរលាននាក់ បានស្លាប់នៅក្រោមរបបនោះ ។ ដូច្នេះ តុលាការគួរតែបន្តការកាត់សេចក្តី អៀង ធីរិទ្ធ នេះ ។ តែទោះយ៉ាងណា វាជាការសម្រេចរបស់តុលាការ ។ ខ្ញុំមិនដឹងថាអាចធ្វើបាននោះទេ" ។

◆ **តែន គីមតុន** : សាស្ត្រាចារ្យនិយាយថា "តាមទស្សនៈខ្ញុំ ខ្ញុំមិនចង់ឲ្យដោះលែង អៀង ធីរិទ្ធទេ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គួរតែបន្តឃុំខ្លួន និងតាមដានស្ថានភាពសុខភាពរបស់គាត់ដោយសារតែស្ថានភាពជំងឺផ្លូវចិត្ត មិនមែនជាបញ្ហាទៀងទាត់ទេ ។ ក្មេងៗក៏អាចមានអារម្មណ៍ល្អនិងមិនល្អដែរ ។ ដូច្នេះ ខ្ញុំចង់ឲ្យតុលាការបន្តកាត់សេចក្តីគាត់តទៅទៀត ដើម្បីធ្វើជាគំរូសម្រាប់អ្នកដែលមានចិត្តចង់បំពានច្បាប់ ។ នៅក្នុងករណីនេះ វាអាចធ្វើជាគំរូអាក្រក់សម្រាប់អ្នកផ្សេងទៀតនៅក្នុងសង្គម ។

◆ **មួង សុជាត** : សាស្ត្រាចារ្យនិយាយថា "តាមផ្លូវសីលធម៌ សេចក្តីសម្រេចរបស់តុលាការក្នុងការដោះលែង អៀង ធីរិទ្ធ អាចទទួលយកបានដោយសារប្រជាជនកម្ពុជាភាគច្រើនមានចិត្តអត់ឱនច្រើន ។ ម្យ៉ាងវិញទៀត ប្រសិនបើតុលាការបន្តកាត់ទោស អៀង ធីរិទ្ធ គាត់អាចប្រឈមមុខនឹងការស្លាប់នៅក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្ន ។ ស្ថានភាពសុខភាពរបស់គាត់ កំពុងធ្លាក់ចុះពីមួយថ្ងៃទៅមួយថ្ងៃ ។ ដូច្នេះ តាមទស្សនៈខ្ញុំ វាជាការសម្រេចចិត្តត្រឹមត្រូវក្នុងការអនុញ្ញាតគាត់ចាកចេញពីមន្ទីរឃុំឃាំងបណ្តោះអាសន្ន ។

យោបល់ទាំងនេះគឺជាប្រតិកម្មទូទៅក្នុងចំណោមមនុស្សចំនួន២៧នាក់ ។ តែទោះជាយ៉ាងណា ពន្លឺនៃក្តីសង្ឃឹមនៅមាននៅឡើយ ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលក្រុមអ្នកជំនាញបានធ្វើការវាយតម្លៃប្រចាំឆ្នាំស្តីពី "ថាតើជម្រើសព្យាបាលថ្មី ឬវិធីព្យាបាលចំពោះស្ថានភាពនៃការវង្វេងស្មារតីដែលចេះតែវិវត្តទៅមុខ (ជាពិសេសជំងឺ Alzheimer) ត្រូវបានរកឃើញ" ។ ប្រការនេះផ្តល់សារយ៉ាងច្បាស់ថា ការជាសះស្បើយរបស់ អៀង ធីរិទ្ធ នឹងបង្កលទ្ធភាពឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបន្ត ប៉ុន្តែអាណត្តិរបស់តុលាការគឺជាការព្រួយបារម្ភមួយផ្សេងទៀត ។



នារីពេទ្យខ្មែរក្រហម កំពុងកូរថ្នាំនៅមន្ទីរពេទ្យមួយក្នុងខែសីហា ឆ្នាំ១៩៧៨ ។
រូបថតៈ ហ្គូណា បើកស្រ្តូម (ប្រភពៈ បណ្ណសារដ្ឋានមជ្ឈមណ្ឌល ឯកសារកម្ពុជា)

# សេចក្តីប្រកាសព័ត៌មាន

## ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានដោះលែងជាមួយលក្ខខណ្ឌបណ្តោះអាសន្ន

ប្រធានអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក ដោយអនុលោមតាមវិធាន៨២(៦) នៃវិធានផ្ទៃក្នុង ធ្វើការសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំផ្អាកសេចក្តីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយគ្មានលក្ខខណ្ឌរបស់អង្គជំនុំជម្រះសាលាដំបូង ដោយសម្រេចថា៖ អៀង ធីរិទ្ធ ត្រូវបានដោះលែងជាមួយលក្ខខណ្ឌបណ្តោះអាសន្នមួយចំនួនដូចជា៖

១) ជនជាប់ចោទត្រូវជូនដំណឹងដល់អង្គជំនុំជម្រះអំពីអាសយដ្ឋានដែលខ្លួនត្រូវស្នាក់នៅ ហើយមិនត្រូវផ្លាស់ប្តូរទីលំនៅដោយមិនមានការអនុញ្ញាតពីអង្គជំនុំជម្រះឡើយ ។

២) ជនជាប់ចោទត្រូវប្រគល់លិខិតឆ្លងដែន និងឯកសារធ្វើដំណើរពាក់ព័ន្ធដទៃទៀត ហើយមិនត្រូវចេញក្រៅព្រំប្រទល់ដែនដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ ។

៣) ជនជាប់ចោទត្រូវគោរពតាមដីកាកោះដែលចេញដោយតុលាការ ។

វិធានការបណ្តោះអាសន្ននេះមានសុពលភាពរហូតដល់អង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តី សម្រេចទាំងស្រុងលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ។

**(ឯកសារ៖ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)**



*រូបខាងឆ្វេង អៀង សារី និងខាងស្តាំបង្អស់ អៀង ធីរិទ្ធ នៅក្នុងបន្ទប់សវនាការ (រូបថត៖ អ.វ.ត.ក)*

# សេចក្តីប្រកាសព័ត៌មានអង្គជំនុំជម្រះតុលាការកំពូលសម្រេចដាក់ជនជាប់ចោទ អៀង ធីរិទ្ធ ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

អង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជា បានបង្គាប់នូវរបបនៃការត្រួតពិនិត្យតាមផ្លូវតុលាការលើជនជាប់ចោទ អៀង ធីរិទ្ធ ដោយរួមបញ្ចូលទាំងការត្រួតពិនិត្យផ្នែកវិទ្យាសាស្ត្រជារៀងរាល់ប្រាំមួយខែម្តង និងការត្រួតពិនិត្យប្រចាំខែដោយនគរបាលយុត្តិធម៌ ដោយស្របទៅតាមសេចក្តីសម្រេចរបស់ខ្លួនដែល បានចេញនៅថ្ងៃទី១៤ ខែធ្នូនេះ ។

អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចទទួលយកបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាដោយផ្នែក ហើយបានបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី១៣ ខែកញ្ញា ត្រង់ចំណុចដែលថា ក្នុងអំឡុងពេលផ្អាកកិច្ចដំណើរការនីតិវិធីដោយគ្មានកំណត់ពេលលើជនជាប់ចោទ អៀង ធីរិទ្ធ អង្គជំនុំជម្រះសាលាដំបូង មិនអាចអនុវត្តយុត្តាធិការលើជនជាប់ចោទបាន ហើយនិងខ្វះនូវមូលដ្ឋានផ្លូវច្បាប់ក្នុងការសម្រេចដាក់លក្ខខណ្ឌដោយបន្ទុំលើការដោះលែងជនជាប់ចោទ ។

នៅក្នុងពេលបច្ចុប្បន្ននេះ ជនជាប់ចោទ អៀង ធីរិទ្ធ មានកាតព្វកិច្ចជូនដំណឹងដល់ អ.វ.ត.ក នូវការផ្លាស់ប្តូរអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់ខ្លួន មិនត្រូវចាកចេញពីព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលការពិនិត្យព្យាបាលផ្នែកវេជ្ជសាស្ត្រជារៀងប្រាំមួយខែម្តង ដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ដែលត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង ។ អង្គជំនុំជម្រះតុលាការកំពូល បានបង្គាប់ផងដែរថា នរគបាលយុត្តិធម៌ ត្រូវធ្វើការត្រួតពិនិត្យជាប្រចាំខែ ដើម្បីបញ្ជាក់ថា ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបន្តស្នាក់នៅអាសយដ្ឋាន ដដែលនេះ និងរាយការណ៍អំពីការគំរាមកំហែងណាមួយចំពោះសុវត្ថិភាពរបស់ជនជាប់ចោទ ។ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចបដិសេធផ្នែកផ្សេងៗទៀតនៃបណ្តឹងសាទុក្ខ និងបានសម្រេចប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណទៅឲ្យជនជាប់ចោទវិញ ។

ជនជាប់ចោទ អៀង ធីរិទ្ធ ដែលអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានរងការចោទប្រកាន់នៅខែកញ្ញា ឆ្នាំ២០១០ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទរំលោភដ៏ធ្ងន់ធ្ងរលើអនុញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងបទប្រល័យពូជសាសន៍ ។ ជនជាប់ចោទត្រូវរកឃើញថា ពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដោយមានជំងឺវង្វេងវង្វាន់កាលពីខែវិច្ឆិកា ឆ្នាំ២០១១ ហើយកិច្ចដំណើរការនីតិវិធីជំនុំជម្រះលើរូបគាត់ ត្រូវបានផ្អាកចាប់ពីពេលនោះមក ។ នៅខែកញ្ញា ក្នុងឆ្នាំនេះ អង្គជំនុំជម្រះសាលាដំបូងបានតម្កល់សាជាថ្មីនូវការរកឃើញរបស់ខ្លួនដំបូងថា ជនជាប់ចោទពុំមានសម្បទាចូលរួមសវនាការឡើយ ហើយបានបង្គាប់ដោះលែងដោយឥតលក្ខខណ្ឌ ។ សហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខទៅលើសម្រេចនេះ ដោយបានលើកឡើងថា ជាការចាំបាច់ដែលតម្រូវឲ្យមានការអនុវត្តនូវវិធានការមួយចំនួន ដើម្បីធានានូវសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីសុវត្ថិភាពរបស់ជនជាប់ចោទ និងសណ្តាប់ធ្នាប់សាធារណៈ ។ ដោយរង់ចាំសេចក្តីសម្រេចលើបណ្តឹងសាទុក្ខនៅថ្ងៃទី១៦ ខែកញ្ញា ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឲ្យដោះលែងជនជាប់ចោទដោយតម្រូវឲ្យគោរពនូវលក្ខខណ្ឌមួយចំនួន ។ ចាប់តាំងពីពេលនោះមក ជនជាប់ចោទស្ថិតនៅក្រោមអាណាព្យាបាលដែលជាកូនស្រីរបស់ខ្លួនគឺលោក អៀង វិជីដា ។

**(ឯកសារ : អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)**

# សេចក្តីសម្រេចស្តីពីការថតខ្សែអាត់សំឡេង ឬវីដេអូ នៅពេល អៀង សារី ស្ថិតនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញសេចក្តីសម្រេចលើកទីបីមិនអនុញ្ញាតឲ្យមានការថតខ្សែអាត់សំឡេង ឬវីដេអូ នៅពេល អៀង សារី កំពុងស្ថិតនៅក្នុងបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ ។

នាចុងខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ បន្ទាប់ពីជនជាប់ចោទរូបនេះត្រូវបានបញ្ជូនមកមន្ទីរឃុំឃាំងវិញ ក្រោយពីចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យរយៈពេលពីរខែ ។ អង្គជំនុំជម្រះបានកំណត់ទៀតថា ដោយសារស្ថានភាពសុខភាពដុយស្រួយ ជនជាប់ចោទ អៀង សារី បានបដិសេធមិនបោះបង់សិទ្ធិក្នុងការមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ ប៉ុន្តែជនជាប់ចោទអាចចូលរួមដោយប្រយោលតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ។ អៀង សារី ដែលធ្លាប់ស្ម័គ្រចិត្តលះបង់សិទ្ធិចូលរួមនៅក្នុងសវនាការស្តីពីការផ្តល់សក្ខីកម្មរបស់សាក្សីជាក់លាក់មួយចំនួនក្នុងអំឡុងពេលដែលខ្លួនអវត្តមានដោយសារត្រូវសម្រាកព្យាបាលជំងឺ បានសម្រេចចិត្តរក្សាសិទ្ធិក្នុងការចូលរួមសវនាការរបស់ខ្លួនវិញ ។ នៅថ្ងៃធ្វើសវនាការនីមួយៗ អៀង សារី ត្រូវបានបង្គាប់ឲ្យចូលរួម បន្ទាប់ពីឃុំខ្លួនខាងក្រោមសាលសវនាការ ។

ក្រុមមេធាវីការពារក្តី អៀង សារី បានប្តឹងសាទុក្ខទាំងចំពោះសេចក្តីសម្រេចនេះ និងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសំណើរបស់ខ្លួនសុំឲ្យមានការថតខ្សែអាត់សំឡេង ឬវីដេអូ នៅខណៈពេលដែល អៀង សារី កំពុងស្ថិតនៅក្នុងបន្ទប់ឃុំឃាំងខាងក្រោមសាលសវនាការ ។ ស្របពេលដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺជាតុលាការដំបូងដែលកំណត់អំពីការចូលរួមពីខាងក្រៅបន្ទប់សវនាការដោយសារបញ្ហាសុខភាព បញ្ហាទាំងពីរនេះបាននឹងកំពុងតែធ្វើឲ្យមានការចោទជាសំណួរទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយស្មើភាព ។

ក្រុមមេធាវីការពារក្តី អៀង សារី បានអះអាងថា ខ្លួនមានសិទ្ធិជាមូលដ្ឋានក្នុងការបង្កើតឲ្យមានកំណត់ត្រាស្តីពីគុណភាពក្នុងការចូលរួមរបស់កូនក្តីរបស់ខ្លួននិងធានាថា តុលាការមិនធ្វើសវនាការគ្រាន់តែបង្គ្រប់កិច្ច នៅពេលកូនក្តីរបស់ខ្លួនកំពុង «អស់កម្លាំងសម្រាន្តលក់ និងមិនសូវយល់ដឹងអំពីនីតិវិធីផ្សេងៗ ......យើងកំពុងតែធ្វើពើថា គាត់ពិតជាអាចតាមដាននីតិវិធីសវនាការបាន និងអាចជួយការពារខ្លួនដោយខ្លួនឯងបាន» ។ មេធាវីអះអាងថា ៖

> ចាប់តាំងពីវេជ្ជបណ្ឌិតរបស់តុលាការជួបពិនិត្យ អៀង សារី ត្រឹមតែពីរឬបីដងក្នុងមួយថ្ងៃ មិនទាន់មានការកត់ត្រាថាតើ អៀង សារី ដឹងខ្លួន សម្រាន្តលក់ មានអារម្មណ៍វិលមុខ ឬអាចតាមដាននីតិវិធីសវនាការនៅឡើយទេ ។ អង្គជំនុំជម្រះសាលាដំបូងនឹងមិនដឹងថា តើ អៀង សារី អាចតាមដាននីតិវិធីសវនាការបានឬយ៉ាងណានោះទេ ។ អង្គជំនុំជម្រះតុលាការកំពូលនឹងមិនមានកំណត់ត្រាដើម្បីយកមកសម្រេចថាតើអង្គជំនុំជម្រះសាលាដំបូងបានរំលោភលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយស្មើភាពរបស់ អៀង សារី ទេ ។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទាក់ទងនឹងសម្បទារបស់ជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ការថតខ្សែអាត់វីដេអូ ឬសំឡេង មិនមានភាពចាំបាច់ក្នុងការធានាថាជនជាប់ចោទ ត្រូវបានតាមដានយ៉ាងសមស្របនោះទេ នៅខណៈពេលដែលអង្គជំនុំជម្រះអាចពឹងផ្អែកលើការត្រួតពិនិត្យសុខភាពចំពោះលក្ខខណ្ឌសុខភាពរបស់ជនជាប់ចោទដោយមន្ត្រីពេទ្យ ។ ទោះបីជាយ៉ាងណា ក្រុមមេធាវីការពារក្តីបានសង្កត់ធ្ងន់ថា ការតាមដានចំពោះស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី

គឺពុំមានសមតុល្យចំពោះការត្រួតពិនិត្យថាតើជនជាប់ចោទមានសមត្ថភាពគ្រប់គ្រាន់ឬទេ នៅពេលដែលមានចំណុចខ្វះផ្ទុយពីសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយស្មើភាពគ្នាចំពោះមុខច្បាប់ និងថាតើជនជាប់ចោទអាចតាមដានបានរហូត ឬអាចតាមដានត្រឹមមួយចំហ ។

អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យមន្ត្រីសំណុំរឿងរបស់ក្រុមមេធាវីការពារក្តីអាចនៅចាំ មើល អៀង សារី ពីបន្ទប់ឃុំឃាំងខាងក្រោមបាន ប៉ុន្តែមិនត្រូវបានអនុញ្ញាតឲ្យចាកចេញទៅណាឡើយ ។ ដោយសារតែរបាយការណ៍ដំបូងរបស់ខ្លួនបានរាយការណ៍ថាជនជាប់ចោទបានសម្រាន្តលក់ក្នុងអំឡុងពេលសវនាការពេលព្រឹក ។ លោកស្រីចៅក្រម ខាតវ្រ៉ាយត៍ បានលើកឡើងថា ៖

> វាគឺជាចំណុចដែលគួរឲ្យចាប់អារម្មណ៍ដែលលោកបានលើកឡើងអំពីការសម្រាន្តលក់របស់ជនជាប់ចោទ អៀង សារី នៅក្នុងអំឡុងពេលសវនាការពេលព្រឹក ។ នេះគឺជាដំណោះស្រាយសាមញ្ញមួយសម្រាប់លោក គឺថា មន្ត្រីសំណុំរឿងរបស់លោកដាស់ជនជាប់ចោទឲ្យក្រោកឡើង......នៅពេលកំពុងសម្រាន្តលក់គឺគ្រាន់តែបញ្ជាក់ថា អៀង សារី មិនចាប់អារម្មណ៍ដោយផ្ទាល់ចំពោះសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ អង្គជំនុំជម្រះមានទំនុកចិត្តថា វេជ្ជបណ្ឌិតនឹងរាយការណ៍មកអង្គជំនុំជម្រះប្រសិនបើគាត់សង្កេតឃើញអ្វីមិនស្រួល ហើយ អៀង សារី មានភាពអស់កម្លាំងខ្លាំង ។

យោងលើរបាយការណ៍របស់មន្ត្រីសំណុំរឿងគ្រូពេទ្យបានបញ្ជាក់ទាក់ទងនឹងការចូលរួមក្នុងសវនាការរបស់ អៀង សារី ថាខ្លួនពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ អៀង សារី ក្នុងការចូលរួមក្នុងសវនាការទេ ។ អង្គជំនុំជម្រះបានធ្វើការហាមឃាត់ជាបន្តបន្ទាប់ មិនអនុញ្ញាតឲ្យមន្ត្រីសំណុំរឿងថតខ្សែអាត់អំពីការសន្ទនាជាមួយជនជាប់ចោទ ឬជាមួយគ្រូពេទ្យដែលព្យាបាលជនជាប់ចោទ ឬរបាយការណ៍សង្កេតរបស់គ្រូពេទ្យដោយពុំមានការអនុញ្ញាតជាមុនពីសំណាក់អង្គជំនុំជម្រះ ៖

គ្រប់ការសង្កេតបន្ថែមអំពីស្ថានភាពសុខភាពរបស់ អៀង សារី មិនថាផ្អែកលើការថតខ្សែអាត់ជាសំឡេង ឬជាវីដេអូ ការសង្កេតរបស់ក្រុមមេធាវីការពារក្តី អៀង សារី ត្រូវបានហាមឃាត់រហូតដល់មានការអនុញ្ញាតឲ្យមានការអនុវត្តដូច្នេះ ត្រូវបានដោះស្រាយដោយអង្គជំនុំជម្រះសាលាដំបូង ។

ឆ្លើយតបចំពោះសេចក្តីសម្រេចនេះ ក្រុមមេធាវីការពារក្តីនិងសហព្រះរាជអាជ្ញាបានដាក់នូវសំអាងហេតុជាលាយលក្ខណ៍អក្សររបស់ខ្លួន ។ សហព្រះរាជអាជ្ញាអះអាងថា ក្រុមមេធាវីការពារក្តីពុំបានបង្ហាញឲ្យបានច្បាស់លាស់នូវមូលដ្ឋានច្បាប់ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយស្មើភាពគ្នាចំពោះមុខច្បាប់សម្រាប់ការថតខ្សែអាត់សំឡេង ឬវីដេអូ របស់ អៀង សារី និងថាការធ្វើដូច្នេះគឺជាការរំលោភលើវិធានផ្ទៃក្នុងរបស់តុលាការដែលហាមឃាត់ភាគីមិនឲ្យធ្វើការស៊ើបអង្កេតស្វែងរកភស្តុតាងដោយខ្លួនឯងនិងធ្វើការចោទសួរសាក្សីសក្តានុពល ដោយរាប់បញ្ចូលទាំងបុគ្គលិកពេទ្យផង ។ ជាងនេះទៅទៀត ប្រតិចារិកប្រចាំថ្ងៃ និងឯកសារក្នុងសំណុំរឿងមិនត្រឹមតែបង្កើតឲ្យមានលក្ខណៈគ្រប់គ្រាន់នៃការធ្វើកំណត់ត្រានៃនីតិវិធីប៉ុណ្ណោះទេ ប៉ុន្តែសំណើឲ្យមានការថតខ្សែអាត់សំឡេង ឬវីដេអូ ក៏នឹងពុំបានផ្តល់ព័ត៌មានអ្វីជាប់ទាក់ទងដែរ ៖

> ការថតខ្សែអាត់ពុំមានកម្មវត្ថុអ្វីច្រើនទេ ប៉ុន្តែគឺដូចអ្វីដែលមានបង្ហាញនៅក្នុងសំណើរបស់ក្រុមមេធាវីការពារក្តីគឺគ្រាន់តែធ្វើឡើងជាមួយនឹងគោលបំណងជាក់លាក់ដែលមាននៅក្នុងចិត្ត និងប្រធានបទបឋមនៃការថតខ្សែអាត់ចង់ធ្វើឲ្យ អៀង សារី យល់ដឹងប្រសើរអំពីអ្វីដែលត្រូវបានថតទុក ហើយនឹងអនុវត្តឲ្យមានប្រយោជន៍បំផុត ។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនដែលទើបនឹងផ្សព្វផ្សាយនិងមានផ្តល់សំអាងហេតុពេញលេញលើបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ស្របជាមួយសហព្រះរាជអាជ្ញាដែលថាសំណើរបស់មេធាវីការពារក្តី គឺជាសំណើមួយដែលប្រមូលភស្តុតាងដោយខ្លួនឯង ខណៈពេលកំពុងមានការជំនុំជម្រះ លើជនជាប់ចោទហើយដែលផ្ទុយនឹងក្របខណ្ឌច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញ

ក្នុងតុលាការកម្ពុជា ។ ចំពោះការលើកឡើងពាក់ព័ន្ធនឹងសិទ្ធិរបស់មេធាវីការពារក្តី អង្គជំនុំជម្រះបានសម្រេចថា ការថតខ្សែអាត់អំពីការចូលរួមរបស់ អៀង សារី ពីចម្ងាយ គឺមិនមានភាពចាំបាច់ ហើយក៏ពុំជាប់ពាក់ព័ន្ធនឹងការការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការកត់ត្រាពេញលេញអំពីសម្បទាក្នុងការចូលរួមក្នុងសវនាការដែរ ។ ជំនួសមកវិញ ក្រុមមេធាវីការពារក្តីគួរតែយកចិត្តទុកដាក់ចំពោះស្ថានភាពសុខភាពរបស់ជនជាប់ចោទ ដែលជាសកម្មភាពសមស្របជាជាងការសង្កេតដែលធ្វើដោយសមាជិកនៃក្នុងមេធាវីការពារក្តីរបស់ជនជាប់ចោទ ។ ហេតុដូច្នេះ អង្គជំនុំជម្រះជាថ្មីម្តងទៀតបានហាមឃាត់មេធាវីការពារក្តីមិនឲ្យដាក់សំណើទាំងការថតខ្សែអាត់ ឬការសរសេរផ្ទាល់ដៃស្តីពីការសង្កេតចំពោះការចូលរួមរបស់ជនជាប់ចោទ អៀង សារី ពីបន្ទប់ឃុំឃាំងខាងក្រោមបន្ទប់សវនាការ ។

ដោយសារក្រុមមេធាវី អៀង សារី បានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងរួចហើយ អង្គជំនុំជម្រះតុលាការកំពូលនឹងចេញសេចក្តីសម្រេចចំពោះបញ្ហានេះ ។ ទោះបីជាយ៉ាងណា ដោយសារអណត្តិរបស់ខ្លួនមានភាពតូចចង្អៀតដើម្បីបើកសវនាការលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ វាអាចនឹងត្រូវសម្រេចថាពុំអាចទទួលយកបានរហូតដល់មានសាលក្រមលើបណ្តឹងឧទ្ធរណ៍ ។ **អាន ហាញឌុល**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធីសំឡេងអំពើប្រល័យពូជសាសន៍ ៈ យុត្តិធម៌ និងការអត់ឃ្មាន ដែលបានចាប់ផ្តើមផ្សាយនៅថ្ងៃអាទិត្យ ទី៣ ខែមីនា ឆ្នាំ២០១៣ ។

ប្រិយមិត្តដែលរស់នៅរាជធានីភ្នំពេញ និងនៅខេត្តអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំតាមរយៈ ៖

◆ វិទ្យុជាតិកម្ពុជា AM 918KHz រាជធានីភ្នំពេញ វេលាម៉ោង៩ព្រឹក និងម៉ោង៧និង៣០នាទីល្ងាច ។

◆ វិទ្យុខេត្តកំពត FM 93.25 MHz វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។

◆ វិទ្យុខេត្តព្រះវិហារ FM 99 MHz វេលាម៉ោង៧:៣០ព្រឹក និងម៉ោង៤រសៀល ។

◆ វិទ្យុខេត្តបាត់ដំបង FM 103.25 MHz វេលាម៉ោង៨ព្រឹក និងម៉ោង៤រសៀល ។



បន្ទប់ឃុំខ្លួនជនជាប់ចោទខាងក្រោមសាលសវនាការ (រូបថត ៖ អ.វ.ត.ក)

# កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (វគ្គទី១)
# សំឡេងយុត្តិធម៌ ៖ អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម
# ប្រធានបទ ៖ ប្រវត្តិខ្លះៗ និងការណែនាំ

*ជម្រាបសួរប្រិយមិត្តអ្នកស្តាប់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាទីមេត្រី!*

កម្មវិធី «សំឡេងយុត្តិធម៌៖ អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លានសម័យខ្មែរក្រហម» គឺជាកម្មវិធីថ្មីមួយដែលបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីពិភាក្សាអំពីការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមតាមន័យខ្លឹមសារច្បាប់ និងក្នុងបរិបទប្រវត្តិសាស្ត្រវាងអ្នកជំនាញផ្នែកច្បាប់ សាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ព្រមទាំងសិស្សានុសិស្ស ។ អ្នកផ្តល់ប្រឹក្សាទៅលើកម្មវិធីនេះ គឺមេធាវី វ៉េនឌុល ឌីហ្វាល់កូ ដែលបានចំណាយពេលវេលាចំនួនដប់ខែនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីសិក្សាស្រាវជ្រាវអំពីប្រធានបទនេះ ។ ជាដំបូង យើងខ្ញុំសូមលើកយកវគ្គទីមួយដែលស្តីអំពីប្រវត្តិ និងការណែនាំខ្លះៗទាក់ទងទៅនឹងការអត់ឃ្លានក្នុងរបបខ្មែរក្រហម និងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

ក្នុងអំឡុងនៃរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ការប្រព្រឹត្តអំពើហិង្សាដោយផ្ទាល់ មិនមែនជាបុព្វហេតុតែមួយគត់នៃការស្លាប់ និងទុក្ខវេទនារបស់ប្រជាជនកម្ពុជាទេ ។ លក្ខខណ្ឌរស់នៅយ៉ាងលំបាកគោកយ៉ាក ការអត់ឃ្លាន ការធ្វើការហួសកម្លាំង និងជំងឺដោយពុំមានការថែទាំត្រឹមត្រូវក៏ជាមូលហេតុចម្បងនៃទុក្ខវេទនា និងការស្លាប់របស់ប្រជាជនកម្ពុជាដែរ ។

ទោះបីជាយ៉ាងនេះក្តី ការពិភាក្សាអំពីបទឧក្រិដ្ឋដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមនៅឯតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមហាក់ដូចជាផ្តោតទៅលើតែបទឧក្រិដ្ឋដែលពាក់ព័ន្ធទៅនឹងអំពើហិង្សាលើរូបរាងកាយ ដូចជា ការធ្វើទារុណកម្ម និងការសម្លាប់ជាទ្រង់ទ្រាយធំ ។ បច្ចុប្បន្ន តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម កំពុងតែជំរុញដំណើរការកាត់សេចក្តីនៅក្នុងសំណុំរឿង ០០២ប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហមចំនួនបីរូប ដែលនៅរស់រានមានជីវិតរួមមាន នួន ជា, អៀង សារី និង ខៀវ សំផន ។ ចំណែកឯជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដកចេញពីសំណុំរឿង០០២ ដោយតុលាការរកឃើញថា ជនជាប់ចោទ អៀង ធីរិទ្ធ ពុំមានកាយសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមដំណើរការកាត់សេចក្តីនៅក្នុងសំណុំរឿង០០២ និងដោយសារតែជនជាប់ចោទរូបនេះមានជំងឺវង្វេងវង្វាន់ ។ មេដឹកនាំខ្មែរក្រហមទាំងបីរូបផ្សេងទៀតនៅក្នុងសំណុំរឿង០០២ មានវ័យជាង៨០ឆ្នាំ ហើយសុខភាពរបស់មេដឹកនាំទាំងបីរូបហាក់ដូចជាទ្រុឌទ្រោម ។ នៅពេលថ្មីៗនេះ មេដឹកនាំទាំងបីរូបត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យដើម្បីពិនិត្យសុខភាពដោយមូលហេតុសុខភាពចុះខ្សោយ ។ ជំងឺដែលជនជាប់ចោទទាំងបីរូបកំពុងប្រឈមមុខរួមមាន ជំងឺផ្លូវដង្ហើម សម្ពាធឈាមឡើងខ្ពស់ និងជំងឺរលាកទងសួតជាដើម ។ បញ្ហាសុខភាពរបស់ជនជាប់ចោទទាំងបីរូបអាចជាហេតុផលមួយដែលធ្វើឲ្យតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមផ្តោតការយកចិត្តទុកដាក់ទៅលើតែឧក្រិដ្ឋកម្មដែលពុំសូវមានលក្ខណៈសាំញ៉ាំ ក្នុងគោលបំណងធ្វើយ៉ាងណាដើម្បីជំរុញឲ្យការកាត់ទោសមេដឹកនាំខ្មែរក្រហមប្រព្រឹត្តទៅមុខបានឆាប់រហ័ស ។ ប្រសិនបើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ធ្វើការកាត់សេចក្តីទៅលើបញ្ហាអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមប្រហែលជាត្រូវចំណាយពេលវេលាច្រើនក្នុងការប្រមូលភស្តុតាង ចាំបាច់ផ្សេងៗ និងការពិភាក្សាផ្នែកច្បាប់ផ្សេងៗដែលពាក់ព័ន្ធ ។ ប្រសិនបើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមចំណាយពេលវេលាកាន់តែយូរ នោះឱកាសដែលថាជនជាប់ចោទទាំងបីរូបអាចស្លាប់បាត់បង់ជីវិតមុនការប្រកាសសាលក្រមអាចនឹងកើតមាន ។

ដោយយោងតាមហេតុផលពេលវេលា បទឧក្រិដ្ឋទាក់ទងនឹងលក្ខខណ្ឌរស់នៅដ៏លំបាក និងការអត់ឃ្លានក្នុងរបបខ្មែរក្រហមពុំត្រូវបានអើពើ ពីព្រោះការដាក់បន្ទុកចំពោះបទឧក្រិដ្ឋទាក់ទងនឹងគុក អំពើហិង្សា ការសម្លាប់ និងវណ្ណៈសាកសពមានលក្ខណៈងាយស្រួលជាងភាពសាហាវដែលកើតឡើងនៅក្នុងខ្លួនមនុស្សដោយសារការរួមបញ្ចូលគ្នានៃលក្ខខណ្ឌរស់នៅ ។ ការផ្តោតតែទៅលើបទឧក្រិដ្ឋដោយអំពើហិង្សា គឺជាបែបផែននៃតុលាការអន្តរជាតិ និងច្រើនតែអាចកើតឡើងដោយសារតែបទឧក្រិដ្ឋដោយអំពើហិង្សាទាំងនោះត្រូវនឹងគំរូច្បាប់ដែលមានស្រាប់ ។ បទឧក្រិដ្ឋដោយអំពើហិង្សាទាំងឡាយ គឺជាបែបផែនដែលមានលក្ខណៈងាយស្រួលបង្ហាញឲ្យឃើញជាងបទឧក្រិដ្ឋទាក់ទងទៅនឹងលក្ខខណ្ឌរស់នៅជាទូទៅ ។ ឧទាហរណ៍ នៅក្នុងករណីខ្មែរក្រហម ការចងក្រងឯកសារនៃរបបខ្មែរក្រហមបានបង្ហាញយ៉ាងច្បាស់ថា មេដឹកនាំខ្មែរក្រហមបានផ្តល់សិទ្ធិឲ្យមានការ "កម្ទេច" អ្នកណាដែលចាត់ទុកថាជាសត្រូវផ្នែកនយោបាយ ហើយជនបទនៃប្រទេសកម្ពុជារាយពាសពេញទៅដោយវណ្ណៈសាកសពនៃជនរងគ្រោះដែលត្រូវបានសម្លាប់ដែលផ្តល់ភ័ស្តុតាងដ៏មានឥទ្ធិពល ។

ក៏ប៉ុន្តែ នៅពេលដែលនិយាយដល់បទឧក្រិដ្ឋដែលផ្តោតទៅលើការអត់ឃ្លាន បុព្វហេតុដែលនាំឲ្យហេតុការណ៍នេះកើតឡើង និងការទទួលខុសត្រូវជាលក្ខណៈបុគ្គល អាចមានលក្ខណៈស្មុគស្មាញនិងពិបាកចោទប្រកាន់ ពីព្រោះការស្លាប់ដោយសារការអត់ឃ្លានមានការជាប់ពាក់ព័ន្ធរវាងផលិតកម្មម្ហូបអាហារ គោលនយោបាយរបស់រដ្ឋាភិបាលជម្លោះប្រដាប់អាវុធ និងការរីករាលដាលនៃជំងឺឆ្លង ។

មកទល់នឹងពេលនេះ គ្មានសាលាក្តីឬតុលាការព្រហ្មទណ្ឌអន្តរជាតិណាមួយបានធ្វើការចោទប្រកាន់ ដោយដាក់លាក់ទៅលើបុព្វហេតុនៃការអត់ឃ្លានឡើយ ។ ក៏ប៉ុន្តែ តុលាការស្រដៀងគ្នានេះជាច្រើនបានខ្វល់ខ្វាយពីបញ្ហាអត់ឃ្លាន ឬទទួលស្គាល់អំពីភាពខុសច្បាប់នៃការបង្អត់អាហារចំពោះប្រជាជនទូទៅ ។ ម្យ៉ាងទៀត នៅពេលដែលការអត់ឃ្លានត្រូវបានដាក់បង្ខំចំពោះនរណាម្នាក់ ការអត់ឃ្លាននោះអាចជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋកម្មអន្តរជាតិដូចជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម ។

លទ្ធភាពនៃការចោទប្រកាន់បទឧក្រិដ្ឋនៃការអត់ឃ្លានមានការពិបាក ។ ប្រសិនបើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមសម្រេចដាក់បញ្ចូលបញ្ហាអត់ឃ្លានទៅក្នុងសំណុំរឿងរបស់តុលាការសំណុំរឿង ០០២អាចជាករណីមួយដែលប្រសើរសម្រាប់ការដាក់បញ្ចូលបញ្ហាអត់ឃ្លាននេះ ពីព្រោះជនជាប់ចោទទាំងបីរូបនៅក្នុងសំណុំរឿង០០២នេះ រួមមាន នួន ជា, អៀង សារី និង ខៀវ សំផន ដែលជាអតីតមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់បំផុត ត្រូវបានដឹងឮជាទូទៅថាមានអំណាចថ្នាក់ជាតិដែលបានជួយជ្រោមជ្រែងក្នុងការបង្កើត និងលើកកម្ពស់គោលនយោបាយមួយដែលបង្កឲ្យមានគ្រោះអត់ឃ្លានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ប៉ុន្តែ ការដាក់បញ្ចូលបញ្ហាអត់ឃ្លានទៅក្នុងសំណុំរឿងប្រហែលជាមិនអាចកើតមាននោះទេ ពីព្រោះជនជាប់ចោទទាំងបីរូបនៅក្នុងសំណុំរឿង០០២នេះ កំពុងស្ថិតក្នុងវ័យជរា និងមានសុខភាពទ្រុឌទ្រោម ។ ដូច្នេះហើយ តុលាការបានសម្រេចចោទប្រកាន់ជនជាប់ចោទទាំងបីអំពីបទឧក្រិដ្ឋផ្សេងៗដែលទាក់ទងនឹងអំពើហិង្សាលើរូបរាងកាយ ។

សរុបមកវិញ កម្មវិធីវិទ្យុនេះ គឺជាកម្មវិធីដំបូងបង្អស់នៅក្នុងប្រភេទនេះ ដែលស្វែងយល់អំពីផល ប៉ះពាល់ផ្លូវច្បាប់ដែលអាចធ្វើបាននៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទាក់ទិននឹងការអត់ឃ្លានដល់ស្លាប់ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។ កម្មវិធីនេះនឹងពិនិត្យមើលថាតើការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមកើតឡើងយ៉ាងដូចម្តេច និងស្វែងយល់អំពីគោលនយោបាយដឹកនាំសំខាន់ៗរបស់ខ្មែរក្រហមដែលបណ្តាលឲ្យកើតមានការអត់ឃ្លាន ។ លើសពីនេះទៅទៀត កម្មវិធីនេះនឹងដកស្រង់ប្រភពច្បាប់ ដែលអាចយោងបាន និងឧបសគ្គផ្នែកច្បាប់ដែលអាចចោទឡើងនៅពេលដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមធ្វើការស្វែងយល់អំពីរឿងអត់ឃ្លាននៅក្នុងសំណុំរឿង០០២ ។

*តទៅនេះយើងខ្ញុំសូមនាំប្រិយមិត្តអ្នកស្តាប់ទៅពិនិត្យមើលចំណុចមួយគឺ ខ្មែរក្រហម និងគោលនយោបាយសំខាន់ៗពាក់ព័ន្ធនឹងការអត់ឃ្លាន*

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់អាចចងចាំបានយ៉ាងច្បាស់ពីបទពិសោធផ្ទាល់ខ្លួន ទាក់ទងនឹងការស្រេកឃ្លាននិងការបង្អត់អាហារ ។ ប៉ុន្តែ មានតែមនុស្សមួយចំនួនតូច

ប៉ុណ្ណោះដែលយល់អំពីមូលហេតុនៃការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម និងគោលនយោបាយជាតិដែលត្រូវទទួលខុសត្រូវ ។

នៅពេលដែលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៥ ផលិតផលស្រូវនៅក្នុងតំបន់មួយចំនួនត្រូវបានកាត់បន្ថយយ៉ាងខ្លាំងអស់រយៈពេលប្រាំឆ្នាំ ពីព្រោះតែសង្គ្រាមស៊ីវិលដែលកើតឡើងពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ។ ក៏ប៉ុន្តែ ក៏មានតំបន់មួយចំនួននៅក្នុងប្រទេសកម្ពុជាមិនត្រូវបានបំផ្លិចបំផ្លាញដោយសារសង្គ្រាម ដូចជា តំបន់នៅជុំវិញខេត្តបាត់ដំបងក្នុងភាគពាយ័ព្យ ដែលចាត់ទុកថាជាឆ្នាំងបាយរបស់ប្រទេសកម្ពុជា និងជាតំបន់ដែលផលិតស្រូវច្រើនបំផុតរបស់ប្រទេសកម្ពុជា ។

របបខ្មែរក្រហមបានប្រញាប់ប្រញាល់ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងពីទីប្រជុំជនានាឲ្យទៅរស់នៅជាកសិករធ្វើស្រែចម្ការនៅទីជនបទ ។ អៀង សារី បានធ្វើការបកស្រាយដោយផ្ទាល់ជាផ្លូវការមួយថា បុព្វហេតុនៃការជម្លៀសគឺដោយសារតែមិនមានស្បៀងនៅក្នុងទីក្រុងភ្នំពេញ ។ ខ្មែរក្រហម បានអះអាងថា បញ្ហាស្បៀងអាហារនឹងត្រូវបានដោះស្រាយតាមរយៈការបង្កើនផលិតផលស្បៀង ដោយការបញ្ជូនប្រជាជនកម្ពុជាទាំងអស់ទៅធ្វើការនៅសហករណ៍ ។ ប្រជាជនជាច្រើននាក់ត្រូវបានបញ្ជូនទៅកាន់ខេត្តបាត់ដំបង ព្រោះរបបខ្មែរក្រហមជឿជាក់ថា តំបន់នៅជុំវិញខេត្តបាត់ដំបងអាចផ្តល់ទិន្នផលស្រូវបានច្រើនជាងមុនប្រសិនបើបន្ថែមកម្លាំងធ្វើការ ។ ខ្មែរក្រហមបានអះអាងថា ការជំរុញវិស័យកសិកម្មអាចជួយស្តារដល់ការបាត់បង់ជំនួយស្បៀងអាហារ បន្ទាប់ពីខ្មែរក្រហមបានបណ្តេញទីភ្នាក់ងារបរទេសទាំងអស់ចេញពីប្រទេស រួមទាំងអង្គការមនុស្សធម៌ផ្សេងៗដែលផ្តល់ជំនួយស្បៀងអាហារ ។ គម្រោងការរបស់ខ្មែរក្រហមមួយនេះបានទទួលបរាជ័យ ហើយលក្ខខណ្ឌរស់នៅក្នុងតំបន់ទាំងនោះ ដូចជានៅខេត្តបាត់ដំបងមានសភាពអាក្រក់ខ្លាំងបំផុត ពោលគឺជន់ជោរទៅដោយអ្នកជម្លៀស និងទទួលរងនូវការដាក់កម្រិតឲ្យផលិតផលស្រូវឲ្យបានទិន្នផលខ្ពស់ ។

របបថ្មីនេះបានប្រកាសថា កម្ពុជាអាចអនុវត្តផែនការ "មហាលោតផ្លោះមហាអស្ចារ្យ" ផ្នែកកសិកម្មបានយ៉ាងលឿនជាជាងការធ្វើបដិវត្តន៍ទៅតាមពេលវេលាកំណត់ជាក់លាក់ ។ មេដឹកនាំខ្មែរក្រហមបានបញ្ជាក់នៅក្នុងកិច្ចប្រជុំបក្សថា គោលដៅបដិវត្តន៍ និងភាពបរិសុទ្ធស្អាតស្អំនៃរបបខ្មែរក្រហមអាចសម្រេចបានតាមរយៈការបង្កើនទិន្នផលស្រូវជាមធ្យមនៅក្នុងប្រទេសឲ្យបានបីដងច្រើនជាងទិន្នផលដែលធ្លាប់សម្រេចបានកាលពីសម័យមុន ពោលគឺកាលពីមុនធ្លាប់ធ្វើបានមួយតោនក្នុងមួយហិកតា ពេលនេះត្រូវសម្រេចឲ្យបានបីតោនក្នុងមួយហិកតា ។

គម្រោងក្នុងការបង្កើនទិន្នផលស្រូវយ៉ាងសន្ធឹកសន្ធាប់នេះត្រូវបានរៀបរាប់យ៉ាងលម្អិតនៅក្នុង "គម្រោងផែនការបួនឆ្នាំ" របស់ខ្មែរក្រហមដែលរៀបចំឡើងនៅឆ្នាំ១៩៧៦ ប៉ុន្តែមិនទាន់បានបោះពុម្ពផ្សាយនៅឡើយទេ ។ នៅក្នុងគម្រោងផែនការបួនឆ្នាំខ្មែរក្រហមមានគម្រោងសម្រេចឲ្យបានទិន្នផលស្រូវ និងឲ្យលើសពីបីតោនក្នុងមួយហិកតាដែលជាទិន្នផលមធ្យមនៅទូទាំងប្រទេសក្នុងរយៈពេលពីរឬបីឆ្នាំ ។

របបខ្មែរក្រហមមានគម្រោងប្រើប្រាស់ស្រូវមួយភាគធំដែលគ្រោងនឹងផលិត ដើម្បីយកទៅចិញ្ចឹមកងទ័ពបដិវត្តន៍របស់ខ្លួន និងប្រើប្រាស់ជាប្រភពចាំបាច់សម្រាប់ចំណូលផ្នែកពាណិជ្ជកម្ម ដែលនឹងត្រូវយកទៅផ្គត់ផ្គង់គ្រប់គោលដៅបដិវត្តន៍ទាំងអស់ ។ នៅក្នុងឯកសារមេដឹកនាំខ្មែរក្រហមបានបញ្ជាក់ថា ផលិតផលស្រូវគឺជាកត្តាក្នុងការផ្គត់ផ្គង់កងទ័ព និងការពារកម្ពុជាប្រជាធិបតេយ្យទប់ទល់នឹងប្រទេសវៀតណាម ។ ហេតុដូច្នេះ ការដាំដុះស្រូវត្រូវបានមើលឃើញថា ជាទិសដៅសំខាន់ចាំបាច់នៃការការពារជាតិ ។

របបខ្មែរក្រហមមិនអើពើទៅនឹងផលលំបាករាប់មិនអស់ដែលនឹងជួបប្រទះនោះទេ រួមមានកង្វះខាតហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក កង្វះខាតគ្រឿងចក្រទំនើប កម្លាំងជំនាញ និងថ្នាំសម្លាប់សត្វល្អិតដែលចាំបាច់ក្នុងការសម្រេចឲ្យបាននូវការបង្កើនទិន្នផលស្រូវដ៏ច្រើនសន្ធឹកសន្ធាប់ ។ ផ្ទុយទៅវិញ មេដឹកនាំខ្មែរក្រហមបានដាក់បទបញ្ជាថា ប្រទេសជាតិនឹងកសាងប្រព័ន្ធធារាសាស្ត្រដោយខ្លួនឯង និងអភិវឌ្ឍវិធីសាស្ត្រថ្មីដែលប្រសើរជាងមុនក្នុងការដាំដុះស្រូវតាមរយៈស្មារតីបដិវត្តន៍ពិតប្រាកដ ។

ខ្មែរក្រហមបានដាក់បទបញ្ជាថា ដើម្បីប្រយុទ្ធប្រឆាំងនឹងការលំបាកទាំងអស់កម្លាំងពលកម្មរបស់ប្រជាជនត្រូវតែសម្រុក "ប្រយុទ្ធ" នឹងផលិតកម្មស្រូវ ដូចជា ការវាយច្បាំងប្រយុទ្ធក្នុង

សមរភូមិដែរ ។ តម្រូវការមិនច្បាស់លាស់របស់ថ្នាក់ដឹកនាំខ្មែរក្រហម និងកង្វះខាតគ្រឿងបរិក្ខារ បានបណ្តាលឲ្យប្រជាជនកម្ពុជាទាំងអស់ត្រូវធ្វើការងារធ្ងន់ជាច្រើនម៉ោង និងជារៀងរាល់ថ្ងៃនៅទូទាំងប្រទេស ។

ការគណនារបស់មេដឹកនាំខ្មែរក្រហម ដែលថាទិន្នផលស្រូវជាមធ្យមបីតោនក្នុងមួយហិចតាអាចសម្រេចទៅបាននៅទូទាំងប្រទេស គឺជាការសន្មតមួយដែលមិនត្រូវត្រឹម ។ ប៉ុន្តែ មេដឹកនាំខ្មែរក្រហមនៅតែជំរុញអនុវត្តផែនការរបស់ខ្លួន និងបដិសេធមិនទទួលស្គាល់កំហុសណាមួយ ឬបន្ថយជំហានបដិវត្តន៍របស់ខ្លួនឡើយ ។ ផ្ទុយទៅវិញ ខ្មែរក្រហមបានបង្កើនកម្រិតទិន្នផលស្រូវលើចំនួនដែលមិនអាចសម្រេចបានទៅហើយនោះ ចំពោះតំបន់ដែលដីមានជីជាតិល្អ ដូចជា តំបន់នៅជុំវិញខេត្តបាត់ដំបង តម្រូវឲ្យផលិតស្រូវឲ្យបានប្រាំតោនក្នុងមួយហិកតាក្នុងគោលបំណងដើម្បីបង្គ្រប់នូវឱនភាពផលិតផលស្រូវដែលបានគ្រោងទុក ។

កម្ពុជាប្រជាធិបតេយ្យបានប្រមូលយកស្រូវយ៉ាងច្រើនសន្ធឹកសន្ធាប់ពីជង្រុកស្រូវរបស់សហករណ៍នៅទូទាំងប្រទេសទៅផ្គត់ផ្គង់កងទ័ព និងធ្វើពាណិជ្ជកម្មជាមួយកូរ៉េខាងជើង និងចិន ។ ខ្មែរក្រហមបានបង្កើតគណៈនីពាណិជ្ជកម្មបរទេសមួយនៅទីក្រុងហុងកុង ដែលផ្តល់ថវិកាដោយរដ្ឋាភិបាលចិន ។ ជំនួយហិរញ្ញប្បទាននេះគឺជាការចាំបាច់ពីព្រោះតែខ្មែរក្រហមបានហាមប្រាមការប្រើប្រាស់លុយទាំងស្រុង ។

ខណៈពេលដែលខ្មែរក្រហមកំពុងតែបញ្ជូនប្រជាជនឲ្យទៅធ្វើស្រែចម្ការជាច្រើនម៉ោង ដើម្បីផលិតស្រូវឲ្យបដិវត្តន៍របស់ខ្លួន ខ្មែរក្រហមក៏បានដាក់កម្រិតយ៉ាងតឹងរ៉ឹងទៅលើសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាជននៅក្នុងសហករណ៍ ។

បន្ទាប់ពីបានឡើងកាន់អំណាច ខ្មែរក្រហមបានប្រកាសហាមប្រាមកម្មសិទ្ធិឯកជនគ្រប់រូបភាពនៅក្នុងប្រទេស ។ ហេតុដូច្នេះ អ្វីៗទាំងអស់ រួមមាន អាហារ បន្លែ ផ្លែឈើព្រៃ ព្រមទាំងសត្វព្រៃ គឺជាកម្មសិទ្ធិរបស់អង្គការបដិវត្តន៍ ។ គ្រោះអត់ឃ្លានដែលបានកើតឡើងនៅដំណាក់កាលដំបូងនៅក្នុងប្រទេសកម្ពុជាមិនសូវជាមានសភាពធ្ងន់ធ្ងរប៉ុន្មាននោះទេ ពីព្រោះប្រជាជនអាចទៅរកប្រភពចំណីអាហារច្រើនក្រាស់ក្រៃនៅក្នុងព្រៃ តាមទីជនបទ និងព្រៃស្រោង ។ ក៏ប៉ុន្តែ នៅក្រោមរបបខ្មែរក្រហម អ្នកដែលអត់ឃ្លានត្រូវប្រឈមមុខនឹងការដាក់ឃុំឃាំង វាយដំ ឬត្រូវសម្លាប់ចោលដោយគ្រាន់តែចាប់ត្រីមួយពីបឹង ឬបេះដូងមួយផ្លែពីដើមដែលខ្លួនដាំយកមកហូប ឬឲ្យក្រុមគ្រួសារ ។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានបង្កើតឲ្យមានការហូបរួមក្នុងសហករណ៍នៅទូទាំងប្រទេសកម្ពុជា ហើយខ្មែរក្រហមបានហាមការដាំដុះដំណាំកសិផលក្បែរផ្ទះដែលប្រជាជនកម្ពុជាតែងតែដាំសម្រាប់ផ្គត់ផ្គង់នៅក្នុងគ្រួសារដែលជាអាហារបន្ទាប់បន្សំអស់រយៈពេលជាច្រើនសតវត្សរ៍កន្លងមក ។ នេះមានន័យថា ទីកន្លែងតែមួយគត់ដែលប្រជាជនកម្ពុជាអាចហូបបាន គឺមានតែនៅរោងបាយសហករណ៍តែមួយប៉ុណ្ណោះ ។ ហេតុដូច្នេះ អ្នកធ្វើពលកម្មពឹងផ្អែកទាំងស្រុងទៅលើរបបអាហារដែលខ្មែរក្រហមផ្តល់ឲ្យដើម្បីចិញ្ចឹមជីវិត ។ ក៏ប៉ុន្តែរបបអាហារដែលទទួលបាននេះមានចំនួនតិចជាងចំនួនដែលមនុស្សម្នាក់ៗត្រូវការទៅទៀត ជាពិសេសសម្រាប់អ្នកដែលត្រូវបង្ខំឲ្យធ្វើការងារធ្ងន់ធ្ងរជាប់រហូតច្រើនម៉ោង ។

គោលនយោបាយរិតត្បិតរបស់ខ្មែរក្រហមទាំងអស់នេះគឺជាមូលហេតុមួយដែលបង្កឲ្យមានគ្រោះអត់ឃ្លានរហូតដល់បាត់បង់អាយុជីវិតប្រជាជនកម្ពុជាអស់ជាច្រើននៅក្នុងរបបខ្មែរក្រហម ។ ការអត់ឃ្លាននេះបានសម្លាប់មនុស្សរាប់ពាន់នាក់ ហើយនៅតែបន្តកាន់តែធ្ងន់ធ្ងរថែមទៀតរហូតដល់ពេលដែលរបបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩ ។

មិនដល់បួនឆ្នាំផង ប្រជាជនកម្ពុជារាប់សែននាក់បានស្លាប់ដោយការអត់ឃ្លាន ឬបុព្វហេតុផ្សេងទៀតដែលពាក់ព័ន្ធនឹងការអត់ឃ្លាន ។ អ្នកស្រាវជ្រាវជាន់ខ្ពស់អំពីរបបខ្មែរក្រហមបានប៉ាន់ប្រមាណថា ប្រជាជនកម្ពុជាប្រហែលជាពាក់កណ្តាល ឬ៨សែននាក់ នៃចំនួនប្រជាជនដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមមិនបានស្លាប់ដោយរងការប្រើអំពើហិង្សានោះទេ ។ ពោលគឺប្រជាជនទាំងអស់នេះបានស្លាប់ដោយសារលក្ខខណ្ឌរស់នៅមិនសមរម្យជាមនុស្ស ការធ្វើការហួសកម្លាំង ការអត់ឃ្លាន និងជំងឺ ។

ប្រិយមិត្តអ្នកស្តាប់ជាទីមេត្រី សូមក្រឡេកមើលចំណុចមួយទៀតគឺ ឧក្រិដ្ឋកម្មនៃការអត់ឃ្លានក្នុងរបបខ្មែរក្រហម និងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

ប្រជាជនកម្ពុជារាប់សែននាក់ ដែលបានស្លាប់ដោយសារការអត់ឃ្លាន ការធ្វើការហួសកម្លាំង និងជំងឺនៅក្នុងរបបខ្មែរក្រហម គឺជារឿងមួយដែលមិនអាចប្រកែកបាន ។ ប៉ុន្តែ នៅមានភាពស្រពេចស្រពិលត្រង់មួយចំនួនដែលចោទឡើងថា តើទង្វើរបស់មេដឹកនាំខ្មែរក្រហមដែលបង្កឲ្យមានការអត់ឃ្លានរហូតដល់ស្លាប់នេះ អាចចោទជាបទឧក្រិដ្ឋដើម្បីផ្តន្ទាទោសក្រោមច្បាប់របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរឬយ៉ាងណា ។

នៅក្នុងបទសម្ភាសន៍មួយចំនួន ជនជាប់ចោទទាំងបីរូបនៅក្នុងសំណុំរឿង០០២បានលើកឡើងថា ការស្លាប់របស់ប្រជាជនកម្ពុជានៅក្នុងរបបខ្មែរក្រហម និងបញ្ហាដែលទាក់ទងនឹងលក្ខខណ្ឌរស់នៅផ្សេងៗ ដូចជាការអត់ឃ្លាន មិនមែនជាកំហុសរបស់ថ្នាក់ដឹកនាំមជ្ឈិមនោះទេ ។ មេដឹកនាំទាំងបីរូបបានលើក ឡើងថា បញ្ហាដែលកើតឡើងដោយការអត់ឃ្លាន គឺជាលទ្ធផលនៃសង្រ្គាមស៊ីវិល និងជាកំហុសឆ្គងរបស់កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម ។

ជាឧទាហរណ៍ អៀង សារី និង ខៀវ សំផន ធ្លាប់បានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈថា ហេតុផលមួយដែលប្រជាជនត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥ គឺដោយសារតែពុំមានស្បៀងអាហារផ្គត់ផ្គង់គ្រប់គ្រាន់នៅក្នុងទីក្រុង ហើយប្រទេសជាតិទាំងមូលកំពុងតែប្រឈមមុខនឹងការអត់ឃ្លានរួចទៅហើយ ពីព្រោះសង្រ្គាមស៊ីវិល និងរបប លន់ នល់ ។

អ្នកស្រាវជ្រាវជាន់ខ្ពស់និងអ្នកជំនាញផ្នែកច្បាប់ជាច្រើនរូបបានបញ្ជាក់ថា នៅក្នុងកាលៈទេសៈមួយចំនួន ក្រុមឬបុគ្គលដែលមានអំណាចដែលបានបង្កឲ្យមានការស្លាប់ដោយការអត់ឃ្លានអាចនឹងដាក់ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មនេះ ។ ខណៈពេលដែលមិនមានបទឧក្រិដ្ឋអន្តរជាតិដ៏ជាក់លាក់ណាមួយពាក់ព័ន្ធនឹងការអត់ឃ្លាន ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលកើតឡើងដោយការអត់ឃ្លានអាចដាក់បញ្ចូលទៅក្នុងសណ្ឋាននៃឧក្រិដ្ឋកម្មសង្រ្គាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬអំពើប្រល័យពូជសាសន៍ ដែលបទឧក្រិដ្ឋទាំងបីខាងលើនេះត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២ ។

ដោយឡែក នៅក្នុងបរិបទរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺជាប្រភពដ៏សក្តិសមបំផុតមួយក្នុងការចោទប្រកាន់ដែលទាក់ទងទៅនឹងការអត់ឃ្លាន ។ ប៉ុន្តែ ការទទួលបាននូវការផ្តន្ទាទោសពីបទឧក្រិដ្ឋនៃការអត់ឃ្លាននៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអាចនឹងមានការលំបាក ពីព្រោះកង្វះខាតផ្នែកទម្រង់ច្បាប់ជាក់លាក់ និងបញ្ហាភ័ស្តុតាង ព្រមទាំងកត្តានៃបុព្វហេតុដែលបានពិភាក្សាពីខាងដើម ។ ជាក់ស្តែង នៅក្នុងដំណើររបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមសព្វថ្ងៃ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានធ្វើការផ្តោតសំខាន់ទៅលើតែឧក្រិដ្ឋកម្មដែល ពាក់ព័ន្ធនឹងអំពើហិង្សានៅក្នុងសំណុំរឿង០០១ និង០០២ ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមប្រហែលជាមិនបញ្ចូលប្រធានបទដទៃទៀតទៅក្នុងដំណើរកាត់ក្តីនាពេលខាងមុខនេះទេ ។ ដូច្នេះហើយ កម្មវិធីវិទ្យុនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ជាព័ត៌មានទូទៅទាក់ទងនឹងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម និងបញ្ហាពាក់ព័ន្ធផ្នែកច្បាប់ផ្សេងៗ ដើម្បីផ្តល់ជាវេទិកាមួយសម្រាប់ប្រជាជនកម្ពុជាអាចបង្ហាញទស្សនៈយល់ឃើញរបស់ខ្លួនពាក់ព័ន្ធនឹងការអត់ឃ្លាន និងដំណើរការស្វែងរកយុត្តិធម៌ ។

*ជាបន្តទៅនេះ យើងខ្ញុំសូមលើកយកអត្ថបទមួយក្រោមចំណងជើងថា "គ្មានទេពាក្យថាអត់ឱន" ចេញផ្សាយដោយទស្សនាវដ្តី "ស្វែងរកការពិត" របស់មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ១៤៩ ខែឧសភា ឆ្នាំ២០១២ សរសេរដោយ ទាវ សារៈមុនិន្ទ*

អង្គុយជជែកលេងនៅលើផ្ទះកន្តាំងពីរខ្នង ខ្ញុំកត់សម្គាល់ឃើញថា ផ្ទះធំទូលាយនេះមានតែលោកយាយ និងលោកតាពីរនាក់ប៉ុណ្ណោះរស់នៅ ។ លោកយាយ អិត ណាន់ អាយុ៦៩ឆ្នាំ និងលោកតា សោម ឌុល អាយុ៧០ឆ្នាំ ។ យាយតា មានកូនបួននាក់ គឺស្រីបីនាក់ និងប្រុសម្នាក់ ។

កូនស្រីទាំងបីមានគ្រួសារ និងបែកទៅរស់នៅផ្ទះផ្សេង ចំណែកកូនប្រុសពៅបានទៅធ្វើការនៅខេត្តឆ្ងាយ ហើយរយៈពេលពីរអាទិត្យ ឬមួយខែទើបមកលេងផ្ទះម្តង ។

សព្វថ្ងៃយាយតារស់នៅស្រុកព្រះស្តេច ខេត្តព្រៃវែង ។ អំឡុងពេលខ្ញុំជជែកលេងជាមួយគាត់ពីរឿងរ៉ាវផ្សេងៗ ស្រាប់តែទឹកមុខរបស់ អិត ណាន់ ប្រែស្រងូតស្រងាត់មួយរំពេច បន្ទាប់ពីខ្ញុំបានសួរគាត់ទាក់ទងទៅនឹងរបបខ្មែរក្រហម ឬដែលប្រជាជនខ្មែរ

ទូទៅហៅថារបប ប៉ុល ពត នោះ ។ គាត់បានសម្លឹងមើលមកខ្ញុំបន្តិចទៅដោយទុក្ខព្រួយ រួចនិយាយថា គាត់មិនដែលភ្លេចទេរបបបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ ភាពឈឺផ្សាវេទនាទាំងឡាយដែលបានជួបប្រទះ វានៅតែដិតដាមនៅក្នុងចិត្តជានិច្ច ទោះបីជារឿងរ៉ាវទាំងនេះកន្លងផុតទៅជាងសាមសិបឆ្នាំហើយក៏ដោយ ។ អិត ណាន់ បន្តថា គាត់មិនអាចអត់ឱនឲ្យអ្នកទាំងនោះបានទេ ចំពោះទង្វើទាំងឡាយដែលបានធ្វើមកលើរូបគាត់ ។

ឈោងដៃយកក្រមាមកជូតមុខ ហើយងាកសម្លឹងទៅរកវាលស្រែខៀវស្រងាត់នៅមុខផ្ទះ អិត ណាន់ បានរៀបរាប់ពីជីវិតដ៏លំបាកនៅក្នុងរបបកាប់សម្លាប់នោះថា នៅឆ្នាំ១៩៧៥ ខ្មែរក្រហមកាន់កាប់កម្ពុជាទាំងស្រុង គាត់និងកូនតូចៗពីរនាក់ (ស្រីម្នាក់ ប្រុសម្នាក់) ព្រមទាំងប្តី មិនត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិទេ ដោយហេតុថា គាត់ជាប្រជាជនមូលដ្ឋាន ប៉ុន្តែគ្រួសារគាត់ត្រូវធ្វើការដូចអ្នកថ្មីដែរ ។ នៅសហករណ៍ភូមិពោធិ៍ ណាន់ ត្រូវបានអង្គការចាត់តាំងឲ្យដកស្ទូង ចំណែកប្តីទៅអារឈើតាមភូមិស្រុកនានា ក្នុងតំបន់២៤ ខេត្តព្រៃវែង ។

នៅឆ្នាំ១៩៧៦ និងនៅដើមឆ្នាំ១៩៧៧ ការហូបចុកនៅភូមិពោធិ៍នេះមិនសូវជាពិបាកប៉ុន្មានទេ ព្រោះមនុស្សម្នាក់ទទួលបានស្រូវប្រាំមួយតាំក្នុងមួយថ្ងៃ ប៉ុន្តែក្រោយមកក៏មានការផ្លាស់ប្តូរមកហូបរួមនៅក្នុងសហករណ៍ ដោយថ្ងៃខ្លះមានតែរបបបបររាវពោតស្ងោរ ឬដំឡូងម្នាក់មួយដុំតែប៉ុណ្ណោះ ។ គាត់ឆ្ងល់ថា ស្រូវធ្វើបានច្រើនសន្ធឹកសន្ធាប់ ហេតុអ្វីបានជាអង្គការឲ្យប្រជាជនហូបបបរ ឬដំឡូង ដូច្នេះតើអង្គការដឹកស្រូវដែលគាត់ខំធ្វើទាំងយប់ទាំងថ្ងៃនេះទៅណា? គាត់បានដកដង្ហើមធំ ហើយងាកមករកខ្ញុំដោយពោលថា គាត់ចាំមិនភ្លេចទេ ខ្មែរក្រហមធ្វើឲ្យកូនប្រុសជាទីស្រឡាញ់របស់គាត់ស្លាប់ វាហាក់ដូចជាយកកាំបិតមកចាក់កាត់ផ្តាច់បេះដូងគាត់អ៊ីចឹងដែរ ។

ណាន់ រំឭកថា ប្រហែលក្នុងអំឡុងពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ កូនប្រុសពៅដែលមានអាយុទើបប្រាំមួយឆ្នាំប៉ុណ្ណោះ ឈឺគ្រុនក្តៅ គាត់បានទៅសុំថ្នាំពីពេទ្យភូមិដែលមានចម្ងាយមិនដល់ ១០០ម៉ែត្រផង ពីផ្ទះរបស់គាត់ ប៉ុន្តែពេលទៅដល់ទីនោះ អ្នកកាន់ថ្នាំឆ្លើយថា មិនមានសិទ្ធិបើកថ្នាំឲ្យទេដូច្នេះពេលព្រឹកចាំមកសុំពេទ្យទៅ ។ ណាន់ ត្រឡប់មកវិញទាំងក្តីអស់សង្ឃឹម ហើយដោយសារកូនគាត់មានជំងឺកាន់តែធ្ងន់ធ្ងរ ទើបស្លាប់នៅពេលនោះទៅ ចំណែក ណាន់ និងប្តី បានត្រឹមតែយំ និងឈឺចាប់ប៉ុណ្ណោះ ។ ក្រោយពីមរណភាពកូន ណាន់ និងប្តី ខិតខំធ្វើការងារមិនហ៊ានឈប់ ឬខ្ជិលច្រអូសទេ ព្រោះពេលមានអ្នកឈឺម្តងៗ អង្គការតែងតែចោទថា នោះមានជំងឺសតិអារម្មណ៍ ឬជាគ្រុនទន្សាយទៅវិញ ។ ណាន់ បញ្ជាក់ថា អង្គការឲ្យគាត់ហូបតិច ប៉ុន្តែឲ្យធ្វើការច្រើន បើមិនធ្វើទេ អង្គការមិនចែកបាយ ឬបបរឲ្យហូបទេ ។ រាល់ថ្ងៃ ណាន់ ត្រូវធ្វើជាមនុស្សខ្វាក់ គរ ថ្លង់ និងប្រឹងប្រែងធ្វើការដើម្បីផ្គាប់ចិត្តអង្គការ ដើម្បីរក្សាជីវិតគាត់ កូន និងប្តី រហូតដល់វៀតណាមរំដោះនៅឆ្នាំ១៩៧៩ ។

អិត ណាន់ និយាយមួយៗថា ខ្មែរក្រហមមិនដែលធ្វើទុក្ខបុកម្នេញមកលើរាងកាយអ្វី ក្រៅពីដាក់ផែនការឲ្យធ្វើការងារនោះទេ ប៉ុន្តែអ្វីដែលធ្វើឲ្យខ្លួនឈឺចាប់នោះ គឺការបាត់បង់កូនជាទីស្រឡាញ់របស់គាត់ កាត់ផ្តាច់មនោសញ្ចេតនាបងប្អូន ប្តីប្រពន្ធ ហើយការធ្វើបាបផ្លូវចិត្តរបស់គាត់ហាក់ដូចជាស្រមោលដែលអន្ទោលតាមប្រាណគាត់ជាងសាមសិបឆ្នាំមកហើយ ។ ភាពឈឺចាប់ទាំងអស់នេះ វានៅតែជាស្នាមខ្មៅដិតនៅក្នុងចិត្តរបស់គាត់ដែលមិនអាចលុប



បាន ហើយក៏គ្មានពាក្យថា អត់ទិនចំពោះខ្មែរក្រហមទាំងនោះដែរ សម្រាប់រូបគាត់ ទោះបីរឿងរ៉ាវនេះកន្លងផុតទៅជាច្រើនឆ្នាំហើយក៏ដោយ ។

សព្វថ្ងៃនេះ ថ្វីបើ អិត ណាន់ និងប្តីមានវ័យជរាបន្តិចទៅហើយក៏ពិតមែន ប៉ុន្តែគាត់មានការចាប់អារម្មណ៍ពីដំណើរការនៃការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ គាត់សំណូមពរឲ្យតុលាការពន្លឿនការកាត់ទោសនេះឲ្យបានឆាប់ ហើយស្នើតុលាការដាក់ទោសឲ្យធ្ងន់ធ្ងរទៅលើមេដឹកនាំខ្មែរក្រហម ព្រោះប្រជាជនខ្មែរច្រើនណាស់បានស្លាប់ក្នុងអំឡុងពេលគ្រប់គ្រងរបស់ខ្មែរក្រហម ។

អិត ណាន់ បានបញ្ជាក់ទៀតថា ការរៀនប្រវត្តិសាស្ត្រខ្មែរក្រហម មានសារសំខាន់ណាស់សម្រាប់កូនចៅជំនាន់ក្រោយឲ្យយល់ដឹង និងចងចាំដើម្បីទប់ស្កាត់កុំឲ្យរបបនេះកើតមានឡើងម្តងទៀត ។

ប្រិយមិត្តអ្នកស្តាប់ជាទីមេត្រី ការផ្សាយនៅពេលក្រោយៗទៀត យើងនឹងពិនិត្យមើលទៅលើបញ្ហាផ្លូវច្បាប់ជាក់លាក់ផ្សេងៗពាក់ព័ន្ធនឹងសំណុំរឿង០០២របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ នៅក្នុងកម្មវិធីផ្សាយជារៀងរាល់លើកនឹងមានយករឿងរ៉ាវផ្ទាល់ខ្លួនរបស់អ្នករស់រានមានជីវិតពីការអត់ឃ្លានមកចែករំលែកទាក់ទងនឹងបទពិសោធនៃការស្រេកឃ្លាន និងការបង្អត់អាហារនៅក្នុងរបបខ្មែរក្រហម ។ នៅចុងកម្មវិធីផ្សាយមួយលើកៗនឹងមានការឆ្លើយសំណួររបស់ប្រិយមិត្តអ្នកស្តាប់ដែលមានចម្ងល់ទាក់ទងនឹងការអត់ឃ្លាន និងដំណើរការកាត់ទោស នៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រិយមិត្តអ្នកស្តាប់ដែលបានតាមដានស្តាប់ការផ្សាយរបស់យើងខ្ញុំ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសូមថ្លែងអំណរគុណចំពោះស្ថានីយវិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ ដែលបានផ្តល់ស៊ីឌីយោថតសំឡេង ។

ប្រសិនបើប្រិយមិត្តអ្នកស្តាប់ចង់ចូលរួមផ្តល់ជាមតិយោបល់ សួរសំណួរ ឬចម្ងល់ផ្សេងៗ នៅក្នុងកម្មវិធី សូមសរសេរជាលិខិតផ្ញើមកកាន់លោក ម៉ែន ពិចិត្រ អ្នករៀបចំកម្មវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានអាសយដ្ឋានផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ឬប្រអប់សំបុត្រលេខ ១១១០ រាជធានីភ្នំពេញ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣-២១១-៨៧៥ ឬទូរសារលេខ ០២៣-២១០-៣៥៨ ។

**រ៉េនដុល ឌីហ្វាល់កូ, ម៉ែន ពិចិត្រ និង លន់ ដាលីន**

## សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម





មជ្ឈមណ្ឌលឯកសារកម្ពុជាគ្រោងនឹងបោះពុម្ពឈ្មោះអ្នកស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមកយើងបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាន រួចមកហើយ ។ ប្រសិនបើ លោកយាយ លោកតា អ៊ំ ពូ មីង ទូន ហាកឹម ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងសៀវភៅនេះ សូមទាក់ទងមកយើងខ្ញុំឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

សូមទាក់ទងមក បណ្ឌិត អេង គុកថាយ ៖ ០១២ ៩៥៥ ៨៥៨

អ៊ីមែល ៖ truthkokthay@dccam.org, www.dccam.org

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាម៖ *http://dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

- ◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**
- ◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺជាឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យព័ត៌មានសាធារណៈ» មានផ្តល់ជូននូវសេវាចម្បងបីយ៉ាង ៖

**១) បណ្ណាល័យ ៖** នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ ៖** មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃ ។

**៣) ក្រុមការងារផ្នែកតុលាការ ៖** ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ិរ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ **សូមអរគុណ ។**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិ ដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនិងថ្នាក់រៀននេះ សូមទាក់ទង ស៊ីវ សាវីណា តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ។

◆ **ទីកន្លែង ៖ អាគារ "ក" ជាន់លើ**

◆ **ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការសោយព្រះទិវង្គតរបស់ព្រះមហាវីរក្សត្រ គឺជាការសាកល្បង ឯកភាពជាតិរឹងមាំជាងមុន

ប្រជាពលរដ្ឋកម្ពុជាភាគច្រើនយល់ឃើញថា ការសោយព្រះទិវង្គតរបស់ព្រះមហាវីរក្សត្រ សម្តេចព្រះ នរោត្តម សីហនុ ជាទីស្រលាញ់របស់ខ្លួន គឺជាការបាត់បង់ដ៏ធំបំផុតមួយរបស់ជាតិ ។ ស្ត្រីម្នាក់មកពីខេត្តកំពង់ឆ្នាំងបាននិយាយថា “ការសោយព្រះទិវង្គតរបស់ព្រះអង្គ ដូចជាការបាត់បង់ឪពុកម្តាយ ដែលទុកឲ្យគ្រួសារទាំងមូលបាត់បង់ភាពកក់ក្តៅ” ។ ទោះជាអនាគតខាងមុខនឹងទៅជាយ៉ាងណាក្តី អវត្តមានរបស់ព្រះមហាវីរក្សត្រ សម្គាល់ចំណុចរបត់ជាប្រវត្តិសាស្ត្រមួយទៀតនៃនយោបាយរបស់កម្ពុជា ។ ប្រទេសកម្ពុជាបានទទួលរងគ្រោះពីសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ ការទម្លាក់គ្រាប់បែក អំពើប្រល័យពូជសាសន៍ជម្លោះនយោបាយ អំពើហិង្សា និងការជ្រៀតជ្រែកពីបរទេសដែលបានដាក់ទម្ងន់និងមានឥទ្ធិពលមកលើវប្បធម៌និងនយោបាយខ្មែរ ។ រយៈពេល២២ឆ្នាំ នៃរយៈកាលអន្តរកាលនៃប្រទេសក្រោយជម្លោះមួយនេះ ការសោយព្រះទិវង្គតរបស់ព្រះមហាវីរក្សត្រ នរោត្តម សីហនុ បានបង្ហាញអំពីពិសោធដ៏សំខាន់មួយទៀតនៃឯកភាពជាតិកម្ពុជា ស្ថេរភាពនយោបាយ សន្តិភាពជានិរន្តរ៍ និងការផ្សះផ្សាជាតិ ដែលជាសេចក្តីប៉ងប្រាថ្នាចម្បងរបស់ព្រះមហាវីរក្សត្រ និងប្រជាពលរដ្ឋទូទាំងប្រទេស ។

នៅល្ងាចថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៣ ប្រជាពលរដ្ឋកម្ពុជានៅទូទាំងប្រទេស បានជូនព្រះរាជដំណើរចុងក្រោយបង្អស់ចំពោះព្រះមហាវីរក្សត្ររបស់ខ្លួនដែលប្រហែលជាព្រះមហាក្សត្រជាអាទិទេពចុងក្រោយបង្អស់របស់កម្ពុជា ។ ខណៈពេលដែលប្រជាពលរដ្ឋរាប់សែននាក់បានប្រមូលផ្តុំគ្នានៅសួនច្បារមុខព្រះបរមរាជវាំង និងនៅកន្លែងផ្សេងៗទៀតនៅជុំវិញបរិវេណនោះ ដោយសារហេតុផលសន្តិសុខ ប្រជាពលរដ្ឋទាំងអស់ មិនអនុញ្ញាតឲ្យចូល



ជនជាតិភាគតិចចាមចូលពិធីដង្ហែព្រះបរមសពព្រះមហាវីរក្សត្រ នរោត្តម សីហនុ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៣



ទៅជិតវាលព្រះមេរុ ដែលនៅទីនោះព្រះបរមសពត្រូវបានតម្កល់សម្រាប់ថ្វាយព្រះភ្លើង ។ ប្រជាពលរដ្ឋមួយចំនួនបានអង្គុយនៅលើថ្នល់ និងបួងសួងថ្វាយព្រះវិញ្ញាណក្ខន្ធព្រះមហាវីរក្សត្រ ខណៈដែលប្រជាពលរដ្ឋផ្សេងទៀតដើរដង្ហែនៅតាមផ្លូវ ។ សិស្សស្ម័គ្រចិត្តមួយក្រុមមកពីវិទ្យាល័យទួលស្វាយព្រៃ បានដើររើសសំរាមនៅតាមផ្លូវ ហើយក្រុមស្ម័គ្រចិត្តផ្សេងៗទៀត បានផ្តល់អាហារនិងភេសជ្ជៈជូនប្រជាពលរដ្ឋដែលមកពីតាមបណ្តាខេត្តឆ្ងាយៗ ។ ពាក្យស្លោកនៅលើអាវរបស់ក្រុមសិស្សស្ម័គ្រចិត្ត មានសេចក្តីជាអាទិ៍ថា ៖ «ខ្ញុំប្តេជ្ញាមិនឲ្យទឹកដីសម្តេចតា មានសំរាមដោយសារតែខ្ញុំ ចំណែកលោកអ្នកវិញ? គោរពតាមព្រះរាជបណ្តាំរបស់សម្តេចតា យើងប្តេជ្ញាខិតខំសិក្សា ដើម្បីឲ្យខ្មែរមានឈ្មោះល្បីលើឆាកអន្តរជាតិ ។ ព្រះរាជបំណងសម្តេចតា ប្រាថ្នាកូនចៅខ្មែរសាមគ្គីគ្នា ដើម្បីអភិវឌ្ឍប្រទេសជាតិ» ។ ពាក្យស្លោកដ៏សាមញ្ញនិងការងារស្ម័គ្រចិត្តទាំងនេះ ជានិមិត្តរូបនៃមនោសញ្ចេតនាដ៏អស្ចារ្យនៃការរួបរួមគ្នាដែលព្រះមហាវីរក្សត្របានព្យាយាមបំផុសគំនិតនេះទៅដល់ប្រជាពលរដ្ឋខ្មែរទាំងអស់ ។

មានចម្លើយចម្រុះគ្នាចំពោះសំណួរដែលថា តើអនាគតប្រទេសកម្ពុជានឹងទៅជាយ៉ាងណា ប្រសិនបើគ្មានវត្តមានរបស់ព្រះមហាវីរក្សត្រ ។ ព្រះតេជគុណមួយអង្គ ដែលនិមន្តមកពីខេត្តសៀមរាប និងបានមកភ្នំពេញអស់រយៈពេលបួនថ្ងៃមកហើយនោះ ដើម្បីចូលរួមនៅក្នុងព្រះរាជពិធីបុណ្យជាប្រវត្តិសាស្ត្រនេះ បានមានព្រះសង្ឃដីកាថា ព្រះមហាវីរក្សត្រមិនត្រឹមតែជាអ្នកនយោបាយដ៏មានឥទ្ធិពលបំផុតប៉ុណ្ណោះទេ ប៉ុន្តែ ព្រះអង្គថែមទាំងជាអ្នកការទូតប្រកបដោយបទពិសោធន៍យ៉ាងខ្ពស់ ។ ព្រះតេជគុណបានពណ៌នាអំពីទំនាក់ទំនងយ៉ាងល្អរបស់ព្រះមហាវីរក្សត្រជាមួយប្រមុខរដ្ឋនិងថ្នាក់ដឹកនាំជាតិជាច្រើន ដែលទំនាក់ទំនងនេះបានធ្វើឲ្យព្រះអង្គក្លាយជាមេដឹកនាំដ៏មានសារសំខាន់ ។ វត្តមានរបស់ព្រះមហាវីរក្សត្រ ប្រសិនបើព្រះអង្គនៅមានព្រះជន្ម នឹងនាំមកនូវសេចក្តីគោរព ដែលប្រទេសផ្សេងៗមានមកលើប្រទេសកម្ពុជា ។ ព្រះមហាវីរក្សត្រអាចទទួលបាននូវសេចក្តីស្រលាញ់និងការគោរពពីសំណាក់ប្រមុខរដ្ឋ និងថ្នាក់ដឹកនាំពិភពលោកជាច្រើនទោះបីជាក្រោយពេលដែលព្រះអង្គចូលព្រះនិវត្តន៍ពីកិច្ចការនយោបាយនៅក្នុងឆ្នាំ២០០៤ ហើយបានដាក់រាជថ្វាយព្រះរាជបុត្រារបស់ព្រះអង្គ គឺព្រះមហាក្សត្របច្ចុប្បន្ន ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ។

អ្នករត់ម៉ូតូឌុបម្នាក់មកពីខេត្តតាកែវ បាននិយាយថា លោកមានការស្តាយស្រណោះព្រះមហាវីរក្សត្រជាងឪពុកម្តាយរបស់លោកទៅទៀត ។ លោកបានពណ៌នាអំពីការគោរព ដែលបរទេសមានចំពោះព្រះមហាវីរក្សត្រ ទោះបីជានៅក្នុងប្រទេសប្រជាជនមួយចំនួនមានការគោរពតិចតួចចំពោះព្រះអង្គ ។ លោកបានប៉ាន់ស្មានផ្ទាល់ខ្លួនថា ប្រជាពលរដ្ឋកម្ពុជាប្រហែលតែពីរភាគរយប៉ុណ្ណោះ ដែលមានការគោរពតិចតួចចំពោះព្រះមហាវីរក្សត្រ ដោយសារតែទំនាក់ទំនងរបស់ព្រះអង្គជាមួយខ្មែរក្រហមនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ។ ទោះជាយ៉ាងនេះក្តី សម្រាប់អ្នករត់ម៉ូតូឌុបរូបនេះ ដែលជាអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមមួយរូបដែរនោះ ព្រះមហាវីរក្សត្រគឺជានិមិត្តរូបនៃសន្តិភាព និងឯកភាពជាតិ ។ លោកបានសង្កត់បញ្ជាក់ថា វត្តមានរបស់ព្រះមហាវីរក្សត្រ អាចបង្រួបបង្រួមកូនចៅរបស់ព្រះអង្គ ឲ្យមានការអត់ឱនឲ្យគ្នា ដើម្បីទទួលបានសន្តិភាព ។

មុនពេលចាកចេញ អ្នករត់ម៉ូតូឌុបរូបនេះបានសន្និដ្ឋានថា «ប្រសិនបើយើងមានការរួបរួមគ្នា មិនមានប្រទេសណាមួយហ៊ានមើលងាយយើង ហើយប្រទេសជាតិនឹងមានការអភិវឌ្ឍ» ។ យោបល់របស់លោកនេះគឺស្របទៅនឹងព្រះរាជបំណងចុងក្រោយរបស់ព្រះមហាវីរក្សត្រ ដែលព្រះអង្គចង់ទតឃើញកម្ពុជាមួយដែលរួបរួមគ្នាទាំងគោលបំណងនិងស្មារតី ។

**ឌី ខាំបូលី**

# ចាមមូស្លីមនៅម៉ាឡេស៊ីផ្តល់ទស្សនៈពីការយាងចូលទិវង្គតរបស់ព្រះមហាវីរក្សត្រ នរោត្តម សីហនុ

ការសោយទិវង្គតរបស់ព្រះមហាវីរក្សត្រ នរោត្តម សីហនុ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ បណ្តាលឲ្យមានប្រតិកម្មប្លែកៗគ្នាជាច្រើនក្នុងចំណោមជនជាតិចាមមូស្លីមនៅប្រទេសម៉ាឡេស៊ី ។ ជនជាតិចាមមូស្លីមនៅម៉ាឡេស៊ីមួយចំនួននិយាយថា ការចងមេត្រីភាពរបស់សម្តេច នរោត្តម សីហនុ ជាមួយនឹងខ្មែរក្រហមនេះហើយដែលជំរុញឲ្យខ្លួនភៀសខ្លួនពីប្រទេសកម្ពុជាមកកាន់ប្រទេសម៉ាឡេស៊ី ។ ផ្ទុយទៅវិញ មនុស្សមួយចំនួនទៀតយល់ឃើញថា ការសោយទិវង្គតនេះគឺជាការបាត់បង់ដ៏ធំធេងណាស់សម្រាប់ប្រទេសជាតិទាំងមូល ។

ជនជាតិចាមមូស្លីមមួយភាគធំរស់នៅក្នុងប្រទេសកម្ពុជា និងមួយចំនួនទៀតរស់នៅតាមសហគមន៍តូចៗនៅតាមប្រទេសនានាដូចជា វៀតណាម ម៉ាឡេស៊ី ថៃ ឡាវ ឥណ្ឌូនេស៊ី សហរដ្ឋអាមេរិក បារាំង និងប្រទេសជាច្រើនទៀត ។ នៅប្រទេសម៉ាឡេស៊ី ជនជាតិចាម មូស្លីមរស់នៅជាសហគមន៍នៅក្នុងរដ្ឋចំនួន១១ ដែលស្ថិតនៅប៉ែកខាងលិចនៃប្រទេសនេះ ។

ជនជាតិចាមដែលរស់នៅក្នុងប្រទេសម៉ាឡេស៊ីភាគច្រើនសុទ្ធតែមានប្រភពមកពីប្រទេសកម្ពុជា ។ មូលហេតុដែលនាំឲ្យអ្នកទាំងនោះត្រូវបង្ខំចិត្តឲ្យមកតាំងទីលំនៅថ្មីដោយសារតែរត់គេចពីសង្គ្រាមស៊ីវិល ការធ្វើទុកបុកម្នេញរបស់ក្រុមកុម្មុយនីស្តខ្មែរក្រហមនៅក្នុងអំឡុងទសវត្សរ៍៧០ រួមទាំងអស្ថេរភាពនយោបាយជាងពីរទសវត្សរ៍បន្ទាប់មក ។ នៅប្រទេសម៉ាឡេស៊ី អ្នកទាំងអស់នោះភាគច្រើនរកចំណូលប្រចាំថ្ងៃដោយសារការលក់សម្លៀកបំពាក់ម្ហូបអាហារ និងជំនួញតូចតាចៗផ្សេងៗទៀត ។ អ្នកទាំងនោះត្រូវបានស្គាល់ថា «អូរាំង ខាំបូឌា» ដែលមានន័យជាភាសាខ្មែរថា «អ្នកដែលមកពីប្រទេសខ្មែរ ឬជនជាតិកម្ពុជា» ឬមួយត្រូវបានស្គាល់ថា «ម៉ាឡាយូ ចម្ប៉ា» ជាជាងនិយាយថា អ្នកទាំងនោះជាជនជាតិចាម ជ្វា ឬខ្មែរអ៊ីស្លាម ។ ពាក្យ «ខ្មែរអ៊ីស្លាម» ត្រូវបានសម្តេច នរោត្តម សីហនុ ដាក់ឲ្យនៅក្នុងទសវត្សរ៍៦០ ក្នុងគោលបំណងបង្រួបបង្រួមជាតិ និងធ្វើសមាហរណកម្មអ្នកកាន់សាសនាអ៊ីស្លាមទៅក្នុងសង្គមកម្ពុជាឲ្យកាន់តែស្និតរមួត ។

ជនជាតិចាមមូស្លីម បានដឹងដំណឹងពីការសោយទិវង្គតរបស់ព្រះមហាវីរក្សត្រ នរោត្តម សីហនុ និងព្រះរាជពិធីបុណ្យព្រះរាជសពរបស់ព្រះអង្គតាមកញ្ចក់ទូរទស្សន៍ និងតាមសារព័ត៌មាននានា ។ លើសពីនេះទៀត រឿងរ៉ាវមួយចំនួនរបស់ព្រះអង្គ និងព្រះរាជវង្សានុវង្សរបស់ព្រះអង្គក៏ត្រូវបានបោះពុម្ពផ្សាយនៅក្នុងសារព័ត៌មាន



ក្នុងស្រុកក្នុងប្រទេសម៉ាឡេស៊ីដែរ ។ ជាក់ស្តែង អូម៉ា រ៉ុម្លាស់ បានទិញអត្ថបទ កាសែតយកមកអាន ព្រមទាំងចែកចាយទៅឲ្យក្រុមគ្រួសាររបស់គាត់ដើម្បីឲ្យដឹងព័ត៌មាននេះ ។ រ៉ុម្លាស់ បានចាកចេញពីប្រទេសកម្ពុជាតាមទូកដែលបើកដោយពូរបស់គាត់ (អតីតមេបញ្ជាការកងម៉ារីនសម័យ លន់ នល់) ដែលបានចេញដំណើរនៅមុនពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញប្រមាណជាពីរបីម៉ោងនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ។ បីថ្ងៃក្រោយមក អ្នកទាំងនោះបានទៅដល់ទឹកដីនៃប្រទេសម៉ាឡេស៊ី ហើយត្រូវបានស្វាគមន៍យ៉ាងរាក់ទាក់និងផ្តល់កន្លែងស្នាក់នៅដោយអង្គការសុខុមាលភាពអ៊ីស្លាមនៃប្រទេសម៉ាឡេស៊ី ***(PERKIM)*** ព្រមទាំងទទួលការស្វាគមន៍ដោយរដ្ឋាភិបាលម៉ាឡេស៊ីដែរ ។

ប្រជាជនដែលកើតក្នុងជំនាន់ រ៉ុម្លាស់ ទទួលស្គាល់ភាពរុងរឿងរបស់ប្រទេសកម្ពុជានៅក្នុងទសវត្សរ៍៥០និង៦០ ប៉ុន្តែអ្នកទាំងនោះបានរំឭកតិចតួចបំផុតគុណបំណាច់របស់សម្តេច នរោត្តម សីហនុ ទៅលើការដណ្តើមយកឯករាជ្យបានពីប្រទេសបារាំងនៅក្នុងឆ្នាំ១៩៥៣ ។ ទន្ទឹមនឹងនេះ មនុស្សមួយចំនួនឆ្ងល់ថា ហេតុអ្វីបានជា សម្តេច នរោត្តម សីហនុ ចងមេត្រីភាពជាមួយខ្មែរក្រហមនៅទសវត្សរ៍៧០ទៅវិញ ។ ហាជី ហ៊ោហ្ស៊ី អ៊ីស្មាអែល បានចាកចេញពីប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៨០ ហើយមកដល់ប្រទេសម៉ាឡេស៊ីនៅក្នុងឆ្នាំ១៩៨៣ ដែលសព្វថ្ងៃ ជាអ្នកជំនួញមួយរូបនៅក្នុងរដ្ឋប៉េណាំង បានគួរបញ្ជាក់ថា ពិតជាចង់ដឹងថា តើមូលហេតុអ្វីបានជាសម្តេច នរោត្តម សីហនុ ហៅប្រជាជនទាំងអស់ឲ្យរត់ចូលព្រៃ ហើយចុងក្រោយបែរជាខ្មែរក្រហមធ្វើទុក្ខបុកម្នេញទៅវិញ ។ ដូចគ្នាដែរ ហាជី សាហ្វី រស់នៅក្នុងរដ្ឋកាឡាន់តាន់ ក៏មានចម្ងល់អំពីមូលហេតុដែលធ្វើឲ្យសម្តេច នរោត្តម សីហនុ គាំទ្រខ្មែរក្រហម នៅខណៈពេលដែលក្រុមខ្មែរក្រហមទាំងនោះធ្លាប់ធ្វើការប៉ះបោរប្រឆាំងនឹងព្រះអង្គនៅក្នុងទសវត្សរ៍៦០ ។ ហាជី ហ៊ោហ្ស៊ី និង ហាជី សាហ្វី បានសង្កត់ធ្ងន់ថា ពួកគាត់ពិតជាពិបាកក្នុងការស្វែងរកដំណោះស្រាយឲ្យបានសមស្របទៅនឹងចំណោទបញ្ហានេះ ។

ម៉ារីយម រស់នៅក្នុងរដ្ឋចូហូរ រៀបរាប់ថា គាត់មិនយល់ពីគោលនយោបាយក្នុងសម័យនោះទេ ប៉ុន្តែគាត់មានអារម្មណ៍ថា ឥទ្ធិពលនៃការចងមេត្រីភាពនេះបានធ្វើឲ្យរូបគាត់ និងអ្នកដទៃជាច្រើនរូបទៀត ចាកចេញពីប្រទេសទៅរកសិទ្ធិជ្រកកោននៅក្នុងប្រទេសមួយផ្សេងទៀត ។

បើទោះជាយ៉ាងនេះក្តី ហ្សាលីហាស់ ជាជាងកាត់ដេរនៅក្នុងរដ្ឋកាឡាន់តាន់ ដែលបានចាកចេញពីប្រទេសកម្ពុជានៅដើមទសវត្សរ៍៩០ និងជាមនុស្សម្នាក់ក្នុងចំណោមក្រុមចុងក្រោយដែលបានចាកចេញមុនពេលជំរឺជំរំវ៉ាទីង (មានជាប់ព្រំប្រទល់រដ្ឋប៉ាហាំង និងរដ្ឋត្រាំងហ្កានូ) ត្រូវបានបិទក្នុងឆ្នាំ១៩៩៣ យល់ឃើញថាការសោយទិវង្គតរបស់សម្តេច នរោត្តម សីហនុគឺជាបាត់បង់ដ៏ធំធេងមួយសម្រាប់ប្រទេសកម្ពុជា ដោយសារតែព្រះអង្គបានកសាងស្នាព្រះហស្ត និងភាពជោគជ័យជាច្រើនសម្រាប់ប្រជាជនកម្ពុជានៅក្នុងសម័យសង្គមរាស្ត្រនិយម ។ ហ្សាលីហាស់ និយាយថា នេះគឺជារឿងដ៏សំខាន់ដែលធ្វើឲ្យយើងចងចាំរូបព្រះអង្គ បើទោះជាព្រះអង្គធ្លាប់ប្រព្រឹត្តកំហុសខ្លះពីអតីតកាលក៏ដោយ ។

លើសពីនេះទៀត មនុស្សជាច្រើននៅតែគោរពព្រះអង្គចំពោះការលះបង់ដ៏ធំធេងចំពោះប្រទេសជាតិ ។ ហ្សាការីយ៉ា រស់នៅក្នុងរដ្ឋម៉ាឡាកា បាននិយាយថា សម្តេច នរោត្តម សីហនុជាក្សត្រមួយអង្គដែលគួរឲ្យគោរព ហើយយើងគួរតែផ្តល់នូវតម្លៃខ្ពស់ចំពោះព្រះអង្គ បើទោះជាព្រះអង្គបានលាចាកលោកនេះក៏ដោយ ។

សរុបមកវិញ ការសោយទិវង្គតរបស់សម្តេច នរោត្តម សីហនុ ពិតជាមានអត្ថន័យសម្រាប់ជនជាតិចាមមូស្លីមដែលរស់នៅក្នុងប្រទេសម៉ាឡេស៊ី ។ បើទោះបីខណៈនោះ ជនមួយចំនួនមិនពេញចិត្តទៅលើស្នាព្រះហស្ត ក៏ដូចជាកំហុសមួយចំនួនដែលព្រះអង្គបានប្រព្រឹត្តដែលប៉ះពាល់ដល់អាយុជីវិតរបស់ប្រជាជន ប៉ុន្តែមនុស្សជាច្រើនពិតជាផ្តល់តម្លៃខ្ពស់ ការគោរព និងកោតសរសើរចំពោះកេរ្តិ៍ព្រះនាមរបស់ព្រះមហាក្សត្ររូបនេះ ។ អ្នកទាំងនោះគិតថា ការពិចារណាតែទៅលើចំណុចអវិជ្ជមានចំពោះការដឹកនាំរបស់ព្រះអង្គធ្វើឲ្យយើងមិនបានគិតទៅដល់ការលះបង់កន្លងមករបស់ព្រះអង្គចំពោះប្រទេសជាតិដែលរួមបញ្ចូលទាំងស្នាព្រះហស្តរបស់ព្រះអង្គនៅក្នុងប្រទេសកម្ពុជាអំឡុងទសវត្សរ៍៦០ និងអំឡុងពេលក្រោយៗមកទៀត ។

**ស្វូ ហ្សារីណា**

# ដំណើរជីវិតខ្ញុំ

ខ្ញុំកើតក្នុងខែធ្នូ ឆ្នាំ១៩៣៥ នៅភូមិព្រែកឫស្សី ស្រុកស្ទឹងកណ្តាល ខេត្តកណ្តាល ដែលមានចម្ងាយដប់គីឡូម៉ែត្រភាគខាងត្បូងទីក្រុងភ្នំពេញ ។ បន្ទាប់ពីសម័យសង្គ្រាមលោកលើកទីពីរ នៅក្នុងអំឡុងឆ្នាំ១៩៤៩ ខ្ញុំបានចូលរៀននៅសាលាមួយក្នុងទីក្រុងភ្នំពេញ ។ ក្នុងឆ្នាំ១៩៥៩ ខ្ញុំបានចូលរៀនក្នុងសាលាពេទ្យ ហើយក៏បានបញ្ចប់ការសិក្សានៅឆ្នាំ១៩៦៦ ។ មិនយូរប៉ុន្មាន ខ្ញុំបានចូលបម្រើការងារនៅមន្ទីរពេទ្យឯកជនមួយដែលបានចុះកុងត្រាជាមួយនឹងកងកម្លាំងយោធាខ្មែរកាលពីជំនាន់នោះ ។

ក្នុងឆ្នាំ១៩៧០ ខ្ញុំត្រូវបានចាត់តាំងឲ្យចូលបម្រើការងារជាមន្ត្រីផ្នែកសុខភាពផ្លូវកាយសម្រាប់ព្យាបាលឲ្យកងកម្លាំងយោធានៅបន្ទាយយោធាមួយដែលមានទីតាំងនៅក្បែរមន្ទីរពេទ្យនោះ ។ នៅពេលនោះ ខ្ញុំបានជួបជាមួយប្រពន្ធរបស់ខ្ញុំឈ្មោះ យីហៀង ហើយខ្ញុំបានរៀបការជាមួយគាត់ និងមានកូនពីរនាក់ (ប្រុសទាំងពីរ) ។ កូនប្រុសច្បងរបស់ខ្ញុំដែលមានឈ្មោះថា ដូរ៉ាកើតនៅក្នុងឆ្នាំ១៩៧១ ចំណែកឯកូនប្រុសពៅឈ្មោះ ដូរិទ្ធកើតក្នុងឆ្នាំ១៩៧៣ ។ ខ្ញុំធ្វើជាគ្រូពេទ្យនៅឯបន្ទាយទាហានរហូតដល់ពេលខ្មែរក្រហមចូលកាន់កាប់នៅក្នុងឆ្នាំ១៩៧៥ ។

ដូចអ្នកផ្សេងទៀតដែរ ខ្ញុំត្រូវបង្ខំឲ្យភៀសខ្លួនចេញពីទីក្រុងភ្នំពេញឲ្យបានឆាប់រហ័សបន្ទាប់ពីខ្មែរក្រហមចូលមកដល់ទីក្រុង ។ អំឡុងពេលស្ថានភាពជ្រួលច្របល់បែបនេះ គ្រួសាររបស់ខ្ញុំបន្តដំណើរឆ្ពោះទៅទិសខាងត្បូង តម្រង់ទៅតាខ្មៅដើម្បីឲ្យទៅដល់ស្រុកកំណើតរបស់ខ្ញុំនៅភូមិព្រែកឫស្សី ។ ប៉ុន្តែភ្លាមៗនៅពេលដែលយើងទៅដល់វង់មូលក្បាលថ្នល់ខ្មែរក្រហមបញ្ជាឲ្យយើងធ្វើដំណើរទៅទិសខាងកើតឆ្លងកាត់ស្ពានមុនីវង្សច្បារអំពៅ ។ នៅច្បារអំពៅ ខ្ញុំបានជួបប្អូនថ្លៃខ្ញុំម្នាក់ និងក្រុមគ្រួសាររបស់គាត់ ។ ប្អូនថ្លៃរបស់ខ្ញុំប្រាប់ថា យើងគួរតែធ្វើដំណើរទៅមុខទៀតដោយនៅទីនោះមានមនុស្សនៅច្រើនពេក ។ ដូច្នេះយើងបន្តដំណើររហូតទៅដល់ព្រែកឯង ។ យើងស្នាក់នៅព្រែកឯងអស់រយៈពេលប្រហែល




តាំង ស៊ីនឿន លឹម គឹមឡេង តាំង មេតី

មួយខែ ។

ពេលមួយដែលយើងស្នាក់នៅព្រែកឯង ខ្ញុំបានឃើញសេចក្តីប្រកាសមួយបិទលើក្តារព័ត៌មានថា ស្វែងរកអតីតមន្ត្រីរាជការដើម្បីចូលរួមស្វាគមន៍សម្តេច នរោត្តម សីហនុ ។ មនុស្សជាច្រើនជឿលើល្បិចបញ្ឆោតនេះ ហើយអ្នកទាំងនោះទៅបាត់មិនដែលត្រឡប់មកវិញទេ ។ ខ្ញុំគិតថា ខ្មែរក្រហមប្រហែលជាសម្លាប់អ្នកទាំងនោះអស់ហើយ ។ ថ្ងៃមួយ ពេលដែលខ្ញុំកំពុងឈរតម្រង់ជួរដើម្បីចាំទទួលយករបបអាហារ ខ្ញុំបានប្រទះឃើញកម្មាភិបាលខ្មែរក្រហមដែលខ្ញុំដូចជាធ្លាប់ស្គាល់ ។ ក្រោយពីគិតយូរៗទៅ ខ្ញុំក៏នឹកឃើញថា ខ្ញុំធ្លាប់ជួបគាត់នៅពេលដែលខ្ញុំធ្វើការនៅទីក្រុងភ្នំពេញ ។ នៅពេលនោះ ខ្ញុំមានអារម្មណ៍ថាជីវិតខ្ញុំនឹងជួបបញ្ហាហើយ ដោយសារខ្ញុំធ្លាប់ធ្វើជាគ្រូពេទ្យឲ្យទាហាន លន់ នល់ ហើយគិតថាខ្មែរក្រហមនឹងមិនទុកជីវិតឲ្យខ្ញុំទេ ដូច្នេះខ្ញុំក៏សម្រេចចិត្តចាកចេញពីព្រែកឯងភ្លាម ។

ដំបូងយើងធ្វើដំណើរទៅកាន់វត្តចំពុះក្អែក បន្ទាប់មកទៀតយើងឆ្លងកាត់ទន្លេបាសាក់ត្រឡប់ទៅត្រើយខាងលិចទន្លេបាសាក់ ។ ក្រោយមកទៀត យើងដើរទៅកាន់ព្រែករទាំង ហើយស្នាក់នៅទីនោះមួយរយៈ ។ ពេលនោះខ្ញុំឈឺហើយ ខ្ញុំត្រូវអង្គការបញ្ជូនឲ្យទៅព្យាបាលនៅឯមន្ទីរពេទ្យមួយ ។ យើងបានស្នាក់នៅព្រែករទាំងរហូតដល់ខែកញ្ញា នៅពេលដែលខ្មែរក្រហមចាប់ផ្តើមបញ្ជូនប្រជាជនថ្មីទៅកាន់ភាគខាងលិចនៃប្រទេស ។

យើងបានធ្វើដំណើរដោយគោយន្តពីព្រែករទាំងទៅកាន់ភូមិមួយមានឈ្មោះថាភូមិព្រៃស្វាយដែលមានទីតាំងនៅតាមបណ្តោយផ្លូវជាតិលេខ៥ នៅក្នុងស្រុកមោងឫស្សីខេត្តបាត់ដំបង ។ នៅពេលយើងមកដល់ភូមិព្រៃស្វាយ ខ្មែរក្រហមបានបញ្ជាឲ្យយើងធ្វើដំណើរបន្តទៀតដោយថ្មើរជើងទៅកាន់ភូមិចាមរអារដែលជាភូមិដាច់ស្រយាលមួយ ។ បន្ទាប់ពីទៅដល់ភូមិចាមរអារ ខ្ញុំបានស្នាក់នៅក្នុងបរិវេណវត្តមួយដែលត្រូវបានបោះបង់ចោល ។ ទោះបីជាបែបនោះក៏ដោយ បន្ទាប់ពីខ្មែរក្រហមរុះរើវត្តនោះ ខ្ញុំបានទៅស្នាក់នៅភូមិរណបដែលត្រូវបានខ្មែរក្រហមបង្កើតសម្រាប់ប្រជាជនថ្មីរស់នៅ ។

ក្នុងខែធ្នូឆ្នាំ១៩៧៥ អស់រយៈពេលបីខែបន្ទាប់ពីមកដល់ភូមិចាមរអារ ខ្ញុំត្រូវអង្គការចាត់តាំងឲ្យអូសរទេះគោដឹកសម្ភារពីកន្លែងមួយទៅកន្លែងមួយ ពេលខ្លះរទេះដែលខ្ញុំអូសទឹមជាមួយនឹងសត្វគោ ហើយពេលខ្លះទៀតទឹមជាមួយនឹងសត្វក្របីដែលទុកប្រើសម្រាប់ភ្ជួររាស់ដី ។ មានម្តងនោះអំឡុងពេលដែលខ្ញុំកំពុងអូសរទេះ ខ្ញុំបានរអិលដួលចូលក្រោមនឹមរទេះគោនោះ ។ ខ្ញុំមានបញ្ហាឈឺត្រគាក ដោយសារតែមកពីគ្រោះថ្នាក់ដោយចៃដន្យនោះ ហើយបានធ្វើឲ្យរាងកាយខ្ញុំមានបញ្ហាអសមត្ថភាពអំឡុងពេលនោះ ។ ដោយសារតែខ្ញុំមិនបានទទួលការព្យាបាលភ្លាមៗនៅពេលនោះ ខ្ញុំបានចំណាយពេលប្រាំមួយខែទម្រាំតែរបួសត្រគាកបានជាសះស្បើយឡើងវិញ ។ អំឡុងពេលពីរទៅបីខែដំបូង ខ្ញុំពិបាកស៊ូទ្រាំនឹងការឈឺចាប់របួសនោះណាស់ ។ ខ្ញុំចំណាយពេលរាល់ថ្ងៃដើម្បីព្យាបាលខ្លួននៅក្នុងខ្ទមជាមួយនឹងកូនប្រុស ចំណែកឯប្រពន្ធរបស់ខ្ញុំត្រូវទៅធ្វើស្រែឆ្ងាយពីភូមិ ។ ពេលនោះ ខ្ញុំបានបាត់បង់កូនប្រុសច្បងរបស់ខ្ញុំរួចទៅហើយដោយសារតែអត់អាហារ ។

ប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៦ បន្ទាប់ពីរបួសរបស់ខ្ញុំបានជាសះស្បើយដោយខ្លួនវាតាមធម្មជាតិ ខ្ញុំបានស្នើសុំអ្នកដែលធ្វើការនៅក្នុងព្រៃឲ្យជួយកាប់ឫស្សីព្រៃមួយចំនួន ដូច្នេះខ្ញុំអាចយកឫស្សីព្រៃនោះមកធ្វើជាឈើច្រត់ ។ បន្ទាប់ពីខ្ញុំធ្វើឈើច្រត់រួចហើយ ខ្ញុំរៀនដើរម្តងទៀត ហើយខ្ញុំអាចដើរបានដោយសារតែមានការជួយពីឈើច្រត់នេះ ។

គ្រាមួយ នៅពេលដែលឃើញខ្ញុំអាចដើរបាន កម្មាភិបាលខ្មែរក្រហមក៏មកជួបខ្ញុំ ហើយនិយាយថា ខ្ញុំមិនអាចប្រើជើងរបស់ខ្ញុំបានតែដៃរបស់ខ្ញុំនៅល្អទេ ។ ដូច្នេះ កម្មាភិបាលនោះក៏ស្នើសុំឲ្យខ្ញុំទៅធ្វើការជាមួយនឹងក្រុមជំនាញអូសទាញម៉ាស៊ីនបូមទឹក និងការងារផ្សេងៗទៀតដែលខ្ញុំអាចធ្វើបានដោយប្រើដៃរបស់ខ្ញុំ ។ ខ្ញុំគួរតែរៀបរាប់អំពីស្ថានភាពក្រុមគ្រួសាររបស់ខ្ញុំឲ្យបានកាន់តែលម្អិតជាងនេះទៀត អំពីស្ថានភាពតាំងពីពេលដំបូង ពេលដែលយើងមកដល់ភូមិចំរអារនេះ ។ នៅពេលយើងមកដល់ភូមិចំរអារ ម្តាយក្មេករបស់ខ្ញុំ ប្រពន្ធរបស់ខ្ញុំ និងកូនទាំងពីរ គឺនៅជួបជុំគ្នាទាំងអស់ ។ ភ្លាមៗបន្ទាប់ពីមកដល់ទីនោះ ម្តាយក្មេករបស់ខ្ញុំបានស្លាប់ ។ ពីរបីខែបន្ទាប់ទៀត កូនប្រុសច្បងរបស់ខ្ញុំស្លាប់ដោយសារអត់អាហារ ។ មិនយូរប៉ុន្មានបន្ទាប់ពីការស្លាប់របស់កូនប្រុសច្បង

ខ្ញុំបានជួបគ្រោះថ្នាក់ហើយ ធ្វើឲ្យប៉ះពាល់ដល់ត្រគាក ។ អំឡុងពេលដែលខ្ញុំដេកសម្រាកលើគ្រែជារៀងរាល់ថ្ងៃដើម្បីឲ្យរបួសជាសះស្បើយ នៅពេលនោះប្រពន្ធរបស់ខ្ញុំក៏បានស្លាប់ទៀត ។ ទាំងប្រពន្ធនិងកូនប្រុសច្បងរបស់ខ្ញុំស្លាប់មួយខែបន្តបន្ទាប់គ្នា ដោយសារការអត់ឃ្លាន ។ មានតែកូនប្រុសពៅរបស់ខ្ញុំទេដែលមានជីវិតនិងរស់នៅជាមួយខ្ញុំនាពេលនោះ ។ បន្ទាប់ពីខ្ញុំជាសះស្បើយពីរបួសហើយនឹងអាចដើរបានតែដោយពឹងផ្អែកលើឈើច្រត់កូនប្រុសពៅរបស់ខ្ញុំក៏បានស្លាប់ទៀត ។ អាស្រ័យហេតុនេះហើយ សមាជិកគ្រួសាររបស់ខ្ញុំទាំងអស់ស្លាប់នៅក្នុងរយៈពេលប្រាំបួនខែដំបូងបន្តបន្ទាប់គ្នា ពេលដែលរស់នៅភូមិចំរអារ ។

នៅពេលដែលកូនប្រុសពៅរបស់ខ្ញុំស្លាប់ ប្រជាជនថ្មីជាច្រើនដែលត្រូវបង្ខំឲ្យរស់នៅទីនោះក៏ ស្លាប់បន្តបន្ទាប់គ្នាដែរ ។ ដូច្នេះមិនមានមនុស្សច្រើនទេរស់នៅជិតខ្ញុំ ។ ខ្ញុំបានយកចបជីកទៅជីកផ្នូរដែលមានចម្ងាយបួនប្រាំម៉ែត្រពីខ្ទមដែលខ្ញុំស្នាក់នៅហើយកប់សាកសពកូនប្រុសរបស់ខ្ញុំ តែម្នាក់ឯងនៅទីនោះ ។ ពីព្រោះតែគ្មាននរណាម្នាក់ដឹងថា កូនពៅរបស់ខ្ញុំស្លាប់ ខ្ញុំនៅតែបន្តយករបបអាហាររបស់កូនប្រុសខ្ញុំ ពីផ្ទះបាយរបស់សហករណ៍ដើម្បីចម្អែតក្រពះរបស់ខ្លួន ។ ប៉ុន្តែ មានមនុស្សម្នាក់ចាប់អារម្មណ៍ពីអវត្តមានរបស់កូនប្រុសពៅខ្ញុំ ក្រុមកម្មាភិបាលខ្មែរក្រហមក៏មកតាមស៊ើបសួរអំពីរឿងនេះ ហើយខ្ញុំបានប្រាប់គេថា គាត់ទើបស្លាប់ថ្មីៗនេះទេ ។ កម្មាភិបាលមិនជឿអ្វីដែលខ្ញុំបានប្រាប់នោះទេ ហើយខ្ញុំត្រូវបានចោទប្រកាន់ថាស៊ីសាច់កូនខ្លួនឯង ។ កម្មាភិបាលនោះបានប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំពិតជាស្អាតស្អំមែន ខ្ញុំត្រូវបង្ហាញអំពីកន្លែងកប់សាកសពកូនប្រុសរបស់ខ្ញុំ ដូច្នេះគេអាចជីកផ្នូរនោះដើម្បីយកមកពិនិត្យពិច័យថាតើវាជាសាកសពកូនរបស់ខ្ញុំមែនដែរឬទេ ។

ដោយឃើញជាក់ស្តែងថា កម្មាភិបាលខ្មែរក្រហមនេះពិតជាមិនឲ្យកូនប្រុសរបស់ខ្ញុំបានទៅកាន់សុគតិភពនោះទេ ខ្ញុំក៏បានចង្អុលប្រាប់ពីទីកន្លែងកប់សាកសពនោះ ហើយកម្មាភិបាលទាំងនោះបម្រុងនឹងជីកយកសាកសពនោះមកពិនិត្យពិច័យដើម្បីធ្វើជាភ័ស្តុតាង ។ ប៉ុន្តែ ក៏បោះបង់ការតាំងចិត្តនេះចោលនៅពេលមកដល់កន្លែងសាកសពស្អុយរលួយរបស់កូនប្រុសខ្ញុំ ដោយសារតែមិនអាចទ្រាំទ្របាននូវក្លិនអសោចសាយភាយពីសាកសពបាន ។ បន្ទាប់ពីជឿជាក់ថាកូនប្រុសរបស់ខ្ញុំពិតជាបានស្លាប់ពិតប្រាកដមែន កម្មាភិបាលខ្មែរក្រហមក៏ចាកចេញពីទីនោះទៅ ។

ខណៈពេលដែលខ្ញុំធ្វើការជាមួយក្រុមជំនាញ ខ្ញុំត្រូវបានកម្មាភិបាលខ្មែរក្រហមបញ្ជាឲ្យជួសជុលម៉ាស៊ីនម៉ូតូម៉ាកហុងដាដ៏កញ្ចាស់មួយ ដើម្បីឲ្យវាមានដំណើរការ និងច្នៃប្រឌិតឲ្យកង្ហារវាវិល ។ ខ្ញុំបានធ្វើឲ្យម៉ាស៊ីននោះដំណើរការ ហើយបន្ទាប់ពីដំណើរការហើយ កង្ហាររបស់វាក៏ខូច ហើយបង្កឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់មេក្រុមរបស់យើងដែលដឹកនាំធ្វើការងារ ។ ពេលនោះ ខ្ញុំគិតថាខ្ញុំនឹងត្រូវស្លាប់ហើយ ដោយសារតែខ្ញុំបរាជ័យក្នុងការជួសជុលម៉ាស៊ីនឲ្យមានដំណើរការប្រក្រតី ហើយថែមទាំងបង្កគ្រោះថ្នាក់ដល់មនុស្សដែលតែងតែចាំតែចោទប្រកាន់ធ្វើទុកបុកម្នេញដល់យើងដែលជាប្រជាជនថ្មី ។ ថ្ងៃបន្ទាប់ទៀត ប្រធានភូមិបានចូលមកមើលទិដ្ឋភាពនោះ ហើយក៏ព្រមានខ្ញុំ ។ ពីរទៅបីខែបន្ទាប់ពីគ្រោះថ្នាក់ចៃដន្យដោយសារម៉ាស៊ីនម៉ូតូនោះ ឈ្លបខ្មែរក្រហមមកហៅខ្ញុំឲ្យទៅជួបមេរបស់ខ្លួន ។ ខ្ញុំក៏បានទៅជួបភ្លាមៗ ហើយបានរកឃើញថា កូនប្រុសរបស់គាត់ពិតជាឈឺធ្ងន់ ។ មេនោះក៏បានស្នើសុំឲ្យខ្ញុំពិនិត្យមើលអាការៈរបស់កូនប្រុសគាត់ ហើយប្រាប់គាត់ថាមានអ្វីខុសប្រក្រតីចំពោះកូនប្រុសរបស់គាត់និងថាតើមានវិធីណាដែលអាចព្យាបាលជំងឺនេះបាន ។ បន្ទាប់ពីធ្វើការពិនិត្យអាការៈកូនប្រុសគាត់រួចរាល់ហើយ ខ្ញុំបានប្រាប់អាការៈរោគរបស់កូនប្រុសគាត់ពីរទៅបីចំណុចហើយខ្ញុំស្នើសុំគាត់ថា ប្រសិនបើគាត់អាចស្វែងរកថ្នាំម្យ៉ាងដែលត្រូវទៅនឹងជំងឺគាត់ប្រហែលជាអាចជួយជីវិតកូនប្រុសរបស់គាត់បាន ។ មេនោះបានប្រាប់ខ្ញុំថាគ្មានបញ្ហានោះទេ គាត់អាចរកថ្នាំទំនើបៗមកបាន ។ គ្រាន់តែសរសេរឈ្មោះថ្នាំនោះឲ្យគាត់ទៅបានហើយ ។ នៅខណៈពេលនោះ ខ្ញុំដឹងថាជីវិតរបស់ខ្ញុំគឺស្ថិតក្នុងកណ្តាប់ដៃបុរសនោះហើយ ព្រោះការសរសេរឈ្មោះថ្នាំទំនើបត្រូវតែសរសេរជាអក្សរភាសាបារាំងឬមួយភាសាអង់គ្លេស ហើយនៅពេលដែលខ្ញុំអាចសរសេរជាភាសាបរទេសភ្ជាប់ជាមួយនឹងសមត្ថភាពរបស់ខ្ញុំដែលអាចវិនិច្ឆ័យរោគបានផងនោះ គាត់នឹងដឹងថាខ្ញុំជាអ្នកណាហើយ ។ ប៉ុន្តែខ្ញុំស្ថិតនៅក្នុងស្ថានភាពដែលមិនអាចបកក្រោយបាន ដូច្នេះហើយខ្ញុំគិតថាប្រសិនបើខ្ញុំស្លាប់ហើយអាចជួយជីវិតក្មេងម្នាក់



តាំង ស៊ីនឿន និងភរិយាឈ្មោះ លីម គីមឡេង

នោះបាន ខ្ញុំក៏សុខចិត្ត ។

បន្ទាប់ពីទទួលបានថ្នាំព្យាបាល ក្មេងនោះក៏បានជាសះស្បើយពីជំងឺ ហើយឪពុករបស់ក្មេងនោះ ក៏បានលាក់ការជាសម្ងាត់អំពីសមាសភាពរបស់ខ្ញុំលើសពីនេះទាំងដោយសារតែគាត់ចង់ទុកខ្ញុំឲ្យជួយព្យាបាលពេលក្រោយ នៅពេលដែលគាត់ឬមួយក្រុមគ្រួសាររបស់គាត់មានបញ្ហាសុខភាពនិងការធ្វើជាបារម្ភអំពីសុវត្ថិភាពរបស់ខ្ញុំ ។ មានតែព្រះទេដែលដឹងពីអារម្មណ៍ពិត ។ ប៉ុន្តែខ្ញុំអាចស្នើសុំឲ្យគាត់ធ្វើរឿងមួយសម្រាប់ខ្ញុំជាការតបស្នងនៅពេលដែលប្រពន្ធក្រោយរបស់ខ្ញុំឈ្មោះ គីម ឡេង មានជំងឺជាទម្ងន់ ។

ប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៧ ការបះបោរប្រឆាំងជាមួយនឹងខ្មែរក្រហមបានកើតឡើង ។ ដោយសារតែការចងកំហឹងជាមួយនឹងខ្មែរក្រហម ខ្ញុំក៏បានចុះចូលនឹងក្រុមខុទ្ទាមសម្ងាត់នេះ ហើយខ្ញុំអាចបញ្ចុះបញ្ចូលអ្នកមូលដ្ឋានមួយចំនួនទៀតឲ្យចូលរួមបះបោរ ។ ជាអកុសល សកម្មភាពបះបោររបស់យើងនេះត្រូវបានខ្មែរក្រហមដឹង ហើយសមាជិកយើងជាច្រើនត្រូវបានចាប់ចងនិងសម្លាប់ ។ ខ្ញុំបានរួចខ្លួនពីការសម្លាប់នោះដោយសារតែឈ្មោះខ្ញុំប្រហែលជាត្រូវបានដកចេញពីបញ្ជីឈ្មោះនោះ ។

ខ្ញុំជួបជាមួយប្រពន្ធទីពីររបស់ខ្ញុំដែលមានឈ្មោះថា គីមឡេង បន្ទាប់ពីខ្ញុំបានចូលរួមសកម្មភាពបះបោរ ។ ប្រហែលជានៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ នៅពេលដែលក្រុមការងាររបស់ខ្ញុំឈ្មោះ ញ៉ី មករកខ្ញុំ ហើយប្រាប់ខ្ញុំថា គីមឡេង កំពុងតែភ័យខ្លាចដោយសារតែ គីមឡេង ត្រូវបានបង្ខំឲ្យគាត់រៀបការជាមួយនឹងកម្មាភិបាលខ្មែរក្រហមម្នាក់ដែលគាត់មិនពេញចិត្ត ។ ដូច្នេះហើយដើម្បីជួយសង្គ្រោះជីវិតរបស់ គីមឡេង ពីការបង្ខិតបង្ខំឲ្យរៀបការនោះ ញ៉ី ក៏ស្នើសុំឲ្យខ្ញុំរៀបការជាមួយ គីមឡេង មុនពេលដែលខ្មែរក្រហមអាចសម្រេចទៅតាមគម្រោងបាន ។ បន្ទាប់ពីខ្ញុំបានដឹងពីស្ថានភាពរបស់គាត់ និងការបាត់បង់នូវសមាជិកក្រុមគ្រួសាររបស់ គីមឡេង យើងទាំងពីរនាក់មានការឈឺចាប់ ហើយខ្ញុំមានអារម្មណ៍ថា យើងទាំងពីរនាក់បានឆ្លងកាត់នូវការឈឺចាប់ស្រដៀងគ្នានៅក្នុងឆាកជីវិតនេះ ។ ដូច្នេះ ខ្ញុំក៏យល់ព្រមជាមួយនឹងការស្នើសុំរបស់ ញ៉ី ។

**តាំង ស៊ីនឿន**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ៈ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល សហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 158, February 2013 ◆ Funded by USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.